ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ដើម្បីយុត្តិធម៌សម្រាប់ជនរួមជាតិ
- [illegible]

[illegible]

[illegible]

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត

លេខ៣២ ខែសីហា ឆ្នាំ២០០២

## មាតិកា

◆ សំបុត្រៈ ដើម្បីយុត្តិធម៌សម្រាប់មនុស្សជាតិ................................១

### ផ្នែកឯកសារ

◆ ទូន សុខផល្លា .................................................................៣

◆ ទីតាំងវាលពិឃាតខេត្តពោធិសាត់...................................៨

◆ បញ្ជីឈ្មោះជនរងគ្រោះបរទេស..........................................១៤

◆ ក្បួនទ័ពព្រៃខ្មែរក្រហម .....................................................១៦

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ..........២១

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ សម្លេងពីមន្ទីរ ស-២១(តចប់)..........................................២៣

◆ប្រព័ន្ធសន្តិសុខភូមិភាគនិរតី ...................................................២៨

### ផ្នែកច្បាប់

◆ ការលើកលែងទោសនិងការអភ័យទោស ...............................៣៤

◆ ការផ្សឹកព្រះសង្ឃ .........................................................៣៦

### វេទិកាពិភាក្សាសាធារណៈ

◆ មហាអំណាចក្លែងបុកនិងតុលាការខ្មែរក្រហម ............................៤២

◆ ភ្នាក់ងារផ្ដាច់ព្រលឹង ........................................................៤៨

◆ ស្វែងយល់នូវព្រះពុទ្ធដីកា ..................................................៥៤

### ធំព័រស្រាវជ្រាវរកគ្រួសារ

◆ ដរាបណាគ្មានយុត្តិធម៌ ឡាច នី នៅតែវិលវល់ .......................៥៨

◆ ចម្លើយសារភាពរបស់ឪពុកខ្ញុំ.............................................៦០

### សិល្បៈខ្មែរក្រហមៈ

◆ រូបថតអ្នកទោសនៅមន្ទីរស-២១ .............................គ្របក្រោយ



ពុទ្ធបដិមានៅវត្តកែវព្រះភ្លើង (រូបថតឆ្នាំ១៩៧៩)

## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩
រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ:** ដេវីដ ឆេនដល័រ, អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ចន ឆរឆីអារី, អាឡិច ហ៊ីនតុន, ដេង ពង្សរ៉ាស៊ី, អៀ ម៉េងទ្រី **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងទី១ៈ** សួ ប៊ុនស៊ូ **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** សុខ វណ្ណៈ

*សំបុត្រៈ*

# ដើម្បីយុត្តិធម៌សម្រាប់មនុស្សជាតិ

នៅខែកុម្ភៈ ឆ្នាំ២០០២ អង្គការសហប្រជាជាតិបានដកថយចេញពីការចរចាជាមួយរដ្ឋាភិបាលកម្ពុជាស្តីអំពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងសំណេរទៅកាន់សារពត៌មាន ហ្វេរ៉ូលទ្រីប៊ូន នៅថ្ងៃទី១៩ ខែកក្កដា លោក ហេន កូរ៉េល អគ្គលេខាធិការរងអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់បានពន្យល់ និងការពារសេចក្តីសម្រេចចិត្តដ៏សំខាន់នេះ ។

លោក កូរ៉េល ទាញហេតុផលថា តាំងពីមុនរហូតមកដល់បច្ចុប្បន្ននេះ រដ្ឋាភិបាលកម្ពុជាមិនដែលមានសុឆន្ទៈចុះហត្ថលេខាលើកិច្ចព្រមព្រៀងដែលជាការធានាដល់សុច្ចរិតភាពនៃអង្គជំនុំជម្រះវិសាមញ្ញនេះឡើយ ហើយថា អង្គការសហប្រជាជាតិមិនអាចយកឈ្មោះរបស់ខ្លួនទៅប្រឡូកប្រឡាក់ជាមួយអង្គជំនុំជម្រះវិសាមញ្ញដែលខ្លួនមានការគ្រប់គ្រងដ៏តិចតួចបំផុតនោះទេ ។ លោក កូរ៉េល ក៏បានសរសេរបន្តទៀតថា អង្គការសហប្រជាជាតិគ្មានបំណងចង់ចូលរួមនៅក្នុងដំណើរការជំនុំជម្រះទោសដែលមិនអាចផ្តល់នូវ «យុត្តិធម៌ដែលគួរឲ្យជឿជាក់» ចំពោះជនរងគ្រោះរបស់ខ្មែរក្រហម ហើយនិងដែលមានកម្រិតទាបជាងបទដ្ឋានយុត្តិធម៌អន្តរជាតិ ។

សេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិនេះបានធ្វើឲ្យសាធារណជនជាច្រើនមានការខកចិត្ត ។ ជាការច្បាស់ណាស់ថា ប្រជាជនកម្ពុជា (ជនរងគ្រោះ និងជនដៃដល់) មានបំណងប្រាថ្នាចង់ឲ្យមានការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម ។ ដូចដែលលោក កូរ៉េល បានឲ្យយោបល់យ៉ាងដូច្នេះដែរថាប្រព័ន្ធតុលាការកម្ពុជាមានចំណុចខ្វះខាតច្រើន ។ បើគ្មានកិច្ចគាំទ្រពីសំណាក់អន្តរជាតិទេនោះ ការផ្តល់នូវយុត្តិធម៌ដែលគួរឲ្យទុកចិត្តគឺពិបាកនឹងសម្រេចបានណាស់ ។

អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា មិនទាន់បញ្ចប់កិច្ចព្រមព្រៀងឲ្យបានពេញលេញនៅឡើយ ក៏ប៉ុន្តែសហគមន៍អន្តរជាតិបានបញ្ចេញជម្រើសនានាឥតស្រាកស្រានដើម្បីជំរុញឲ្យមានអង្គជំនុំជម្រះវិសាមញ្ញមួយដែលប្រកបដោយយុត្តិធម៌ ។ ម្ចាស់ជំនួយទ្វេភាគីនិងពហុភាគីគួរតែពិចារណាអំពីសារសំខាន់នៃការជំនុំជម្រះក្តីដែលបានស្នើឡើងនេះ ទាំងទៅលើសីលធម៌ និងគំនិតអភិវឌ្ឍ ។ ការគ្មានយុត្តិធម៌ចំពោះទង្វើរបស់មេដឹកនាំខ្មែរក្រហមដែលបានធ្វើឲ្យប្រជាជនកម្ពុជារាប់លាននាក់បាត់បង់ជីវិត គឺជាការធ្វើឲ្យកម្ពុជាវិលវល់និងបន្ទុចបន្ទាក់ដល់ការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចសង្គម ។ ប្រជាជនកម្ពុជានឹងមានការខ្វះជំនឿទៅលើប្រព័ន្ធតុលាការដែលផ្តន្ទាទោសតែឧក្រិដ្ឋជនតូចតាច ហើយបែរជាបណ្តែតបណ្តោយឲ្យមេគំនិតប្រល័យពូជសាសន៍ក្លាយទៅជាជនដែលច្បាប់មិនអាចប៉ះពាល់បានទៅវិញ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលគាំទ្រដោយអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិនិងមានលក្ខណៈរឹងមាំឈានទៅសម្រេចបាននូវយុត្តិធម៌ ការផ្សះផ្សាជាតិស្តារឡើងវិញនូវជំនឿជឿជាក់ទៅលើប្រព័ន្ធច្បាប់កម្ពុជា ហើយនិងត្រួសត្រាយផ្លូវឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយនិរន្តរភាព ។ អង្គការសហប្រជាជាតិត្រូវតែចូលរួមសាជាថ្មីនៅក្នុងដំណើរការស្វែងរកយុត្តិធម៌និងប្រើវិធីសាស្ត្របន្ថែមទៀតដើម្បីជំរុញឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមួយដែលប្រកបដោយយុត្តិធម៌ ។ ជាការសំខាន់បំផុត កេរ្តិ៍ឈ្មោះរបស់អង្គការសហប្រជាជាតិ និងការថែរក្សាបទដ្ឋានយុត្តិធម៌អន្តរជាតិ គឺពឹងផ្អែកលើកត្តានេះឯង ។

អង្គការសហប្រជាជាតិ និង រដ្ឋាភិបាលកម្ពុជា គួរពិនិត្យសាឡើងវិញនូវជំហររបស់ខ្លួនចំពោះការចរចា និងបន្តការចរចាទៅតាមគន្លងដែលប្រកបដោយន័យស្ថាបនាតាមតែអាចធ្វើទៅបាន ។

**ឆាំង យុ**



ទួន ឃឿន និង ទួន សុខផល្លា

## សង្ខេបចេញពីឯកសារចម្លើយសារភាព:

# ទូន សុខផល្លា

ទូន សុខផល្លា គឺជាប្រធានផ្នែកបច្ចេកទេសនៅមន្ទីរស-៨ ។ មន្ទីរស-៨ ជាផ្នែកមួយស្ថិតក្រោមក្រសួងសាធារណការ នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងចម្លើយសារភាពរបស់ ទូន សុខផល្លា បានបញ្ជាក់អំពីសកម្មភាពរបស់ ភិន (តូច ភឿន ហៅ ភិន ដែលជារដ្ឋមន្ត្រីក្រសួងសាធារណការនៃរបបកម្ពុជាប្រជាធិបតេយ្យ) ថា “លុះក្រោយរំដោះទូទាំងប្រទេសហើយ បង ភិន បានស្នើខ្លួនខ្ញុំយកមកបម្រើការងារនៅក្រសួងសាធារណការវិញ ។ ទន្ទឹមនេះ គាត់ក៏ស្នើ ម៉ៃ សាខន, ម៉ែន និថូ, ភុក គី មកឲ្យធ្វើការនៅក្នុងក្រសួងនេះវិញដែរ មិនបានស្នើតែ ឈុន សុខងួន ម្នាក់ ដោយហេតុថា មានជាប់ភារកិច្ចនៅកំពង់ផែកំពង់សោមរួចហើយ ។ នៅក្នុងចំណោមពួកខ្ញុំទាំង៤នាក់នេះ ម៉ៃ សាខន មានការទាក់ទងជិតដិតជាមួយបងភិនច្រើនជាងគេ ។ ប្រពន្ធ ម៉ៃ សាខន ត្រូវជាក្មួយបង្កើតរបស់បងទូច ដែលជាគ្រួសារបងភិន ។ ហេតុនេះការទាក់ទងរវាងបងភិន និង ម៉ៃ សាខន មានលក្ខណៈស្និទ្ធស្នាលជាគ្រួសារតាំងពីក្នុងឆ្នាំ១៩៦៧ មកម្ល៉េះ ។ ម៉ៃ សាខន នេះត្រូវអង្គការដកភារកិច្ចទាំងអស់នៅក្រោយរំដោះទូទាំងប្រទេស ហើយយកមកត្រៀមធ្វើស្រែនៅកំពង់ស្ពឺ ។ ប៉ុន្តែបងភិនបានស្នើយកគាត់មកក្រសួងសាធារណការ ដំបូងបងភិនត្រៀមឲ្យធ្វើប្រធានមន្ទីរស-៨ ។ លុះមិនបានសម្រេចតាមការរៀបចំនេះ បងភិនក៏ចាត់តាំងគាត់ឲ្យធ្វើជាសមាជិកគណៈមន្ទីរ ហើយទទួលខុសត្រូវគ្រប់គ្រងការដ្ឋាននៅក្នុងក្រុងទាំងមូល ។ ហេតុនេះនៅក្នុងសកម្មភាពប្រឆាំងបដិវត្តនៅក្នុងមន្ទីរស-៨ ម៉ៃ សាខន ជាអ្នកធ្វើការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយបងភិន” ។

មន្ទីរស-៨ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទូច (ឈឹម សុផន) ដែលជាប្រពន្ធរបស់ ភិន ។ នៅក្នុងមន្ទីរស-៨ សមាសភាពកម្មករមានចំរុះមកពីគ្រប់ភូមិភាគទាំងអស់ ។ កម្មករដែលមានចំនួនច្រើនបំផុត គឺកម្មករដែលមកពីតំបន់២៥, មកពីភូមិភាគបូព៌ា និង ភូមិភាគនិរតី ។

ចាប់តាំងពីដើមឆ្នាំ១៩៧៦ នៅក្នុងមន្ទីរស-៨ មានសកម្មភាពប្រមូលកម្លាំងប្រឆាំងបដិវត្ត ។ ជាដំបូងកម្លាំងស្នូល មាន៤នាក់ គឺ ម៉ៃ សាខន, ម៉ែន និថូ, ភុក គី និង ទូន សុខផល្លា ។ ភិន គឺជាអ្នកដឹកនាំកម្លាំងនេះ ។ សកម្មភាពរៀបចំកម្លាំងប្រឆាំងនឹងបដិវត្តមិនទាន់ទាំងបានទទួលលទ្ធផលធំដុំផង ស្រាប់តែ ម៉ៃ សាខន បានបាត់ខ្លួនពីក្នុងមន្ទីរនៅខែតុលា ឆ្នាំ១៩៧៦ ហើយ ទូន សុខផល្លា ត្រូវបានចាប់ខ្លួននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ។

### ប្រវត្តិសកម្មភាពរបស់ ទូន សុខផល្លា មុនឆ្នាំ១៩៧៥ រហូតដល់ពេលចាប់ខ្លួន

ទូន សុខផល្លា បានសារភាពជូនអង្គការថា សកម្មភាពក្បត់របស់ខ្លួនចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៩៦១ ។ នៅក្នុងឆ្នាំដដែលនេះ គាត់បានចូលសេ.អ៊ី.អា តាមរយៈ ខេង គេងអាន និង ឃួន (កុយ ធួន) ។ ទូន សុខផល្លា បានរៀបរាប់អំពី សកម្មភាព និង មូលហេតុនៃអំពើក្បត់របស់គាត់ថា នៅឆ្នាំ១៩៦០ ឈុន សុខងួន និងគាត់រៀនថ្នាក់ទី១ នៅវិទ្យាល័យកំពង់ចាម ស្របពេលដែល ឃួន បានផ្លាស់មកបង្រៀននៅទីនោះដែរ ។ ក្នុងការជួបគ្នាជាលើកដំបូង ឃួន នៅសួរសុខទុក្ខ ទូន សុខផល្លា និង ឈុន សុខងួន នៅឡើយ ដោយមិនទាន់លើកយកបញ្ហាស៊ីជម្រៅមកនិយាយទេ ។ ឃួន បានសួរអំពីការរៀនសូត្រប្រចាំថ្ងៃ អំពីជីវភាពរស់នៅក្នុងគ្រួសារ និង អំពីចំណូលចិត្តរបស់ ទូន សុខផល្លា និង ឈុន សុខងួន ។ ក្រៅពីនេះ ឃួន បានលើកសភាពការណ៍របស់សិស្សនៅភ្នំពេញដែលមានចលនាតស៊ូតាមរយៈសិស្សសភាមកនិយាយប្រាប់អ្នកទាំងពីរដោយរាក់ទាក់កក់ក្តៅដែលជាហេតុរឹតតែធ្វើឲ្យអ្នកទាំងពីរនេះស្រឡាញ់ទុកចិត្ត ឃួន ថែមទៀត ។ ការទាក់ទង

គ្នានេះបានប្រព្រឹត្តទៅជាញឹកញាប់និងមានភាពកាន់តែជិតស្និទ្ធនិងកាន់តែច្បាស់ថែមទៀត ។ ក្រោយមក យួន បានលើកអំពីសភាពការណ៍នយោបាយរួមមកណែនាំដោយនិយាយប្រាប់ថា "ចក្រពត្តិអាមេរិកមានផែនការទម្លាក់សីហនុ ចាប់តាំងពីឆ្នាំ១៩៥៨មក ។ ទៅថ្ងៃអនាគត ក៏នៅតែមានផែនការផ្តួលរំលំសីហនុនេះដដែល ។ ចំណែកបដិវត្តនៅខ្សោយមិនទាន់មានកម្លាំងសម្រាប់ទប់ទល់ជាមួយចក្រពត្តិអាមេរិកនៅឡើយ ។ ហេតុនេះចក្រពត្តិអាមេរិកនឹងគ្រប់គ្រងកម្ពុជាក្នុងពេលខាងមុខជាមិនខាន ។ ប៉ុន្តែដើម្បីគ្រប់គ្រងបានចក្រពត្តិអាមេរិកត្រូវការឲ្យមានមហាជនគ្រប់មជ្ឈដ្ឋានគាំទ្រវាដែរ" ។ ទីបំផុត ទួន សុខផល្លា និង ឈុន សុខងួន ក៏បានយល់ស្របក្នុងការធ្វើសកម្មភាពដើម្បីឲ្យអាមេរិកគ្រប់គ្រងកម្ពុជា ។ យួន បានបញ្ជាក់ប្រាប់អ្នកទាំងពីរថា អាមេរិកបានមកតាំងមូលដ្ឋាននៅពេញប្រទេសថៃ ប្រទេសលាវ និង វៀតណាមខាងត្បូង រួចជាស្រេចហើយដែរ ។ ក្នុងខែកញ្ញា ឆ្នាំ១៩៦១ ទួន សុខផល្លា និង ឈុន សុខងួន ត្រូវបានរៀបចំពិធីបញ្ចូលជាសេ.អ៊ី.អា ។ ពិធីបញ្ចូលនេះធ្វើឡើងនៅលើផ្ទះរបស់ យួន ដែលបានជួលនៅផ្ទុំទួលស្បូវ ។

ក្រោយពីបានទទួលការណែនាំទាំងនេះហើយ ទួន សុខផល្លា និង ឈុន សុខងួន ក៏បានបែកគ្នាមករៀននៅភ្នំពេញក្នុងឆ្នាំសិក្សា ១៩៦១-៦២ ។ ទួន សុខផល្លា រៀននៅវិទ្យាល័យស៊ីសុវត្ថិ ។ ឈុន សុខងួន រៀននៅវិទ្យាល័យដេកាត ។ អ្នកឯទៀតៗនៅរៀន និង ធ្វើសកម្មភាពជាបន្តទៀតនៅក្នុងខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៦៣ ទួន សុខផល្លា និង ឈុន សុខងួន បានមករៀនជាមួយគ្នាវិញដើម្បីត្រៀមប្រឡងចូលមហាវិទ្យាល័យទេពកោសល្យស៊ីវិល ។ ក្នុងឆ្នាំនេះ ទួន សុខផល្លា បាន ចូលរួមយ៉ាងសកម្មនៅក្នុងចលនាតស៊ូរបស់សិស្ស-និស្សិតនៅក្នុងទីក្រុងភ្នំពេញ រួមមានបាតុកម្ម, មិទ្ទីង និងការបាចខិតប័ណ្ណជាដើម ។

ក្នុងឆ្នាំ១៩៦២-៦៣ និង១៩៦៤នេះ សិស្ស-និស្សិតបានធ្វើសកម្មភាពផុលផុសជាប់ៗ ។ ហេតុនេះ ទើបនៅក្នុងការចុះឈ្មោះឃោសនាអប់រំនិស្សិតត្រូវបានទទួលឲ្យចូលរួមធ្វើសកម្មភាពជាមួយដោយឆាប់រហ័ស ។ គំនិតបង្កើតសមាគមនិស្សិតក៏បានផ្សព្វផ្សាយទូលំទូលាយក្នុងមជ្ឈដ្ឋាននិស្សិតទូទៅដែរ ។ យួន, ភោគ ឆាយ, ឈុន សុខងួន និង ទួន សុខផល្លា បាន កំណត់ថានឹងខិតខំកសាងនិងប្រមូលនិស្សិតឲ្យបានជាកម្លាំងខ្លាំងក្លាសម្រាប់ធ្វើសកម្មភាពនយោបាយទៅថ្ងៃអនាគតទៀត ។

ក្នុងខែមករា ឆ្នាំ១៩៦៥ សមាគមនិស្សិតត្រូវបានបង្កើតឡើងជាផ្លូវការដែលមាន ភោគ ឆាយ ជាប្រធាន និង ទួន សុខផល្លា ជាអគ្គលេខាធិការ ។ ចំណែក ឈុន សុខ ងួន, យិន គីមកេត, កង សារ៉ន, ហ៊ាន់ ពីធី, ប៉ុក កាណែល, អ៊ិន សុភាព, ភុក គី, អួន យាង, និង គិត សាំងជរ ក៏បានចូលក្នុងគណៈដឹកនាំសមាគមនិស្សិតនេះដែរ ។ ក្រោយពីសមាគមនេះបង្កើតឡើងបានប្រហែលកន្លះខែ គិញបានចាប់ខ្លួន ទួន សុខផល្លា យកទៅឃុំឃាំងដោយសារការធ្វើសកម្មភាពបាចខិតប័ណ្ណក្នុងដើមខែកុម្ភៈ ឆ្នាំ១៩៦៥ ។ នៅពេលដែល ទួន សុខផល្លា ជាប់ឃុំឃាំង ឈុន សុខងួន បានធ្វើកិច្ចការជំនួសទាំងអស់នៅក្នុងសមាគម ហើយ ជាប់ជាមួយ ភោគ ឆាយ រហូតមក ។ ពេលនោះ ទួន សុខផល្លា បានសរសេរញត្តិមួយលន់តួសម្តេចសីហនុឲ្យដោះលែងពីការឃុំឃាំងនោះមកវិញ ។

នៅដើមឆ្នាំ១៩៦៦ ទួន សុខផល្លា ត្រូវបានដោះលែង ។ ពេលនោះសភាពការណ៍ក្នុងចំណោមសមាគមនិស្សិតមានការប្រែប្រួលដោយសារអ្នកខ្លះត្រូវផ្ទេរទៅធ្វើការងាររកន្លែងផ្សេងៗពីគ្នា ។ ការទាក់ទងគ្នាមិនបានជាប់ជិតស្និទ្ធគ្នាដូចពេលមុនទៀតទេ ។ ក្រោយពីបានរួចពីឃុំឃាំងវិញ ទួន សុខផល្លា ក៏បានចូលរៀនក្នុងមហាវិទ្យាល័យទេពកោសល្យស៊ីវិលជាមួយ ឈុន សុខងួន និង ភុក គី វិញ ។ ក្នុងឆ្នាំ១៩៦៦នេះ សភាពការណ៍នយោបាយនៅកម្ពុជាមានការប្រែប្រួលមួយកម្រិតទៀត ។ ក្នុងការបោះឆ្នោតឆ្នាំនេះ ក្រុមដែលមាន លន់ ណុល ជាមេ បានឈ្នះឆ្នោតនៅក្នុងរដ្ឋសភា ។ លន់ ណុល បានឡើងធ្វើជានាយករដ្ឋមន្ត្រី ហើយកម្លាំងអាមេរិកកាន់តែមានប្រៀបលើកម្លាំងរបស់សម្តេចសីហនុ ។ ទន្ទឹមនឹងនេះបដិវត្តក៏ធ្វើការតស៊ូកាន់តែខ្លាំងក្លាដែរ ។

ចូលមកដល់ឆ្នាំ១៩៦៧ ទំនាស់នយោបាយនៅកម្ពុជាកាន់តែស្រួចស្រាល់ឡើង ។ នៅតាមជនបទមានផ្ទុះអាវុធនៅទីក្រុង ហើយមហាជនផុលផុសធ្វើការតស៊ូយ៉ាងខ្លាំង ។ ក្នុងពេល

នោះ ភោគ ឆាយ បានទទួលការណែនាំពីសេ.អ៊ី.អា តាមរយៈ សិរិមតៈ ឲ្យរៀបចំបង្កើតបក្សនយោបាយមួយដោយយកសមាគមនិស្សិតធ្វើជាកម្លាំងស្នូល ។ បក្សនយោបាយនេះបានយកផ្លាកចម្រើនមកធ្វើសកម្មភាពបន្ថែមទៀតប្រមូលកម្លាំងត្រៀមបំផុសមហាជនឲ្យងើបឡើងឧបត្ថម្ភគាំទ្រដល់រដ្ឋប្រហារទម្លាក់សម្តេចសីហនុ ។ ប៉ុន្តែផែនការបង្កើតគណបក្សនេះ ត្រូវបរាជ័យ ពីព្រោះសម្តេចសីហនុបានប្រកាសរំលាយសមាគមនិស្សិតចោល ហើយចាប់ខ្លួន ភោគ ឆាយ យកទៅឃុំឃាំងដោយចោទថា សមាគមនិស្សិតបានបំផុសឲ្យនិស្សិតបះបោរប្រឆាំងនឹងរដ្ឋាភិបាល ។ ទន្ទឹមនេះសម្តេចសីហនុ ក៏ផ្អាកលែងឲ្យសមាគមផ្សេងៗទៀតធ្វើសកម្មភាពទាំងអស់ ។

នៅឆ្នាំ១៩៦៨ សន្ទុះតស៊ូប្រឆាំងនឹងសម្តេចសីហនុ កាន់តែខ្លាំងក្លាថែមទៀត ។ រដ្ឋាភិបាលបានធ្វើការបង្ក្រាបចាប់ចងយ៉ាងខ្លាំងក្លា ។ នៅក្នុងការរាត្បាតនេះ គិញបានទៅព័ទ្ធឆែកឆេរទីស្នាក់ការសមាគមនិស្សិតធ្វើឲ្យបែកខ្ញែកគ្នាលែងធ្វើសកម្មភាពអ្វីកើតទៀត ។ ក្រោយនេះបន្តិចមក គិញបានចាប់ខ្លួន ម៉ៃ សាខន, ម៉ៅ រុន និង ងួន យាង យកទៅឃុំឃាំង ។ ឈុន សុខងួន និង ទួន សុខផល្លា បានរត់គេចខ្លួន ។

នៅដើមឆ្នាំ១៩៦៩ ឈុន សុខងួន បានផ្លាស់ទៅធ្វើការនៅក្រុងកំពង់សោម ។ ទួន សុខផល្លា នៅធ្វើការក្នុងក្រុងភ្នំពេញ ។ ក្នុងឆ្នាំនេះ ម៉ៃ សាខន, ម៉ៅ រុន, ងួន យាង បានរួចពីការឃុំឃាំងមកវិញ ។ ម៉ៃ សាខន និង ងួន យាង បន្តធ្វើការក្នុងភ្នំពេញតទៅទៀត ។ ម៉ៅ រុន បានវិលត្រឡប់ទៅបង្រៀននៅក្នុងខេត្តបាត់ដំបង ។ ក្រោយនេះបន្តិច ភោគ ឆាយ ក៏ត្រូវបានដោះលែងមកវិញ ។ បន្ទាប់ពីត្រូវដោះលែង ភោគ ឆាយ បានប្រាប់ ទួន សុខផល្លា ថា បញ្ហាបង្កើតបក្សនោះផ្អាកទុកសិនពីព្រោះសភាពការណ៍បានវិវត្តលឿនទៅមុខហើយ ការទម្លាក់សម្តេចសីហនុ នៅចាំតែត្រូវអនុវត្តប៉ុណ្ណោះ ។

មកដល់ខែកុម្ភៈ ឆ្នាំ១៩៧០ ឪពុកក្មេករបស់ ទួន សុខផល្លា ត្រូវបានចាត់តាំងឲ្យធ្វើជារដ្ឋលេខាធិការក្រសួងកសិកម្ម ។ ក្នុងឋានៈជាសមាជិករដ្ឋាភិបាល ឪពុករបស់ ទួន សុខផល្លា បានចូលរួមដោយផ្ទាល់ក្នុងការរៀបចំទម្លាក់សម្តេចសីហនុនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ រដ្ឋាភិបាលថ្មីមួយដែលមានអាមេរិកជាអ្នកគាំទ្រ ត្រូវបានបង្កើតឡើងដោយមាន លន់ ណុល ជាអ្នកដឹកនាំ ។ នៅក្នុងខែមេសា ឆ្នាំ១៩៧០ ទួន សុខផល្លា បានភ្ជាប់ខ្សែជាមួយបដិវត្តវិញតាមរយៈឈ្មោះ ស៊ាង ប៉ោសែ ។ ប៉ុន្តែជាដំបូង ទួន សុខផល្លា នៅមិនទាន់ធ្វើសកម្មភាពអ្វីដែលមានលក្ខណៈប្រឆាំងនឹងបដិវត្តឡើយ ដោយនៅពួនសម្ងំធ្វើឲ្យមានការទុកចិត្តសិន ។ ចុងឆ្នាំ១៩៧០ ភោគ ឆាយ និង ឈុន សុខងួន បានចេញទៅតំបន់រំដោះ ហើយនៅខែមករា ឆ្នាំ១៩៧១ ម៉ៃ សាខន ក៏បានចេញទៅតំបន់រំដោះទៀត ។

នៅក្នុងខែសីហា ឆ្នាំ១៩៧១ ទួន សុខផល្លា បានខិតខំបញ្ចុះបញ្ចូលប្រពន្ធគាត់ឲ្យចូលជាសេ.អ៊ី.អា ។ ហាក់ យូឡេង ដែលត្រូវជាបងថ្លៃរបស់ សុខផល្លា និង អ៊ុន តាំ ក៏បានចូលរួមក្នុងពិធីនេះដែរ ។ នៅឆ្នាំ១៩៧១នេះ ទួន សុខផល្លា ត្រូវបានក្រសួងសាធារណការ(រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ) ចាត់តាំងឲ្យចូលរួមនៅក្នុងគណៈកម្មការចំរុះតាក់តែងរដ្ឋធម្មនុញ្ញ ។

ប៉ុន្តែនៅឆ្នាំ១៩៧២-៧៣ នៅទីក្រុងភ្នំពេញមានផ្ទុះចលនាកូដកម្មជាទូទៅ ។ សិស្ស និស្សិត គ្រូ និង សាស្ត្រាចារ្យឈប់រៀននិងឈប់បង្រៀន ។ នៅតាមបងសាលាមានចងបដាពាក្យស្លោកព្រោងព្រាត ជេរប្រឆាំងនឹងរដ្ឋាភិបាល លន់ ណុល ។ ចលនានេះបានរីករាលដាលដល់ខេត្តមួយចំនួនទៀតដូចជាខេត្តកំពត, កំពង់ស្ពឺ, កំពង់ឆ្នាំង, បាត់ដំបង, កំពង់ចាមជាដើម ។ នៅចំពោះមុខសភាពការណ៍នេះ ទួន សុខផល្លា ក៏បានពិគ្រោះជាមួយ ម៉ៅ រុន និង នួន យឿន ហើយសម្រេចថា ជំរុញចលនានេះឲ្យខ្លាំងថែមទៀត ដោយធ្វើមិទ្ទីងជាចំហឲ្យមហាជនឡើងថ្កោលទោស លន់ ណុល ហើយទាមទារឲ្យចុះចេញពីតំណែង ។ ក្នុងពេលដែលមហាជនកំពុងតែឡើងនិយាយថ្កោលទោស លន់ ណុល ស្រាប់តែកងកម្លាំងទាហានស្លៀកពាក់ស៊ីវិលដែល លន់ ណុល ចាត់តាំងឲ្យមក ស្ទុះទៅកន្លែងធ្វើមិទ្ទីងបាញ់រះនិងគប់គ្រាប់បែកធ្វើឲ្យមានភាពច្របូកច្របល់បែកខ្ញែកគ្នាអស់ ។ ពេលនោះ ម៉ៅ រុន ត្រូវបានចាប់ខ្លួន ហើយគិញក៏បានទៅព័ទ្ធផ្ទះរកចាប់ ទួន សុខផល្លា និង នួន យឿន ដែរ ប៉ុន្តែចាប់ពុំបាន ។ ក្រោយពីព្រឹត្តិការណ៍នេះ ទួន សុខផល្លា និង នួន យឿន

ក៏ចេញទៅតំបន់រំដោះក្នុងខែមីនា ឆ្នាំ១៩៧៣ ។ ពេលទៅដល់តំបន់រំដោះក្រោម កោក ឆាយ ក៏បានទៅសួរសុខទុក្ខ ទូន សុខផល្លា នៅមន្ទីរតំបន់១៥ ប៉ុន្តែមិនបាននិយាយការងារអ្វីទេ ដោយនៅជុំជាមួយមហាជនទាំងអស់ដែលចេញពីក្រុងជាមួយគ្នា ។

ក្រោយមកទៀត ប្រពន្ធរបស់ ទូន សុខផល្លា បាននាំកូនចេញទៅតំបន់រំដោះ ។ នៅពេលទៅដល់តំបន់រំដោះដំបូង អង្គការបានចាត់តាំងឲ្យ ទូន សុខផល្លា និង ប្រពន្ធ នៅក្នុងមន្ទីរ ៦៧០ ។ ទូន សុខផល្លា និង ប្រពន្ធ រស់នៅកន្លែងដាច់ដោយឡែកពីគ្នា ។ ក្នុងរយៈកាលនេះ ទូន សុខផល្លា និង ប្រពន្ធ មិនទាន់មានធ្វើសកម្មភាពអ្វីប្រឆាំងបដិវត្តទេ ។ ទូន សុខផល្លា បានទទួលដំណឹងពីគ្រួសារនៅភ្នំពេញថាឪពុកក្មេកគាត់នៅតែធ្វើសកម្មភាពក្នុងគណបក្សប្រជាធិបតេយ្យដដែល ។ រយៈពេលរស់នៅក្នុងមន្ទីរ៦៧០នេះ ទូន សុខផល្លា បានជួប ឈុន សុខនួន និង ម៉ៅ សាខន ពីរ ឬបីដងដែរ ។ ឈុន សុខនួន និង ម៉ៅ សាខន បានផ្តាំ ទូន សុខផល្លា ថាឲ្យបំផុសទំនាស់នៅក្នុងកន្លែងរស់នៅដើម្បីធ្វើឲ្យមានភាពស្មុគស្មាញនៅក្នុងមន្ទីរនេះ ។

នៅចុងខែកុម្ភៈ ឆ្នាំ១៩៧៤ អង្គការចាត់តាំងឲ្យ ទូន សុខផល្លា ទៅរស់នៅក្នុងមន្ទីរក-៣០០ ។ នៅទីនោះ ទូន សុខផល្លា បានជួប នួន ឃឿន និង ព្រុំ សង្ការ ។ ពេលនោះ ទូន សុខផល្លា និង ប្រពន្ធ បានបង្កទំនាស់ធ្វើឲ្យបែកបាក់សាមគ្គីដោយធ្វើឲ្យមានជាបក្សពួក ។ ក្នុងសកម្មភាពទាំងអស់នេះ ទូន សុខផល្លា បានរួមជាមួយ នួន ឃឿន និង ព្រុំ សង្ការ ។ ចំណែកប្រពន្ធរបស់ ទូន សុខផល្លា ធ្វើការជាមួយនារីៗ មានឈ្មោះ រិន, ផង និង គុជ ។ ដល់ខែមិថុនា ឆ្នាំ១៩៧៤ ទូន សុខផល្លា បានជួបនិងស្គាល់ ភិន នៅក្នុងមន្ទីរក-៣០០នេះដែរ ។ ពេលនោះ ទូន សុខផល្លា និង ភិន មិនទាន់បានទាក់ទងស្និទ្ធស្នាលជាមួយគ្នានៅឡើយ ដោយ ភិន ចេញទៅធ្វើការនៅខាងក្រៅមួយរយៈ និង សម្រាកពេទ្យព្យាបាលជំងឺជាច្រើនខែផង ។ ទូន សុខផល្លា ចាំបានថា ក្នុងពេលនោះ ភិន បានឲ្យជួយរកអ្នកដែលអាចធ្វើការជាមួយគ្នាបានក្នុងក្រសួងសាធារណការក្រោយពេលឯករាជ្យ ។ ទូន សុខផល្លា បានលើកឈ្មោះ ឈុន សុខនួន, ម៉ៅ សាខន និង ភុក គី ប្រាប់ទៅ ភិន ។

ខែមីនា ឆ្នាំ១៩៧៥ អង្គការបានចាត់តាំងឲ្យ ទូន សុខផល្លា ទៅលត់ដំកសាងខ្លួននៅក្នុងសហករណ៍តំបន់១០៣(ព្រះវិហារ) ។ ទូន សុខផល្លា រស់នៅក្នុងសហករណ៍នេះបានប្រហែលជាមួយខែ ។ ខែមេសា ឆ្នាំ១៩៧៥ អង្គការហៅឲ្យ ទូន សុខផល្លា ត្រឡប់មកបម្រើការងារនៅភ្នំពេញវិញ ។ ខែកក្កដា ឆ្នាំ១៩៧៥ ទូន សុខផល្លា ត្រូវបានចាត់តាំងឲ្យមកបំពេញភារកិច្ចនៅក្រសួងសាធារណការ ។ នៅក្នុងមន្ទីរស-៨ នេះ ទូន សុខផល្លា បានជួប ម៉ៅ សាខន, ភុក គី និង ម៉ែន និថូ ។ ក្រោយពីបានជួបជុំគ្នាវិញហើយ ទូន សុខផល្លា បានរួមការងារគ្នាក្រោមការដឹកនាំរបស់ ភិន ដើម្បីធ្វើសកម្មភាពជាហូរហែប្រឆាំងនឹងបដិវត្តន៍ ។ សកម្មភាពរបស់ ទូន សុខផល្លា ក្នុងរយៈកាលចុងក្រោយនេះ សំខាន់គឺអប់រំ និងពង្រីងសមាសភាពប្រឆាំងបដិវត្តនៅក្នុងមន្ទីរស-៨ ដើម្បីត្រៀមកម្លាំងរួមក្នុងការដណ្តើមរដ្ឋអំណាចនៅកម្ពុជាក្នុងពេលធ្វើបុណ្យខួបបក្សដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ។ ប៉ុន្តែ សកម្មភាពទាំងនេះប្រព្រឹត្តទៅមិនបានសម្រេចជោគជ័យឡើយ ហើយ ទូន សុខផល្លា ក៏ត្រូវបានចាប់ខ្លួននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ ។

## ប្រវត្តិសកម្មភាពប្រពន្ធរបស់ ទូន សុខផល្លា ពាក់ព័ន្ធនឹងការចូលសេ.អ៊ី.អា

ទូន ចាន់ដារ៉ា ហៅ ភាន់ គឺជាប្រពន្ធរបស់ ទូន សុខផល្លា ។ អ្នកទាំងពីរត្រូវជាបងប្អូនជីដូនមួយនឹងគ្នា ហើយបានរៀបការជាមួយគ្នាតាំងពីឆ្នាំ១៩៦៤ មានកូនចំនួន៦នាក់ (ប្រុស៣នាក់ ស្រី៣នាក់) ។ ទូន ចាន់ដារ៉ា រៀនបានត្រឹមថ្នាក់ទី៤នៅវិទ្យាល័យយុគន្ធរ ។

ក្នុងរយៈកាលដំបូង ក្រោយពីបានរៀបការហើយ ទូន ចាន់ដារ៉ា មិនទាន់បានធ្វើអ្វីពាក់ព័ន្ធនឹងសេ.អ៊ី.អាទេ ។ ប៉ុន្តែ ទូន ចាន់ដារ៉ា ត្រូវបានប្តីអប់រំជាបណ្តើរៗក្នុងទិសឲ្យមានទស្សនៈនិងជំហរឯកភាពគ្នា ដើម្បីសម្រួលដល់សកម្មភាពសេ.អ៊ី.អា ។ លុះក្រោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយសារខ្សែសង្វាក់ការងារសេ.អ៊ី.អាមានការមមាញឹកខ្លាំង ទូន សុខផល្លា បានបញ្ចូលប្រពន្ធរបស់ខ្លួនជាសេ.អ៊ី.អា នៅខែសីហា ឆ្នាំ១៩៧១ ដើម្បីធ្វើជាជំនួយការក្នុងការធ្វើសកម្មភាពបន្តទៀត ។

ការបញ្ចូលនេះក៏មានការឯកភាពពីឪពុករបស់គាត់ដែរ ហើយពិធីនេះធ្វើឡើងនៅផ្ទះរបស់ឪពុកគាត់នៅក្បែរមេភ្លើង(ជួរមុនីវង្ស) អស់រយៈពេល១ថ្ងៃ១យប់ និង មានធ្វើពិធីជប់លៀងនៅវេលាយប់នោះទៀតផង។ អ៊ិន តាំ ក៏បានចូលរួមក្នុងឱកាសនោះផងដែរ ។

ទួន ចាន់ដារ៉ា បានធ្វើសកម្មភាពក្នុងចំណោមនារីនៅក្នុងក្រុមកាកបាទក្រហមខ្មែរ។ ភារកិច្ចរបស់ ទួន ចាន់ដារ៉ា គឺខិតខំក្តាប់និន្នាការនយោបាយរបស់នារីៗដែលគាត់ប្រាស្រ័យទាក់ទងជាមួយព្រមទាំងនិន្នាការនយោបាយរបស់ប្តីនារីៗទាំងនោះផង។ ខែកញ្ញា ឆ្នាំ១៩៧៣ ទួន ចាន់ដារ៉ា និង កូន បានចេញទៅតំបន់រំដោះ។ អង្គការបានចាត់ឲ្យ ទួន ចាន់ដារ៉ា នៅក្នុងមន្ទីរដាច់ដោយឡែកពី ទួន សុខផល្លា។ នៅក្នុងមន្ទីរ៦៧០របស់ភូមិភាគពិសេស ទួន ចាន់ដារ៉ា និង ប្តី មិនទាន់មានធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍នៅឡើយទេ។

នៅចុងខែកុម្ភៈ ឆ្នាំ១៩៧៤ អង្គការបានបញ្ជូន ទួន ចាន់ដារ៉ា និងប្តី ព្រមទាំងកូន ឲ្យទៅនៅមន្ទីរក-៣០០។ មកដល់មន្ទីរក-៣០០នេះទើបមានការចាប់ផ្តើមធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍។ ទិសសំខាន់របស់របស់ ទួន ចាន់ដារ៉ា គឺបង្កឲ្យមានទំនាស់បែកបាក់ស្អុកស្អាញក្នុងចំណោមនារីនៅក្នុងមន្ទីរនេះ។ ធាតុពិតនៃទំនាស់នេះ គឺជាទំនាស់បដិបក្ខរវាងបដិវត្តន៍និងការប្រឆាំងបដិវត្ត។ នៅក្នុងមន្ទីរក-៣០០នេះ មាននារីចំនួន៥នាក់ ក្នុងនោះមាន៤នាក់មានធាតុប្រឆាំងបដិវត្ត គឺ ភាន់(ប្រពន្ធរបស់ ទួន សុខផល្លា), រិន(ប្រពន្ធរបស់ នួន ឃឿន), ផង់(ប្រពន្ធរបស់ ព្រុំ សង្ហារ) និង គុជ(ប្រពន្ធរបស់ គី ណាច) ។

ក្រោយរំដោះទូទាំងប្រទេសហើយ មកដល់ខែមករា ឆ្នាំ១៩៧៦ ភិន (តូច ភឿន ជារដ្ឋមន្ត្រីក្រសួងសាធារណការនៃរបបកម្ពុជាប្រជាធិបតេយ្យ) បានស្នើសុំ ទួន ចាន់ដារ៉ា ឲ្យមករស់នៅក្នុងមន្ទីរស-៨វិញ ពេលមុននេះ ទួន ចាន់ដារ៉ា បានរស់នៅក្នុងតំបន់១០៣ ក្នុងខេត្តព្រះវិហារ តាំងតែពីខែមិថុនា ឆ្នាំ១៩៧៥។ មកដល់មន្ទីរស-៨ ទួន ចាន់ដារ៉ា ត្រូវបាន ភិន ឲ្យទៅនៅក្នុងមន្ទីរនារីនិងកុមាររបស់មន្ទីរស-៨ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ទូច (ប្រពន្ធរបស់ ភិន) ហើយ ទូច ក៏ជាអ្នកបំផុសនិងជុំរុញចលនាប្រឆាំងបដិវត្តនៅក្នុងមន្ទីរនេះដែរ។ នារីដែលបានធ្វើសកម្មភាពជាមួយ ទូច រួមមាន ភាន់ (ទួន ចាន់ដារ៉ា), ពុំ (ប្រពន្ធ ម៉ែន និថូ), ផល (ប្រពន្ធ ភុក គី), ខំ (ប្រពន្ធ ម៉ៃ សាខន) និង ញិប (ប្រពន្ធ ភឿន) ។

ក្នុងការត្រៀមរៀបចំប្តូររបបគ្រប់គ្រងពេលមានរដ្ឋប្រហារ ភិន ក៏បានណែនាំ ទូច ផ្ទាល់ឲ្យយកនារីទាំង៥នាក់ គឺ ភាន់, ខំ, ពុំ, ញិប និង ផល ធ្វើជាកម្លាំងស្នូលសម្រាប់គ្រប់គ្រងមហាជននៅមន្ទីរនេះ។ ក្នុងការអូសទាញមហាជន ទួន ចាន់ដារ៉ា បានជំរុញគ្រួសារកម្មករដែលនៅជាមួយខ្លួនឲ្យទាក់ទាញហៅប្តីៗមកចូលរួមជាមួយ។ គ្រួសារកម្មករដែល ទួន ចាន់ដារ៉ា អប់រំបានមានចំនួន៣នាក់ គឺមានឈ្មោះ ហន, ង៉ោ និង ហាន។ នៅក្នុងសកម្មភាពទាំងនេះ ទួន ចាន់ដារ៉ា បានខិតខំជាខ្លាំងរហូតទាល់តែមានមហាជនខ្វះចាប់អារម្មណ៍ ហើយនិយាយថា គាត់បានធ្វើសកម្មភាពបម្រើសន្តិសម្ព័ន្ធជាដើម។

នៅខែតុលា ឆ្នាំ១៩៧៦ មានមហាជនទិតៀនគាត់ខ្លាំងអំពីសកម្មភាពឃោសនានេះ។ ដោយមានការព្រួយបារម្ភខ្លាចបែកការណ៍ពីសកម្មភាពក្បត់ ទួន ចាន់ដារ៉ា បានលេបថ្នាំសម្លាប់ខ្លួននៅថ្ងៃទី១៦ ខែតុលា ឆ្នាំដដែល។ ប៉ុន្តែ ទូច បានដឹងទាន់ពេលវេលា ក៏យក ទួន ចាន់ដារ៉ា ទៅព្យាបាលនៅមន្ទីរពេទ្យព-១៧។ បន្ទាប់ពីការព្យាបាលហើយ ភិន ក៏យក ទួន ចាន់ដារ៉ា ឲ្យមកសម្រាកនៅមន្ទីរស-៨វិញ រហូតដល់ ទួន សុខផល្លា ជាប្តីត្រូវបានចាប់ខ្លួន។ ក្រោយមក ទួន ចាន់ដារ៉ា ក៏ត្រូវចាប់ខ្លួនដែរ គឺនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៧។

ចម្លើយសារភាពរបស់ ទួន សុខផល្លា បានបញ្ជាក់ចុងក្រោយអំពីសកម្មភាពរបស់ប្រពន្ធគាត់ថា "ក្រៅពីសកម្មភាពក្បត់ជាគោលៗរបស់ប្រពន្ធខ្ញុំនេះ គាត់នៅបានរួមសកម្មភាពបន្ទាប់បន្សំខ្លះទៀតនៅមន្ទីរនារីនេះ ដូចជាការពង្រីកទំនាស់រវាង បងទូច និង បងនន់។ មូលហេតុដើមនៃទំនាស់នេះ គឺបញ្ហាប្រណែនក្នុងនាទីតំណែង។ ប៉ុន្តែដោយសារការចាក់រុកថែម ទំនាស់នេះក៏ក្លាយជាការបែងចែកបក្សពួកធ្វើឲ្យមានការមើលមុខគ្នាមិនត្រង់"។

**(នៅមានត)**

**ឌួង សុភារិទ្ធ**

# ទីតាំងខាលពិឃាតខេត្តពោធិសាត់

**(តចប់)**

***ទីតាំងសម្លាប់ដូនអាម***

***លេខកូដភូមិសាស្ត្រៈ១៥០១១១***

***ចំណុចខ្សែស្របៈ (N) ១២o ៣៥' ៤០"***

***រយៈបណ្តោយៈ (E) ១០៣o ៤៦' ៣៦"***

ទីតាំងសម្លាប់មួយឈ្មោះថា ដូនអាម ស្ថិតនៅភូមិដូនអាម ឃុំបាក់នឹម ស្រុកបាកាន ខេត្តពោធិសាត់ បច្ចុប្បន្នហៅភូមិត្រពាំងជង ឃុំត្រពាំងជង ស្រុកបាកាន ខេត្តពោធិសាត់ ។ ទីតាំងនេះគឺជាលានបោកស្រូវរួមមួយកន្លែងប្រចាំឃុំត្រពាំងជងហើយក៏ជាកន្លែងប្រជុំរួមដែរ ។ ស្រះទឹកមួយកន្លែងត្រូវខ្មែរក្រហមយកធ្វើជាកន្លែងកប់សាកសពរួមជាមួយនឹងលូអណ្តូងទឹកមួយកន្លែងទៀតដែលមានជម្រៅ១០ម៉ែត្រ ក៏ត្រូវយកធ្វើជាកន្លែងដាក់សាកសពជនរងគ្រោះក្នុងជំនាន់ខ្មែរក្រហមដែរ ។

ម្ចាស់អណ្តូងឈ្មោះ អ៊ួច ហ៊ាង បានរៀបរាប់ថា អណ្តូងទឹករបស់គាត់ពេញទៅដោយសាកសព ខាងលើមាត់អណ្តូងមានគ្របចំបើង ។ ក្លិនស្អុយបានជះឡើងចេញតាមចំបើងធ្វើឲ្យគាត់ស្ទើរទ្រាំមិនបាន ។ នៅឆ្នាំ១៩៨០ អណ្តូងទឹករបស់ អ៊ួច ហ៊ាង ត្រូវបានគាស់ ។ លោក ស លន បានអធិប្បាយពីមូលហេតុដំបូងនៃការសម្លាប់មនុស្សនៅក្នុងស្រះទឹកនិងក្នុងអណ្តូងទឹកថា គាត់បានឃើញមានការប្រជុំរួមមួយប្រចាំសហករណ៍ត្រពាំងជង ។ កិច្ចប្រជុំបានលើកឡើងពីបញ្ហាផ្សេងៗដែលទាក់ទងនឹងរឿងសេ.អ៊ី.អារបស់ខ្មាំងនិងយួនឈ្លានពាន ។ ក្រោយកិច្ចប្រជុំត្រូវបានបញ្ចប់ អ្នកដែលចូលរួមប្រជុំទាំងអស់ត្រូវបានទទួលបញ្ជាមួយមិនឲ្យរត់ចេញដាច់ខាត ហើយបន្ទាប់មកក៏ត្រូវខ្មែរក្រហមចាប់ចងយកទៅសម្លាប់ចោលទាំងអស់ ។ ស លន បានបញ្ជាក់ទៀតថា រយៈពេលពីរថ្ងៃក្រោយមក គាត់បានទៅមើលក្នុងស្រះទឹក និងក្នុងអណ្តូងទឹក ឃើញមានស្លាកស្នាមខ្លះៗដែលបន្សល់ទុកក្រោយពេលសម្លាប់រួច ។ ស លន បានសន្និដ្ឋានថា អ្នកដែលមកប្រជុំទាំងអស់ពិតជាត្រូវស្លាប់ក្នុងស្រះទឹកនិងអណ្តូងទឹកនេះប្រាកដមែន ។ ចំពោះសាកសពដែលស្លាប់នៅក្នុងទីតាំងសម្លាប់ ដូនអាមនេះ លោក ស លន សន្និដ្ឋានថា នៅក្នុងស្រះទឹកមានសាកសពរបស់ជនរងគ្រោះចំនួនប្រហែលជាង៩០០នាក់ ។ អ្នកមីង អ៊ួច ហ៊ាង ក៏បាននិយាយដែរថា ក្នុងលូទឹករបស់គាត់គឺមានសាកសពជនរងគ្រោះចំនួនពី៧០ទៅ១០០នាក់ ។

***ទីតាំងសម្លាប់កូនត្នោតនិងភូមិរំលេច***

***លេខកូដភូមិសាស្ត្រៈ១៥០១០១-១៥០១០២***

***ចំណុចខ្សែស្របៈ (N) ១២o ៣៦' ០០"៣៨-១២o ៣៥'៥៥"៨២***

***រយៈបណ្តោយៈ (E) ១០៣o ៤០' ៥៥"៧៦-១០៣o ៤១' ៣៧"៨៨***

ស្រះទឹកចំនួនបីកន្លែងដែលស្ថិតនៅក្នុងភូមិកូនត្នោត ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ ត្រូវបានខ្មែរក្រហមប្រើប្រាស់ជាកន្លែងដាក់សាកសពជនរងគ្រោះបន្ទាប់ពីបានសម្លាប់រួច ។ លោក ដួង សួរ អាយុ៥៨ឆ្នាំ បច្ចុប្បន្នជាមេឃុំរំលេច បាននិយាយប្រាប់ថាក្នុងស្រះទឹកចំនួនពាកន្លែងនេះមានសាកសពជនរងគ្រោះសរុបចំនួនប្រហែល៤០០នាក់ ។ លោកដួង សួរ បានរៀបរាប់ថា ជនរងគ្រោះដែលត្រូវបានយកមកសម្លាប់នៅទីនេះ គឺជាប្រជាជនចំរុះ មានក្មេងចាស់ប្រុសស្រី ។ វិធីសម្លាប់របស់ខ្មែរក្រហមនាពេលនោះគឺបាញ់រះទៅលើជនរងគ្រោះទាំងនោះដែលត្រូវបានបញ្ឈរឲ្យឈរនៅនឹងមួយកន្លែង ។ ក្រោយពីការសម្លាប់ សាកសពជនរងគ្រោះមិនទាន់ត្រូវបានប្រមូលយកទៅកប់ភ្លាមៗទេ គឺបានត្រឹមតែប្រមូលយកទៅដាក់នៅក្រោមនិងក្បែរដើមឈើទាលមួយក្បែរផ្លូវថ្នល់ដែលចេញពីភូមិរំលេចឆ្ពោះទៅកាន់ឃុំតាលោ ស្រុកបាកាន ។ ពេលក្រោយមក ទើប

មានការប្រមូលម្តងទៀតយកទៅទម្លាក់ចោលនៅក្នុងស្រះទឹកទាំងបីកន្លែងនោះ ។ មកដល់បច្ចុប្បន្ន ស្រះទាំងបីកន្លែងនោះនៅមានស្លាកស្នាមជាស្រះទឹកដដែល ប៉ុន្តែគ្មានលក្ខណៈជ្រៅដូចស្រះទឹកកាលពីដើមឡើយ ។

**វត្តចន្ទរង្សីរស្មីរំលេច**

**លេខកូដភូមិសាស្ត្រៈ១៥០១០៣**

**ចំណុចខ្សែស្របៈ (N) ១២º ៣៦' ០១:៤៧"**

**រយៈបណ្តោយៈ (E) ១០៣º ៤១' ៤៨:១៧"**

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ គណៈកម្មការវត្តចន្ទរង្សីរស្មីរំលេចហៅវត្តរំលេច បានសហការជាមួយអាជ្ញាធរមូលដ្ឋានសាងសង់បូជនីយដ្ឋានមួយ ដើម្បីតម្កល់ទុកនូវអដ្ឋិធាតុរបស់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ វត្តចន្ទរង្សីរស្មីរំលេច ស្ថិតនៅក្នុងភូមិរំលេច ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ មានចម្ងាយ១៥គីឡូម៉ែត្រ ពីសាលាស្រុកបាកាន ។ អដ្ឋិធាតុដែលបានយកមកតម្កល់ទុកនៅវត្តរំលេច គឺបានប្រមែប្រមូលមកពីទីតាំងសម្លាប់កូនត្នោតខាងលិចសាលារៀនភូមិរំលេច និង វាលគារាំងបាល់ដែលស្ថិតនៅក្នុងភូមិរំលេច និងភូមិប្រឡាយរំដេង ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ ។

ព្រះតេជគុណ ថាច់ សុខ បានជូនក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាទៅមើលបូជនីយដ្ឋាន(ស្តូប) បាក់បែកមួយដែលសង់អំពីឈើ ។ ព្រះតេជគុណបានមានពុទ្ធដីកាថា ឆ្អឹងទាំងប៉ុន្មានត្រូវបានបំផ្លាញស្ទើរអស់ដោយសត្វពាហនៈស៊ី ។

**ទីតាំងសម្លាប់វាលគារាំងបាល់**

**លេខកូដភូមិសាស្ត្រៈ១៥០១០៤**

**ចំណុចខ្សែស្របៈ (N) ១២º ៣៦' ២៣:១៦"**

**រយៈបណ្តោយៈ (E) ១០៣º ៤២' ០៥:៣៨"**

វាលគារាំងបាល់ទាត់មួយដែលស្ថិតក្នុងភូមិប្រឡាយរំដេង ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ បានត្រូវជ្រើសរើសយកធ្វើជាទីតាំងកប់សាកសពជនរបស់រងគ្រោះកាលពីរបបខ្មែរក្រហម ។

លោក ជួង សួរ បាននិយាយថា មានសាកសពរបស់ជនរងគ្រោះកប់នៅពាសពេញគារាំងបាល់ទាត់នេះ ។ បច្ចុប្បន្នគារាំងបាល់ទាត់នេះជាដីទំនេរសុទ្ធសាធ មិនមែនជាគារាំងបាល់ទាត់ដូចមុនទៀតទេ ។ ជួង សួរ បានបន្ថែមថា មានចំនួនរណ្តៅចាប់ពី១០០ទៅ១៥០រណ្តៅនៅលើដីគារាំងបាល់ទាត់នេះ ។ ប្រភេទជនរងគ្រោះដែលយកមកសម្លាប់ គឺជាប្រភេទអ្នកធ្វើពុតជាឈឺ អ្នកខ្ជិលប្រអូសនឹងការងារ អ្នកជំងឺស្លាប់នៅក្នុងមន្ទីរពេទ្យ និងមួយចំនួនទៀតជាប្រភេទមនុស្សដែលត្រូវបានចំរាញ់យកមកពីសហករណ៍នានាក្នុងឃុំរំលេច ។ ជនរងគ្រោះដែលត្រូវបានសម្លាប់នៅលើទីតាំងវាលគារាំងបាល់នេះ មានចំនួនប្រហែល ៥០០នាក់ ។

**៥) ស្រុកពោធិសាត់**

**ទីតាំងសម្លាប់និងមន្ទីរសន្តិសុខបន្ទាយអាតារី**

**លេខកូដភូមិសាស្ត្រៈ១៥០៥០១**

**ចំណុចខ្សែស្របៈ (N) ១២º ៣២' ២០:៣៥"**

**រយៈបណ្តោយៈ (E) ១០៣º ៥៥' ២២:៣៦"**

បន្ទាយអាតារីគឺជាបន្ទាយទាហានរបស់ខេត្តពោធិសាត់ បច្ចុប្បន្ននេះស្ថិតនៅក្នុងភូមិព្រៃញី ឃុំព្រៃញី ស្រុកពោធិសាត់ ខេត្តពោធិសាត់ ។ មន្ទីរសន្តិសុខបន្ទាយអាតារី បានសាងសង់ឡើងដោយខ្មែរក្រហមនៅឆ្នាំ១៩៧៦ ហើយបន្តការគ្រប់គ្រងរបស់ខ្លួនរហូតដល់ចុងឆ្នាំ១៩៧៨ ។ នៅជុំវិញបរិវេណបន្ទាយអាតារី មានស្រះទឹក១ អណ្តូងទឹក៥ និងអាងទឹក១ ។ ជនរងគ្រោះស្ទើរតែទាំងអស់ត្រូវបាននាំយកទៅសម្លាប់នៅក្នុងស្រះទឹក អណ្តូង និង អាងទឹកទាំងនោះ ។ ការសម្លាប់នៅទីតាំងបន្ទាយអាតារី បានចាប់ផ្តើមធ្វើឡើងតាំងពីឆ្នាំ១៩៧៦ ។ នៅចុងឆ្នាំ ១៩៧៨ ការសម្លាប់មនុស្សបានកើនឡើងទ្វេដងថែមទៀត ។ ផ្ទះរបស់អតីតទាហាន សម័យបារាំងត្រូវបានខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំង ។ ជនរងគ្រោះដែលបានមកជាប់ឃុំនៅមន្ទីរសន្តិសុខបន្ទាយអាតារីដំបូងបង្អស់ គឺប្រជាជន១៧មេសា ហើយបន្ទាប់ៗមកទៀត គឺអ្នកមូលដ្ឋាន មន្ត្រីរាជការសម័យសាធារណរដ្ឋខ្មែរ ទាហានអ្នកលួចនេះលួចនោះ និង ចុងក្រោយបំផុតគឺកម្មាភិបាលខ្មែរក្រហមខ្លួនឯងដែលត្រូវបានចោទថាក្បត់ ។ អ្នកទោសទាំងអស់មិនបានរួចខ្លួនពីសេចក្តីស្លាប់ឡើយ ។

តាមការសរុបរបស់សាក្សីចំនួនបីនាក់ គឺលោក យុន



អណ្តូងសម្លាប់ជនរងគ្រោះនៅមន្ទីរសន្តិសុខបន្ទាយអាទាលរី

វឿន វរសេនីយ៍ទោធ្វើការនៅក្នុងបន្ទាយអាទារីបច្ចុប្បន្ន លោក អ៊ុក សាវុធ អនុប្រធានការិយាល័យវប្បធម៌ខេត្ត និងលោក អ៊ុំ សាឡាត់ ប្រធានវប្បធម៌ខេត្ត បានអះអាងថា សាកសពជនរងគ្រោះមានចំនួនជាង៧០០នាក់ ។ នៅក្រោយឆ្នាំ១៩៧៩ អាថ៌កំបាំងនៅបន្ទាយអាទារី ត្រូវបានទម្លាយឲ្យឃើញយ៉ាងច្បាស់ថា ឆ្អឹងខ្មោចជាច្រើនស្ថិតនៅរាយប៉ាយពាសពេញមន្ទីរ ។ ប្រជាជនជាច្រើនរយនាក់បាននាំគ្នាទៅគាស់កកាយរកមាសនិងខ្លះទៀតបានស្រង់យកសពដែលជាសាច់ញាតិរបស់ខ្លួនទៅធ្វើបុណ្យតាមប្រពៃណី ដោយសំអាងទៅលើសម្លៀកបំពាក់ដែលនៅជាប់នឹងខ្លួនសាកសព ។ បច្ចុប្បន្ន បន្ទាយអាទារីបានបន្សល់ទុកនូវអណ្តូងទឹកមួយដែលនៅតែមានសេសសល់ឆ្អឹងខ្លះៗនៅបាតអណ្តូងនៅឡើយ និង ទម្រង់អគារចាស់មួយខ្នងដែលជាអតីតមន្ទីរឃុំឃាំង ហើយដែលបច្ចុប្បន្នត្រូវបានកែឆ្នៃសាជាថ្មីឡើងវិញ ។

## ៦) ស្រុកក្រគរ

ស្រុកក្រគរស្ថិតនៅចម្ងាយពីសាលាខេត្តពោធិសាត់ចម្ងាយ ៣២គីឡូម៉ែត្រ និងមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តកំពង់ធំ និងខេត្តសៀមរាប ខាងត្បូងជាប់នឹងខេត្តកំពង់ស្ពឺ ខាងលិចជាប់នឹងស្រុកសំពៅមាស ខេត្តពោធិសាត់ និងខាងកើតជាប់នឹងស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ។ ស្រុកក្រគរ មាន១៣ឃុំ និង ៩៨ភូមិ ។ ស្រុកក្រគរ មានទីតាំងប្រល័យពូជសាសន៍ចំនួន៣កន្លែង ។

**មន្ទីរសន្តិសុខនិងកន្លែងសម្លាប់ទួលលៀប**

**លេខកូដភូមិសាស្ត្រៈ ១៥០៣០១,២**



**ចំណុចខ្សែស្របៈ (N) ១២០ ៣២' ២៥:៨៦"**

**រយៈបណ្តោយៈ (E) ១០៤០ ០១' ៥៧:៥៨"**

ទួលលៀប ជាឈ្មោះភូមិមួយស្ថិតក្នុងឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិសាត់ ។ ទីតាំងនេះខ្មែរក្រហមបានយកធ្វើជាមន្ទីរសន្តិសុខនិងកន្លែងសម្លាប់មនុស្ស ហើយបច្ចុប្បន្ននេះត្រូវបានហៅថា មន្ទីរសន្តិសុខទួលលៀប ។ មន្ទីរសន្តិសុខទួលលៀបមានចម្ងាយ១៧គីឡូម៉ែត្រពីសាលាស្រុកក្រគរ ។ រហូតមកដល់បច្ចុប្បន្ន អតីតមន្ទីរសន្តិសុខ និង កន្លែងសម្លាប់ទួលលៀប គ្មានបានបន្សល់ទុកនូវអ្វីដែលជាភ័ស្តុតាងឡើយ ។ មន្ទីរសន្តិសុខទួលលៀបត្រូវបានកសាងឡើងតាំងពីឆ្នាំ១៩៧៦ ហើយបន្តរហូតដល់ចុងឆ្នាំ១៩៧៨ ។ ទីតាំងសម្លាប់ទួលលៀបស្ថិតនៅចម្ងាយប្រមាណតែ១០០ម៉ែត្រពីមន្ទីរសន្តិសុខប៉ុណ្ណោះ ។

លោក ញ៉ែម ឌុល អតីតអ្នកទោសនៅមន្ទីរសន្តិសុខទួលលៀប បច្ចុប្បន្នរស់នៅភូមិជ្រលុង ឃុំអន្លង់ត្នោត ស្រុកក្រគរ បាននិយាយប្រាប់ថា ព្រៃទួលលៀបមានទំហំដីប្រមាណទទឹង២ហិកតានិងបណ្តោយ៣ហិកតា ។ ញ៉ែម ឌុល គឺជាអ្នកកប់ខ្មោចក្នុងសម័យខ្មែរក្រហម ។ គាត់ទទួលការងារជាអ្នកកប់ខ្មោចអស់រយៈពេលជាង២ខែ ហើយក៏ជាអ្នកដែលទទួលការងារនេះក្រោយគេបង្អស់ដែរ ។ ញ៉ែម ឌុល បានបន្តថា នៅលើទីតាំងទួលលៀប មានរណ្តៅចំនួនពី៤០០ទៅ៥០០រណ្តៅ ។ ក្នុង១រណ្តៅអាចកប់សាកសពរបស់ជនរងគ្រោះបានចាប់ពីម្នាក់រហូតដល់៧នាក់ ។ អ្នកទោសទាំងអស់ដែលបានស្លាប់នៅក្នុងបរិវេណទីតាំងសម្លាប់ទួលលៀបមានចំនួនប្រហែល៤០០០នាក់ ។ ញ៉ែម ឌុល បានបន្តថា សាកសពរបស់ជនរងគ្រោះទាំងនោះខ្លះយកមកពីមន្ទីរសន្តិសុខទួលលៀប និងខ្លះទៀតយកមកពីកន្លែងផ្សេងៗដែលមិនបានឆ្លងកាត់មន្ទីរសន្តិសុខ ។ ប្រភេទជនរងគ្រោះដែលត្រូវបានសម្លាប់មានលាយចម្រុះគ្នា ទាំងប្រជាជន១៧មេសា ប្រជាជនមូលដ្ឋាន មន្ត្រីរាជការ ទាហានសម័យសាធារណរដ្ឋខ្មែរ និងកម្មាភិបាលខ្មែរក្រហមដែលបានប្រព្រឹត្តខុសនឹងវិន័យរបស់អង្គការ ។ ញ៉ែម ឌុល បានបន្តថា គាត់ឃើញមានការដឹកអ្នកទោសមកកាន់ទីតាំងសម្លាប់ទួលលៀបជាច្រើននាក់ ហើយក្រោយមកអ្នកទាំងនោះក៏ត្រូវបានសម្លាប់ចោលអស់គ្មានសល់ម្នាក់ឡើយ ។ ការដឹកមនុស្សចូលមកកាន់ទីតាំងនេះប្រព្រឹត្តទៅតាមតែតម្រូវការនៃការសម្លាប់ ។

**មន្ទីរសន្តិសុខនិងកន្លែងសម្លាប់តាវិត**

**លេខកូតភូមិសាស្ត្រៈ១៥០៣០៣,៤**

**ចំណុចខ្សែស្របៈ (N) ១២០ ៣១' ៤៧:២៤"**

**រយៈបណ្តោយៈ (E) ១០៤០ ០៥' ០០:៤៣"**

តាវិត ជាឈ្មោះរបស់មន្ទីរសន្តិសុខ និងជាកន្លែងសម្លាប់មួយកន្លែងស្ថិតក្នុងភូមិបឹងកន្ទួត ឃុំបឹងកន្ទួត ស្រុកក្រគរ ខេត្តពោធិសាត់ និងមានចម្ងាយ១៥គីឡូម៉ែត្រពីសាលាស្រុកក្រគរ ។ ប្រភេទជនរងគ្រោះដែលបានមកជាប់នៅក្នុងមន្ទីរសន្តិសុខនេះគឺត្រូវបានជ្រើសរើសយកមកពីគ្រប់សហករណ៍ទាំងអស់នៅទូទាំងស្រុក ប្រជាជនមូលដ្ឋាន ប្រជាជន១៧មេសា អាចារ្យវត្ត

និងអ្នកមានត្រកូលអភិជន ចិន យួន និង ចាម ។ ការសម្លាប់ច្រើនប្រព្រឹត្តទៅនៅពេលយប់ព្រោះបង្ការមិនឲ្យប្រជាជនដែលធ្លាប់ធ្វើការក្បែរនោះដឹងថា មានការសម្លាប់មនុស្សកើតឡើង ។

មន្ទីរគារិត មិនមានបន្សល់អ្វីឡើយរហូតដល់បច្ចុប្បន្ននេះ ។ បរិវេណដីមន្ទីរគារិត មិនត្រូវបានប្រជាជនកែប្រែឲ្យទៅជាដីសម្រាប់បង្កបង្កើនផល ឬដាំដំណាំអ្វីផ្សេងៗឡើយ ។ ញ៉ែម ឌុល បាននិយាយថា មានរណ្តៅប្រហែលពី៥០ទៅ៦០រណ្តៅស្ថិតនៅជុំវិញមន្ទីរសន្តិសុខគារិតនេះ ។ ចំនួនជនរងគ្រោះដែលបានស្លាប់គឺមានពី១០០ទៅ១៥០នាក់ ។

***មន្ទីរសន្តិសុខនិងទីតាំងសម្លាប់អណ្តូងទឹកតាប៉ក់***

***លេខកូដភូមិសាស្ត្រៈ១៥០៣០៥,៦***

***ចំណុចខ្សែស្របៈ (N) ១២ ៣១' ៤៦:០៩"***

***រយៈបណ្តោយៈ (E) ១០៤ ១២' ៤៤:៣៦"***

អណ្តូងតាប៉ក់ ស្ថិតនៅក្នុងភូមិសំរោង ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិសាត់ និងមានចម្ងាយជាងមួយគីឡូម៉ែត្រពីសាលាស្រុក ។ អតីតមន្ទីរសន្តិសុខរបស់ខ្មែរក្រហម បច្ចុប្បន្នជាមន្ទីរពេទ្យស្រុកក្រគរ មានទីតាំងស្ថិតនៅក្បែរអណ្តូងតាប៉ក់ចម្ងាយប្រហែលជា២០០ម៉ែត្រ ។ មានជនរងគ្រោះរាប់រយនាក់ដែលត្រូវជាប់ឃុំឃាំងនៅមន្ទីរនេះ ។ ជនរងគ្រោះទាំងប៉ុន្មានត្រូវបាននាំយកទៅសម្លាប់នៅក្នុងអណ្តូងទឹកមួយដែលជាកម្មសិទ្ធិរបស់តាប៉ក់កាលពីជំនាន់មុនខ្មែរក្រហមកាន់កាប់ ។ អណ្តូងទឹកតាប៉ក់ចំនួនពីរកន្លែងត្រូវបានយកធ្វើជាកន្លែងដាក់សាកសពរបស់ជនរងគ្រោះ ។ អណ្តូងទឹកនីមួយៗមានទំហំមុខកាត់ជាង៣ម៉ែត្រ និងមានជម្រៅ៦ម៉ែត្រ ។ លោក អ៊ិន សារី ប្រធានការិយាល័យវប្បធម៌ស្រុកក្រគរ បានរៀបរាប់ពីការសម្លាប់ជនរងគ្រោះនៅអណ្តូងតាប៉ក់ថា គាត់បានឃើញការសម្លាប់ផ្ទាល់ភ្នែក ដោយហេតុថា គាត់មើលពីលើដើមត្នោតដែលស្ថិតនៅប្រហែលជា៣០០ម៉ែត្រពីទីនោះ ។ លោក អ៊ិន សារី បានបន្តទៀតថា ពេលដែលខ្មែរក្រហមនាំយកជនរងគ្រោះទៅសម្លាប់គឺធ្វើឡើងចាប់ពីម៉ោង១០:០០យប់ទៅ ។ ចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់នៅក្នុងអណ្តូងតាប៉ក់មានចំនួនពី១០០នាក់ទៅ១៥០នាក់ ។

***សេចក្តីសន្និដ្ឋាន***

ប្រជាជន១៧មេសា ប្រជាជនមូលដ្ឋាន និង ទាហានជាច្រើននាក់ ត្រូវបានសម្លាប់តែក្នុងរយៈពេលជាង៣ឆ្នាំនៃការកាន់អំណាចរបស់ខ្មែរក្រហម ។ ការសម្លាប់ជនរងគ្រោះនៅក្នុងទូទាំងខេត្តពោធិសាត់ បានប្រព្រឹត្តទៅតាមរូបភាពផ្សេងៗ ដូចជាបង្អត់អាហារ, បញ្ជាឲ្យធ្វើការដោយគ្មានពេលសម្រាក, បង្ខំឲ្យធ្វើការច្រើន ប៉ុន្តែទទួលរបបអាហារតិច និងដើរទុក្ខទោសដល់អ្នកដែលមិនគោរពតាមបទបញ្ជារបស់អង្គការ និងអ្នកចូលចិត្តលួចនេះលួចនោះដើម្បីចម្អែតក្រពះ ។ ចំពោះប្រជាជន១៧មេសា ការសម្លាប់មិនត្រូវបានទុកពន្យារពេលយូរឡើយពីព្រោះខ្មែរក្រហមយល់ថា "ជាដៃជើងរបស់ចក្រពត្តិ" ។ ការធ្វើនយោបាយតាមគំរូស្តាលីន និងការកសាងសង្គមនិយមក្រហមឆ្អិនឆ្អៅរបស់សាឡុត ស បណ្តាលឲ្យមានការកាប់សម្លាប់ក្រោមលេសមិនទុកចិត្តគ្នា(ថ្នាក់លើមិនទុកចិត្តថ្នាក់ក្រោម) ។ ការនេះធ្វើឲ្យប្រជាជនខ្មែរគ្រប់រូបក្លាចញញើតយ៉ាងក្រៃលែងនិងរិតតែធ្វើឲ្យមានការចងចាំអស់មួយជីវិតថែមទៀតនូវរាល់ទង្វើដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត ។ វិញ្ញាណក្ខន្ធនៃជនរងគ្រោះដែលបានស្លាប់ទៅក្នុងរបបកម្ពុជាប្រជាធិប-តេយ្យទាំងប៉ុន្មានពិតជានៅវិលវល់មិនអស់ចិត្តចំពោះការស្លាប់របស់ខ្លួនឡើយពីព្រោះវាជារឿងមួយដែលអយុត្តិធម៌បំផុត ។ មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យជាច្រើនរូបនៅតែបន្តរស់នៅយ៉ាងសែនសុខទាំងនៅក្នុងប្រទេសកម្ពុជានិងក្រៅប្រទេសហាក់ដូចជាធ្វើមិនដឹងមិនឮចំពោះទង្វើរបស់ខ្លួនទាល់តែសោះ ។ តើបន្ទុកនៃការទទួលខុសត្រូវនឹងធ្លាក់ទៅលើនរណាជាអ្នកដោះស្រាយ? ។ តុលាការមួយដែលរំពឹងថាជាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមយ៉ាងត្រឹមត្រូវយុត្តិធម៌ ហើយដែលបម្រុងនឹងកើតមាននាពេលខាងមុខនេះ បានក្លាយជាជំនឿទុកចិត្តទាំងស្រុងពីសំណាក់ប្រជារាស្ត្រគ្រប់រូបទូទាំងប្រទេសកម្ពុជា ហើយក៏សង្ឃឹមថា វិញ្ញាណក្ខន្ធរបស់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតអស់រយៈពេលជាង២០ឆ្នាំកន្លងទៅ ពិតជាបានដល់សុគតិភពគ្រប់ៗគ្នាមិនខាន ។

**ផេង ពង្សរ៉ាស៊ី**



បូជនីយ៍ដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# បញ្ជីឈ្មោះជនរងគ្រោះបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

(បញ្ជីជនរងគ្រោះបរទេសនេះក៏មាននៅក្នុងបញ្ជីជនរងគ្រោះរួមដែលត្រូវបានកម្ទេចនៅមន្ទីរស-២១ដែរ)

រៀបរៀងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | ចាប់មកពី | សញ្ជាតិ | មុខងារ | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ៦៥ | សំស៊ីអន អាវៀង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៦៦ | ដេង ចាន់សេន | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៦៧ | ចារូន ណូក្រសែ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៦៨ | ចាវៀង ណូក្រសែ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៦៩ | ម៉ាណេត ដុយចែមសៃ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៧០ | សុផាន់ ប៉ុាវង់សា | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៧១ | ម៉ុនទ្រី សីឆាណៈ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៧២ | រោយណេត ណូក្រសែ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៧៣ | ឡាត់ស៊ី វ៉ាផាន់ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៧៤ | មូលស៊ុន ចារើន ហៅ តៃ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ? |
| ៧៥ | ម៉ុង យុន | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៧៦ | កូវ រឹង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៧៧ | ដេត ដេនយឹម | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៧៨ | សំយឹត | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៧៩ | ថាំ ម៉ាឡាក | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨០ | សុតា ប្រុងរ៉េណូ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨១ | វិឆាយ ហៅ កុង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨២ | សាហាត់ ហៅ ពាក | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨៣ | ស្រីតការ ហៅ សឹង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨៤ | យុទ្ធ កុង សាំងរាង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨៥ | ឆើត អឹមថង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨៦ | ធម្មរ៉ាត គេជង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨៧ | វិឆ័យ អំផុវណាន់ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨៨ | សុំប៊ូន សេតបុផា | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៨៩ | ឡា ស៊ុមខា | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៩០ | ឥន្ទ្រី | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៩១ | ភាទ្រី សុភមុនី | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៩២ | សារួម | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៤-៥-៧៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩៣ | ប៉ាក ដាន់ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ៩៤ | សឹត | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ៩៥ | ទី ណាត | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ៩៦ | សំ ស៊ី | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ៩៧ | អា ណុប | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ៩៨ | ដេង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ៩៩ | ម៉ាន នត | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០០ | ចា រូន | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០១ | សុដាន់ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០២ | ប៊ុន ទ្រី | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០៣ | ចា រៀង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០៤ | ឡុយ លោត | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០៥ | ឡាត់ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០៦ | ម៉ូន | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០៧ | ប៊ុន លៀង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០៨ | ឈុត តា | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១០៩ | រិឆៃ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១០ | សា ហាត់ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១១ | រិឆៃ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១២ | ចាន សុំ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១៣ | ស្រ៊ីត ការ | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១៤ | ខឹម | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១៥ | ដេង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១៦ | យុត ដុង | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១៧ | ឆឹត | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១៨ | ឡាក | កំពង់សោម | សៀម | នេសាទត្រី | ៧-៥-៧៦ | ២៨-៥-៧៦ |
| ១១៩ | សាប់ វ៉ា | កំពង់សោម | សៀម | កូនសិស្ស ស្លាប់ | ២៧-១១-៧៦ | ២៨-១-៧៧ |
| ១២០ | ហៀវ គុងហាន | កំពង់សោម | សៀម | កូនសិស្ស | ២៧-១១-៧៦ | ២៨-១-៧៧ |
| ១២១ | រិញ យាំុងតាំ | កំពង់សោម | យួន | ? | ? | ២៨-៤-៧៨ |
| ១២២ | ង៉ូ យាំុងឡើយ | កំពង់សោម | យួន | ពលបាលផ្កាយ១ | ? | ២៨-៤-៧៨ |
| ១២៣ | រិញ ភីឡុង | កំពង់សោម | យួន | ? | ? | ២៨-៤-៧៨ |
| ១២៤ | ង្វៀង យាំុងវ៉ា | កំពង់សោម | យួន | ចោរព្រៃបឹញញី | ១៨-៤-៧៨ | ២៨-៤-៧៨ |
| ១២៥ | ត្រឹង យាំុងចុង | កំពង់សោម | យួន | ចោរព្រៃបឹញញី | ១៨-៤-៧៨ | ២៨-៤-៧៨ |
| ១២៦ | ង្វៀង វ៉ាន់វ៉ាង | កំពង់សោម | យួន | ចោរព្រៃបឹញញី | ១៨-៤-៧៨ | ២៨-៤-៧៨ |

**(នៅមានត)**

# ក្បួនឆ័ពព្រៃខ្មែរក្រហម

(តពីលេខមុន)

**២៩) អធិប្បាយរបៀបចាក់**

១) លើកអាវុធ១ថ្នាក់ របៀបដូចជាគំនាប់អាវុធ ។

២) អាវុធវាត់ចុងទៅមុខ ៦ ជើងឆ្វេងបោះទៅមុខឲ្យព្រមជាមួយអាវុធ ។

៣) ដៃទាំងពីរនោះចាប់អាវុធចាក់ទៅមុខរួចយកជើងស្តាំទៅជុំនឹងជើងឆ្វេងវិញ បើត្រូវចាក់ទៀត ត្រូវបោះជើងឆ្វេងទៅមុខទៀត ។

**៣០) សញ្ញានិងដៃពេលដើរ មាន១០ខ**

១) បើឃើញមនុស្សម្នាក់ ត្រូវលើកដៃឆ្វេងឡើងលើ ។

២) បើឃើញមនុស្ស២-៣នាក់ ។ (គ្មានបញ្ជាក់)

៣) បើឃើញសត្វពាហនៈ ត្រូវលើកដៃឆ្វេងបត់ត្រង់ទៅលើកែងដៃស្មើស្មា ។

៤) បើឃើញរថយន្ត ឬរទេះគោក្របី ត្រូវលើកដៃឆ្វេងបង្វិលឲ្យមូល ។

៥) បើឃើញថ្នល់ ត្រូវលើកដៃឆ្វេងសន្ធឹងឲ្យត្រង់ទៅមុខ ។

៦) បើចង់ទៅមុខ ត្រូវលើកដៃឆ្វេងបោះទៅមុខ ។

៧) ហៅកាំភ្លើងយន្ត ត្រូវលើកដៃឆ្វេងអង្កុញទៅលើទៅក្រោម ។

៨) បើឈប់ លើកដៃទាំងពីរខ្វែង ។

៩) ថយក្រោយ លើកដៃឆ្វេងសន្ធឹងបត់ថយក្រោយ ។

១០) បើផ្ទះ ឬបន្ទាយ ត្រូវលើកដៃឆ្វេងអង្កុញដាក់លើស្មា ។

**៣១) សញ្ញានិងកញ្ចែ ត្រែ ស្គរ មាន៧ខ**

១) ដាស់ពីដេក ——— ——— ———

២) ប្រជុំ ———● ———● ———●

៣) ពេលបាយ ●——— ●——— ●———

៤) អាសន្ន ●● ——— ●●——— ●●———

៥) សូត្រធម៌ ——— ———●

៦) ដេក ●———●———

៧) ហៅនាយ ឬមេ ●●● ——— ●●● ———

**៣២) សញ្ញានិងសម្តីវាចា**

ពេលចេញដើរទៅរកខ្មាំង មេត្រូវប្រាប់ពាក្យសញ្ញាជាមុន ដើម្បីស្រួលចំណាំថា គ្នាយើង ឬគ្នាគេ តែពាក្យនោះត្រូវផ្លាស់ប្តូរជារាល់ថ្ងៃ ការពារមិនឲ្យខ្មាំងវាបន្លំបាន ដូចជាពេលចេញទៅល្បាតក្តី តស៊ូក្តី គោងឲ្យមានពាក្យសញ្ញាដូចសួរថា "បរទេស" យើងឆ្លើយថា "ជាតិ" ទើបហៅថាគ្នាយើង ។

**៣៣) របៀបយាម មាន៧យ៉ាងគឺ**

១) កន្លែងប្រចាំការ

២) តូបយាម

៣) មេប្រចាំការ

៤) នាយប្រចាំការ

៥) អ្នកយាម

៦) បញ្ញត្តិដើម

៧) បញ្ញត្តិផ្សេងៗ

មេគឺអ្នកមានបណ្តាស័ក្តិធំជាងខ្លួន ឬមានប្រាជ្ញាមោះមុតជាងគេ ។ ក្នុងកន្លែងប្រចាំការ បើមេមានធុរៈ ត្រូវឲ្យនាយជំនួសមេ ឬនាយត្រូវចេះចាត់ការយាមល្បាតបញ្ញត្តិដើម និងបញ្ញត្តិផ្សេងៗឲ្យច្បាស់លាស់ ។

**៣៤) បញ្ញត្តិយាម មាន១០ខ**

១) មិនឲ្យជក់ ឬស៊ីផឹក

២) មិនឲ្យងោកងក់ ឬអង្គុយ

៣) មិនឲ្យយកសំពត់ ឬអ្វីមករុំត្រចៀក

៤) មិនឲ្យដាក់អាវុធឆ្ងាយអំពីខ្លួន

៥) មិនឲ្យដើរឆ្ងាយពីតូបយាមឲ្យហួសពី១៥ម៉ែត្រទៅឆ្វេង

ទៅស្តាំ ទៅមុខ

៦) មិនត្រូវនិយាយនឹងពួកម៉ាកឬស្រីអ្នកចម្ងាយ វៀរលែងតែមានការសំខាន់ណាស់ ត្រូវស្រែកឲ្យគេឈប់ ហើយហៅមេមកជម្រាប បើមេអនុញ្ញាតទើបនិយាយបាន តែហាមមិនឲ្យចូលមកជិតខ្លួនឡើយ ត្រូវឲ្យនៅឃ្លាតចម្ងាយ៥០ម៉ែត្រ ៦ អាវុធត្រូវដាក់នៅចង្កេះ វាត់ចុងទៅមុខជាដរាប ។

៧) មិនត្រូវដើរចោលកន្លែងដោយគ្មានអនុញ្ញាតពីមេ ឬនាយ ។

៨) បើមានធុរៈ ត្រូវសុំមេ ឬនាយ ។

៩) ត្រូវសម្គាល់មើលដើមឈើ ឬមានវត្ថុអ្វីខ្លះនៅជិតខ្លួន ។

១០) ត្រូវគំនាប់តាមអ្នកមានបណ្តាស័ក្តធំ ឬតូច ។

## ៣៥) យាមថ្ងៃ

មួយកន្លែង២នាក់ គឺ១នាក់ឈរនៅដី ១នាក់ទៀតឡើងយាមនៅលើចុងឈើខ្ពស់ ដើម្បីមើលខ្មាំងបានពីចម្ងាយ គន់មើលឲ្យសព្វគ្រប់ ។ បើឃើញខ្មាំងពីចម្ងាយ ត្រូវចុះមកប្រាប់អ្នកឈរនៅដីដោយប្រញាប់ ដើម្បីឲ្យអ្នកឈរនៅដីរត់ទៅប្រាប់ដល់ក្រុម ឬពួកដែលនៅខាងក្រោយ ឬបើប្រទះជិតនឹងរត់ទៅប្រាប់ដល់មេមិនទាន់ ត្រូវបាញ់ទៅរកខ្មាំង ដើម្បីឲ្យដំណឹងដល់ពួកយើង គោងទទួលដឹងខុសត្រូវចំពោះមនុស្សចេញ ឬចូល គោងឆែកដោយល្អិត បើមានវត្ថុផ្សេងៗអ្នកយាមត្រូវដកទុកឲ្យ បើចេញទៅវិញគោងមើលឲ្យសព្វគ្រប់ក្រែងបានយកប្រដាប់ប្រដា ឬអាវុធជាតិផ្ទុះទៅផង ។

## ៣៦) យាមយប់

ក្នុងមួយកន្លែងមាន២នាក់ ចំនួន២ម៉ោងផ្លាស់ម្តង ១នាក់ឈរយាម១កន្លែង ១នាក់ទៀតដើរល្បាតគយគន់មើលខ្មាំងចម្ងាយ១៥ជំហានទៅឆ្វេង ឬស្តាំ ទៅមុខ ត្រូវចំណាំមើលដើមឈើអ្វីខ្លះដែលមានដុះនៅជិតខ្លួន ការពារក្រែងខ្មាំងបន្លំដោតមែកឈើមកនឹងខ្លួន ហើយទិតម្តងបន្តិចៗចូលមកចាប់ខ្លួន ហាមផ្ទាត់មិនឲ្យជុតភ្លើង ឬជក់បារី គោងដឹងថាអ្នកយាមនេះជាភ្នែកប្រមុះរបស់កងទ័ព ។ កងទ័ពចម្រើន ឬខូចក៏អាស្រ័យនឹងអ្នកយាមនោះឯង ។

## ៣៧) របៀបយាមក្នុងព្រៃ

ត្រូវពួនតាមដំបូកធំៗ ឬដើមឈើធំៗចម្ងាយពីពួក ១គីឡូម៉ែត្រ ដូចជាអ្នកយាមឈរក្នុងបន្ទាយដែរ ។ បើខ្មាំងមកដល់ចម្ងាយ២០ម៉ែត្រ ឬ១០០ម៉ែត្រ យើងស្រែកឲ្យឈប់មិនទាន់ទេ ត្រូវបាញ់តម្រង់ទៅខ្មាំង ដើម្បីឲ្យពួកយើងបានដឹងហើយសឹមរត់ទៅរកគ្នាយើង ហាមមិនឲ្យរត់ពីមុខទេ ត្រូវរត់ចូលទៅពីចំហៀង ឬពីក្រោយ ដើម្បីកុំឲ្យខ្មាំងវាដឹងពីកន្លែងយើង ។ បើនៅចម្ងាយ២០០ម៉ែត្រ ឬ៣០០ម៉ែត្រ ត្រូវធ្វើសញ្ញាឲ្យដឹងថាគ្នាយើងឬគ្នាគេ ។ បើខ្មាំងត្រូវស្រែកហៅមេ ហើយស្រែកឲ្យឈប់ចម្ងាយពីខ្លួនយើង៥០ម៉ែត្រ រួចបង្គាប់ឲ្យទម្លាក់អាវុធ ហើយឲ្យលើកដៃទាំងពីរទៅលើ អាវុធយើងត្រូវលើកត្រឹមចង្កេះ ហើយវាត់ចុងទៅមុខរកខ្មាំងទើបឲ្យមេចូលឆែក ។ របៀបចូលឆែកនោះត្រូវចូលពីចំហៀង ទាហានទាំងពីរនាក់ត្រូវលើកអាវុធតម្រង់ឲ្យចំដើមទ្រូងខ្មាំង វេលា...យប់បើឃើញខ្មាំងដើរតម្រង់មកចំហើយ ត្រូវឲ្យឈប់ចម្ងាយពីខ្លួន៥០ម៉ែត្រ ហើយសញ្ញាសួរថាគ្នាយើង ឬគ្នាគេ បើឆ្លើយត្រូវហើយ ត្រូវហៅមកសួរទៀត បើឆ្លើយមិនត្រូវទេ ត្រូវបាញ់ភ្លាម ឯកាំភ្លើងត្រូវដាក់តម្រង់ទៅរកមនុស្ស បើមានអាវុធឲ្យដាក់ចុះ បើកំរើក ឬញោចខ្លួន យើងត្រូវបាញ់ព្រោះមិនទាន់ទុកចិត្ត ។

**មន្ទីរអ្នកគយគន់**

ទិសរកខ្មាំង

កន្លែងមេ ផ្លូវថយ

បើឃើញមនុស្សដើរចំមុខ ត្រូវធ្វើសញ្ញាសួរឲ្យដឹងហើយ

ពួកម៉ាកស្តាំ អ្នកយាម ពួកម៉ាកឆ្វេង

ហើយហៅមេមកប្រាប់ មិនត្រូវបាញ់ទេ ត្រូវមើលឲ្យប្រាកដសិន សឹមបាញ់ បើខ្មាំងហើយ ។

## ៣៨) សម្រែកក្នុងពេលយាមយប់ មាន៣

បើកំពុងឈរយាម ហើយឃើញមនុស្សដើរចូលមក ត្រូវស្រែកថា ÷

១) ឈប់!

២) ឈប់! កុំចូល!

៣) ឈប់! កុំចូលខ្ញុំបាញ់!

**៣៩) អ្នកល្បាត**

អ្នកល្បាតមានគ្នាចំនួន១៣នាក់ដែលមេចាត់ឲ្យទៅល្បាតនៅខាងមុខពួក ឬក្រុម មុននឹងអ្នកយាមល្បាតចេញទៅកាន់នាទីនីមួយៗ ត្រូវចាត់អ្នកបំភ្លឺផ្លូវចំនួន៦នាក់ឲ្យដើរទៅជាមុន បើផ្លូវព្រៃត្រូវឲ្យឃ្លាតចម្ងាយ៥០ម៉ែត្រ ផ្លូវវាលត្រូវឲ្យឃ្លាតចម្ងាយ១០០ម៉ែត្រ ត្រូវគេយកគន់ឲ្យសព្វគ្រប់ បើមានការអ្វី ត្រូវចាត់ឲ្យរត់ទៅប្រាប់មេ ឬក៏ឲ្យដំណឹងដោយសូរកាំភ្លើងតាមការប្រចុំដួន ត្រូវដាក់ឲ្យអ្នកបំភ្លឺផ្លូវខាងក្រោយទៀត ដើរយូរៗ មើលក្រោយម្តង ដើម្បីមើលការពារក្រែងខ្មាំងវាមកពីក្រោយទៀត ។

ពួកដែលដើរខាងក្រោយត្រូវដើរបណ្តោយខ្នងឃ្លាតគ្នា៥ម៉ែត្រ ឬ១០ម៉ែត្រពីម្នាក់ទៅម្នាក់ បើដើរមិនត្រូវនិយាយគ្នាឲ្យឮខ្មាំង បើឈប់ មិនត្រូវជក់បារី ឬដុតភ្លើងអ្វីឲ្យសោះ បើមានការតស៊ូ ត្រូវវាយគ្នាជាខ្សែភ្លាម ហាមមិនឲ្យបាញ់ឈរ ត្រូវអង្គុយ លុតក្រាបជាដរាបតាមក្បាច់ទាហានខ្លួនទីពឹងខ្លួន ។

**៤០) កិច្ចល្បាត មាន១០ខ**

១) ត្រូវដឹងពេលចេញទៅ

២) ត្រូវដឹងពេលចូលមក

៣) ត្រូវស្គាល់ផ្លូវចេញ

៤) ត្រូវស្គាល់ផ្លូវចូល

៥) ត្រូវស្គាល់សញ្ញាគ្នាយើង

៦) បើប្រទះខ្មាំង ត្រូវឲ្យ១នាក់ទៅប្រាប់មេ ត្រូវលាក់ខ្លួនឲ្យបាត់

៧) បើគេចខ្លួនមិនរួចទេ ត្រូវស្រែកឲ្យពួករាយជាខ្សែដើម្បីត្រៀមតស៊ូ

៨) បើពួនបានកុំបាញ់ ត្រូវលបមើលឲ្យជាក់តើគ្នាវាប៉ុន្មាននាក់ តើប៉ុន្មាននាក់ដើរមុខទៅណា ។

៩) បើគ្នាវាតិចជាង ត្រូវឡោមព័ទ្ធចាប់ដោយស្រួលតាមរបៀប

១០) មិនត្រូវនិយាយគ្នាឲ្យឮខ្មាំង យប់ឬថ្ងៃ

**៤១) របៀបចម្បាំង**

ទាហានត្រូវរៀននូវរបៀបចម្បាំងឲ្យចេះចាំស្ទាត់ដើម្បីបានស្រួលនិងមានផលប្រយោជន៍ដល់ខ្មាំង ឯខ្មាំងមិនអាចនឹងរុករានបានឡើយ ។ របៀបចម្បាំងមាន១២ខដូចតទៅនេះ ÷

១) សម្រែក

២) ហាត់ប្រាណ

៣) ផ្ទើដំណើរ

៤) តាំងទីលំនៅ

៥) រាយពល

៦) អារុធ

៧) ឡោមព័ទ្ធចាប់

៨) លាក់ខ្លួនបំពួនអាត្មា

៩) ផ្លាស់ប្តូរទីកន្លែង

១០) ឆ្លងព្រែក អូរ ស្ទឹង

១១) ឡើងភ្នំ ចុះភ្នំ

១២) ដោះខ្លួនពីចំណោមខ្មាំង

**សម្រែក មានពីរយ៉ាង**

មួយយ៉ាងសម្រាប់ស្រែកពេលហាត់ប្រាណ មួយយ៉ាងស្រែកក្នុងចម្បាំង ឯសម្រែកហាត់ប្រាណនោះដូចមានក្នុងវិធីហាត់ប្រាណស្រាប់ ។

**៤២) វិធីសម្រែកក្នុងសង្គ្រាមមាន៧យ៉ាង**

១) ពាក់កណ្តាលពួករាយជាខ្សែទៅមុខ៥០ម៉ែត្រ

២) ពាក់កណ្តាលពួករាយជាខ្សែទៅឆ្វេង-ស្តាំ

៣) ពួករាយជាខ្សែទៅឆ្វេង-ស្តាំ

៤) ពួករាយជាខ្សែខាងឆ្វេង-ស្តាំ

៥) ពួកជាជួរឃ្លាតគ្នា៥០ម៉ែត្រ

៦) ពួកជាជួរ

៧) ពួករាយជាជួរចម្ងាយឃ្លាតគ្នាទទឹងនិងបណ្តោយ៥០០ម៉ែត្រ ឬបើក្រុមត្រូវស្រែកថា ក្រុមជា៣ជ្រុង ឬជាជួរទទឹងបណ្តោយ ដូចសម្រែកក្នុងពួក ។

**៤៣) សេចក្តីអធិប្បាយគឺ**

១) ដែលហៅថាពាក់កណ្តាលពួករាយជាខ្សែទៅមុខ

៥០ម៉ែត្រ គឺយើងដើរទៅរកខ្មាំង ហើយគ្មានពួកម៉ាកនៅឆ្វេង ស្តាំ មេត្រូវនៅជាមួយអ្នកនាំការណ៍ មេពួកត្រូវនៅជាមួយអ្នកកាន់កាំភ្លើងយន្ត ។

២) ពាក់កណ្តាលពួករាយជាខ្សែខាងឆ្វេង ស្តាំ៥០ម៉ែត្រ លុះត្រាតែយើងដើរទៅប្រទះគុម្ពោត ឬដុបដុះសងខាង ឬត្រពាំង ។

៣) ពួកជាខ្សែខាងឆ្វេង ខាងស្តាំ លុះត្រាយើងដើរប្រទះមាន អូរ ស្ទឹង ថ្នល់ ឬប្រទះតនឹងខ្មាំង ។

៤) ពួកជាខ្សែនោះ គឺយើងឡោមខ្មាំង ឬឡោមបន្ទាយ ។

៥) ពួកជាជួរចម្ងាយ៥០ម៉ែត្រនោះ ចំពោះតែយើងដើរកណ្តាលវាល ហើយមានពួកម៉ាកនៅខាងមុខ ឆ្វេង-ស្តាំ ។

៦) ពួកជាជួរនោះចំពោះតែដើរក្នុងព្រៃធំ ហើយមានផ្លូវចង្អៀត មានពួកម៉ាកនៅខាងមុខ ។

៧) ពួកជាជួរទទឹងបណ្តោយ៥០ម៉ែត្រនោះ លុះត្រាតែយើងដើរកណ្តាលវាល ហើយមានពួកម៉ាកនៅមុខ ខាងឆ្វេង ឬស្តាំ ។

### ៤៤) ក្រុមជា៣ជួរ

ពួកមួយឡើងទៅមុខ ឬពីរពួកឡើងទៅមុខ ។ ពួកទី២ឡើងទៅមុខ ពួកទី១ឡើងទៅខាងឆ្វេង ឯពួកទី៣នៅខាងស្តាំខាងក្រោយ ។ បើពួកទី១នឹងទី៣ឡើងទៅមុខ គោងពួកទី២នៅកណ្តាល នៅខាងក្រោយ ទទឹងនិងចម្ងាយបណ្តោយ១៥០ម៉ែត្រ ទាហានដើរខាងក្រោយ ត្រូវដើរឃ្លាតគ្នា ៥ ឬ១០ជំហានពីម្នាក់ទៅម្នាក់ ពួកឬក្រុមរាយជាខ្សែទៅមុខធ្វើដូចក្រុមស្មើគ្នាដែរ ។

### ៤៥) ក្រុមបណ្តោយខ្នងឃ្លាតគ្នា

ត្រូវចាត់អ្នកបំភ្លឺផ្លូវឲ្យដើរទៅមុខចម្ងាយ៥០ម៉ែត្រ ឬ ១០០ម៉ែត្រ ឯពួកទី១និងទី២ព្រមទាំងពួកទី៣ ត្រូវដើរតាមក្រោយបណ្តោយចម្ងាយ៥០ ឬ១០០ម៉ែត្រតាមរយៈព្រៃ ឬវាលទាហានដើរតាមក្រោយត្រូវដើរឃ្លាតពីគ្នា៥ម៉ែត្រពីម្នាក់ទៅម្នាក់ បើកាលណាអ្នកបំភ្លឺផ្លូវនិងពួកទី១ប្រទះនឹងខ្មាំងវាបាញ់ គោងពួកទី២ឡើងទៅឆ្វេង ឯពួកទី៣ត្រូវឡើងទៅខាងស្តាំ តែត្រូវឲ្យអ្នកនាំការណ៍ទៅប្រាប់ដល់ពួកទី១ឲ្យបានដឹងខ្លួនថា បានឡើងមកហើយ ពួកដែលឡើងទៅក្រោយនោះ ត្រូវឡើងឲ្យស្មើនឹងពួកទី១សឹមបាញ់ ។

### ៤៦) ក្រុមស្មើគ្នា

ទទឹងពីមួយពួកទៅមួយពួកចម្ងាយ៥០ម៉ែត្រ ឬ១០០ម៉ែត្រ ទាហានដើរបណ្តោយខ្នងឃ្លាតគ្នាចម្ងាយ៥ជំហាន ទាំង៣ពួកនេះត្រូវឡើងឲ្យស្មើគ្នា ត្រូវពួកទី១នៅខាងឆ្វេង ពួកទី២នៅកណ្តាល ពួកទី៣នៅខាងស្តាំ ៖

ក) គ្រប់ពួករាយជាខ្សែ ហើយងើបឡើងទៅមុខ ។

ខ) គ្រប់ពួកឡើងពាក់កណ្តាល ពួកទៅមុខ ។

គ) គ្រប់ពួកឡើងម្នាក់ម្តងទៅមុខ ។

### ៤៧) ក្រុមប្រឆិតគ្នា

ពួកទី១នៅខាងឆ្វេង ៥០ម៉ែត្រ

ពួកទី២នៅកណ្តាល ៥០ម៉ែត្រ

ពួកទី៣នៅខាងស្តាំ

ចម្ងាយឃ្លាតគ្នា៥០ម៉ែត្រ ហើយបើត្រូវរាយគ្នាជាខ្សែ ឬជាជួរត្រូវធ្វើដូចក្រុមស្មើគ្នាដែរ ។

### ៤៨) អ្នកបំភ្លឺផ្លូវ

អ្នកបំភ្លឺផ្លូវត្រូវមានមេរងទៅជាមួយផង ដែលចេញដើរទៅ ត្រូវមើលទៅមុខ ឆ្វេង ស្តាំ ដើម្បីកុំឲ្យបាត់ ឬវង្វេងតែម្នាក់ឯង ត្រូវដើរឃ្លាតគ្នា១០មែត្រឬ២០ម៉ែត្រ បើប្រទះដុប ឬគុម្ពោតព្រៃ ត្រូវគយគន់មើលឲ្យសព្វគ្រប់ក្រែងខ្មាំងវាពួននៅនោះ ÷

១) បើប្រទះស្ពាន ត្រូវពិនិត្យមើលដោយល្អិតល្អ ក្រែងខ្មាំងវាកាត់សសរស្ពានមិនឲ្យដាច់ ឬចងគ្រាប់បែកនៅក្រោមនោះ ដល់យើងដើរធ្ងន់ទៅនឹងបាក់ ឬផ្ទុះគ្រាប់បែកនាំឲ្យអន្តរាយដល់ពួកយើង ម្យ៉ាងទៀតបើឮសូរកាំភ្លើងពីខាងណា ត្រូវផ្ទៀងស្តាប់ឲ្យជាក់ ឲ្យអ្នកនាំការណ៍មកប្រាប់មេក្រុមឲ្យបានដឹង ហើយខំដើរទៅមុខទៀត ដើម្បីមើលទៅខ្មាំង ឬគ្នាយើង បើខ្មាំងតើគ្នាវាប៉ុន្មាននាក់ វាដើរឆ្ពោះទៅកន្លែងណា ។

២) ត្រូវដើរអែបដំបូកធំៗ ព្រៃធំដើម្បីកុំឲ្យខ្មាំងមើលឃើញ បើប្រទះគុម្ពោតព្រៃ អូរស្ទឹង រទេះគោក្របី ត្រូវធ្វើសញ្ញាឲ្យមេដឹង គោងព្យាយាមមើលពួកម៉ាកឲ្យរឿយៗ បើឃើញគ្នា

យើងឈប់ យើងត្រូវឈប់ដែរ តែឈប់នោះត្រូវក្រាបពួន ។

### ៤៩) ប្រទះខ្មាំងថ្មើរជើង

បើកំពុងដើរហើយប្រទះខ្មាំងថ្មើរជើងតាមព្រៃ មេយើងត្រូវស្រែក ឬធ្វើជាសញ្ញាឲ្យទាហាន រាយគ្នាជាខ្សែក្លាម ឆ្វេង ឬស្តាំ ឃ្លាតគ្នា...៥ម៉ែត្រ ហើយត្រូវឡើងឲ្យស្មើគ្នា កុំឲ្យទៅមុខក្រោយឲ្យសោះ រួចចាត់មួយនាក់ឲ្យមកប្រាប់ដល់មេពួកគ្រប់ពួក បើក្រុមយើងនៅឆ្ងាយពីបន្ទាយខ្មាំង ត្រូវលបលូនវារទៅមុខឲ្យជិត ដើម្បីស្រួលបាញ់ ឬស្រួលចោលគ្រាប់បែក ។ មុននឹងបាញ់ត្រូវទទួលបង្គាប់ពីមេសិន ហើយមើលឲ្យច្បាស់ តើយើងឡើងស្មើគ្នាហើយឬនៅ បើស្មើគ្នាហើយ មេត្រូវបង្គាប់ឲ្យបាញ់ ។

### ៥០) ប្រទះរថយន្តតាមផ្លូវថ្នល់

បើប្រទះរថយន្តតាមផ្លូវថ្នល់ ត្រូវរាយពួកជាក្រុមជាខ្សែតាមផ្លូវថ្នល់ក្លាម ពួនតាមគុម្ពោតព្រៃ ភ្លឺស្រែ ដំបូកធំៗ ឃ្លាតគ្នាពីម្នាក់ទៅម្នាក់ចម្ងាយ៥ម៉ែត្រ មិនត្រូវពួនឆ្ងាយពីថ្នល់ពេកទេ ត្រូវពួនឲ្យជិតដើម្បីស្រួលតស៊ូ រួចហើយត្រូវស្តាប់ស្នូរកាំភ្លើងរបស់មេធ្វើសញ្ញាឲ្យបាញ់សឹមបាញ់ ។

### ៥១) ពេលប្រទះអាកាសយាន

បើមានអាកាសយានមក មេត្រូវដឹកពួកឲ្យទាហានរត់រកដើមឈើធំៗ ដំបូកធំៗ បើព្រៃស្តើង ឬរបោះ ត្រូវក្រាបពួនតាមគុម្ពោតល្មមបិទបាំងខ្លួនបាន បើកណ្តាលវាល ត្រូវប្រះដេកឲ្យនឹងមួយកន្លែងធ្វើដូចជាគល់ធំមួយ កុំឲ្យខ្មាំងដែលបើកយន្តហោះ វាមើលឃើញស្គាល់យើង បើមានដើមឈើមួយដើម ឬពីរដើម ត្រូវបំបែកគ្នាឲ្យគ្រប់ដើមឈើ បើអ្នកណានៅបៀតដើមឈើណា ត្រូវរត់ទៅរកដើមឈើនោះ បើរត់មិនទាន់ត្រូវប្រះដេកឲ្យនឹងមួយកន្លែង បើនៅជិតមាត់ព្រៃ អូរ ស្ទឹង ត្រូវរត់ជ្រកតាមនោះ លុះត្រាតែបាត់សូរយន្តហោះហើយ មេត្រូវដឹកពួកប្រមូលគ្នាវិញ ត្រួតមើលក្រែងបាត់ដោយសារហេតុអ្វី?

### ៥២) ពេលមានអាសន្ន

ពេលដេកក្តី សម្រាកក្តី ពេលបរិភោគបាយក្តី មិនត្រូវនៅជុំគ្នាទេ ត្រូវបំបែកគ្នាជា៣ជ្រុងឲ្យស្រេច លុះដល់មានអាសន្នដូចជាខ្មាំងវាបាញ់មក មេត្រូវស្រែកធ្វើជាសញ្ញាឲ្យទាហានបែកគ្នា បែរមុខឆ្ពោះទៅរកខ្មាំងក្រាបនៅមួយកន្លែង ២ ឬ៣នាក់ ឃ្លាតគ្នា ៥ម៉ែត្រ ត្រូវនៅឲ្យស្មើគ្នា បើប្រះដេកចង្អៀតគ្នា ឬមិនស្មើគ្នា ត្រូវលូនទៅបំបែកឡើងឲ្យស្មើគ្នាតាមរបៀប មិនត្រូវនៅមុខពួកម៉ាកយើង គោងឲ្យដឹងនាយចៅហ្វាយ និងពួកម៉ាកនៅឆ្វេងស្តាំ ។

**(នៅមានត)**



រូបគំនូរក្បួនទ័ពខ្មែរក្រហម

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះដើម | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៤៣៦ | សុផាន់ ប៉ាវង់សា | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៣៧ | ម៉ុនទ្រី ស៊ីឆាណៈ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៣៨ | រោយណោត ណូក្រសែ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៣៩ | ឡាត់ស៊ី វ៉ាផាន់ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤០ | មូលស៊ុន ចារើន ហៅ តៃ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤១ | ម៉ុង យុន | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤២ | កូវ វីដ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤៣ | ដេត ដេនយឹម | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤៤ | សំយឹត | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤៥ | ខាំ ម៉ាឡាក | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤៦ | សុតា ប្រុងរ៉េណូ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤៧ | វិឆាយ ហៅ ភុង | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤៨ | សាហាត់ ហៅ ពាក | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៤៩ | ស្រឹត កាវ ហៅ សឹង | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៥០ | យុទ្ធភុង សារំរាន | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៥១ | ឆើត អឹមថង | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៥២ | ធម្មវ៉ាត គេផង | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៥៣ | វិឆ័យ អំផូវណាន់ | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៥៤ | ស៊ុំប៊ុន សេតបុផា | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៥៥ | ឡា ស៊ុមខា | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៥៦ | ឥន្ទ្រី | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៥៧ | ឆាទ្រី សុភមុនី | នេសាទត្រី | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |
| ៤៥៨ | ឌី ពៅ | យុទ្ធជន | តំបន់២៥ | ? | ២៨-៥-៧៦ | |
| ៤៥៩ | ឡូវ ហ៊ី | យុទ្ធជន | វត្តហា | ២៥-១២-៧៥ | ២៨-៥-៧៦ | |
| ៤៦០ | សួន វ៉ាន់ស៊ីម | យុទ្ធជន | ផ្សារចាស់ | ២៩-២-៧៦ | ២៨-៥-៧៦ | |
| ៤៦១ | ភា ហ៊ុកចស៊ីវ | កម្មករ | តម្បាញ ត-៥ | ៩-៥-៧៦ | ២៨-៥-៧៦ | |
| ៤៦២ | ឆាយ ស្រ៊ាវ | ប្រជាជន | ភ្នំពេញ | ១៥-១២-៧៥ | ២៨-៥-៧៦ | |
| ៤៦៣ | ស៊ុយ កើត | ប្រជាជន | តំបន់១៥ | ២៣-៣-៧៦ | ២៨-៥-៧៦ | |
| ៤៦៤ | ព្រុំ ស៊ិន | យុទ្ធជន | ពោធិចិនតុង | ២៧-៣-៧៦ | ២៨-៥-៧៦ | |
| ៤៦៥ | ដាំ យ៉ាងជីង៉ុន | ? | កំពង់សោម | ៧-៥-៧៦ | ២៨-៥-៧៦ | |

| | | | | | |
|---|---|---|---|---|---|
| ៤៦៦ | ចាំង ផាន់ហឿង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៦៧ | ឡេ យ៉ាងម៉ាយ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៦៨ | ដឹម យ៉ាងគឹង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៦៩ | តាំង ង៉ុកហ៊ុង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧០ | លេ ផាក់ឡឹយ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧១ | ដាង យ៉ាងផា | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧២ | ង្វៀង ធីធឿង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧៣ | គីម ង៉ុកទៀង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧៤ | ចាង យ៉ាងហេវ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧៥ | ង្វៀង ដិនអ៊ី | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧៦ | ដាំង យ៉ាងចាន់ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧៧ | យ៉ យ៉ាងផាន់ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧៨ | ង្វៀង យូឡាង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៧៩ | យ៉ យ៉ាងដាង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨០ | បឹង យឹងកេុ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨១ | សារួម | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨២ | សាម ឡូយ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨៣ | ប៉ាក ដាន់ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨៤ | សឹត | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨៥ | ទី ឈាត | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨៦ | សំ ស៊ី | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨៧ | អា ណុប | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨៨ | ដេង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៨៩ | ម៉ាន នត | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩០ | ចា រូន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩១ | សុ ដាត់ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩២ | ប៊ុន ទ្រី | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩៣ | ចា រៀង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩៤ | ឡូយ លោត | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩៥ | ឡាត់ | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩៦ | មូន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩៧ | មុង ឃុន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩៨ | ប៊ុន លៀង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ៤៩៩ | កូ វីង | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |

**(នៅមានត)**

**(តចប់)**

គក ស្រស់ និយាយថា ជួនកាលក៏មានការស្ទាក់ស្ទើរកើតឡើងដែរ ហើយនៅក្នុង“កិច្ចការប្រជុំជីវភាព” ក្នុងចំណោមបុគ្គលិកមន្ទីរ ស-២១ដែលរៀបចំឡើងដោយ ចាន់ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ឌុចខ្លួនឯងផ្ទាល់ត្រូវបានកត់ត្រាសម្តីដែលបាននិយាយទៅកាន់បុគ្គលិករបស់ខ្លួនថា÷ “ត្រូវកម្ចាត់នូវទស្សនៈថាវាយអ្នកទោសគឺឃោរឃៅ ។ (ករណីនេះ) មិនត្រូវធ្វើចិត្តល្អទេ ។ (ត្រូវវាយវា) ដោយមូលហេតុជាតិ មូលហេតុវណ្ណៈនិងមូលហេតុអន្តរជាតិ” ។




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី៦: បរិយាយអំពីមន្ទីរស-២១**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

គួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំងដែលពាក្យសម្តីរបស់ ឌុច មានចាប់ពីពេលសន្តិបាលចាប់ផ្តើមដំណើរការដំបូងគឺជាពេលមួយដែល គ្រីសស្តូហ្វ័រ ប្រោនីង និងនិស្សិតដទៃទៀតដែលសិក្សាពីការសម្លាប់រង្គាលរបស់ណាហ្ស៊ីទៅលើជនជាតិជ្វីហ្វបានកត់ត្រាទុកនូវការស្ទាក់ស្ទើរដំណើរត្រឡប់ទៅជាស្អប់ខ្ពើមនិងការភ្ញាក់ផ្អើល ក្នុងចំណោមអ្នកដែលត្រូវបានចោទថាបានសម្លាប់មនុស្សទាំងហ្វូងៗ ។ នៅពេលមន្ទីរស-២១ ចាប់ផ្តើមប្រតិបត្តិការដំបូង ការស្ទាក់ស្ទើរពីធម្មជាតិក្នុងការធ្វើទារុណកម្មនិងសម្លាប់អ្នកទោស ត្រូវបានព្យាយាមជម្នះដូចជាម្នាក់ដែល ឌុច បានព្រមានខាងលើ ។ ពេលវេលាចេះតែរំកិលទៅមុខ បុគ្គលិកធ្វើការនៅមន្ទីរស-២១ ក៏ដូចជាពួកណាហ្ស៊ីដែរ បានខំបិទបាំងអំពើរបស់ខ្លួន ក្លិនអសោចរបស់សាកសព រូបរាងគោកយ៉ាករបស់អ្នកទោសនិងសម្រែករបស់អ្នកទោស ។

ការលាក់កំបាំងរបៀបនេះគឺអាចយល់បាន ប៉ុន្តែការធ្វើមិនអើពើចំពោះការឈឺចាប់របស់អ្នកដទៃនៅតែបន្តលទ្ធភាពធ្វើឲ្យមនុស្សមានការរន្ធត់តទៅទៀត ។ អ្វីដែលយើងរង់ចាំ ហើយមិនបានទទួលផលនោះ គឺការព្រលយពាក្យថា អ្វីដែលអ្នកធ្វើការនៅមន្ទីរស-២១ បានធ្វើឲ្យខូចខាតដល់ទំនាក់ទំនងក្នុងចំណោមអ្នកទាំងនោះ បណ្តាលឲ្យញ័រដៃនៅពេលសរសេរ និងធ្វើមិនឲ្យដេកលក់ស្រួល ។ ចំពោះ ឌុច និង កូនចៅខ្លួន ចាត់ទុកថា អ្នកទោស “ថោកជាងសំរាមទៅទៀត” ។ ការស្រង់យកចម្លើយសារភាពពីអ្នកទោស មើលទៅហាក់ដូចជាសំខាន់ក្នុងការការពារបដិវត្តន៍និងមិនសូវស្មុគស្មាញ ឬមិនពិបាកជាងការលាងចិញ្ចើមថ្នល់ ឬភ្ជួរស្រែឡើយ ។ អំពើឃោរឃៅដែលជនដៃដល់បានធ្វើឡើងស្របគ្នាទៅនឹងការមិនអើពើរបស់មេកោយ ឬត្រូវបានការយល់ព្រមហើយវាមិនអាចប្រាប់ថា តើពេលណាអំពើឃោរឃៅត្រូវបានចងក្រងជាឯកសារច្រើនជាងគេនៅក្នុងបណ្ណសារ ឬតើជនដៃដល់មានការរីករាយចំពោះទង្វើរបស់ខ្លួនដល់កម្រិតណានោះទេ ។

គ្មានជនដៃដល់ណាម្នាក់និយាយនៅក្នុងកិច្ចសម្ភាសន៍ថា ខ្លួនជួបសុបិនអាក្រក់នៅក្រោយឆ្នាំ១៩៧៩ ឡើយ វាផ្ទុយទៅនឹងជនរងគ្រោះដែលនៅរស់រានមានជីវិត ។

ដោយសារការមិនចេញមុខរបស់អ្នកសួរចម្លើយ យើងអាចត្រឹមតែស្ទង់បានថា អ្នកសួរចម្លើយមានអារម្មណ៍បែបណានៅពេលខ្លួនកំពុងធ្វើការនៅមន្ទីរស-២១ប៉ុណ្ណោះ ។ ប្រសិនមានជនដៃដល់ណាម្នាក់ត្រូវបាននាំយកមកកាត់ទោសនៅចំពោះមុខតុលាការនោះ ម៉្លេះគេនឹងឆ្លើយថា គេធ្វើតាមបញ្ជា នៅក្រោមលក្ខខណ្ឌពេលមានសង្គ្រាម ហើយថាការវាយដំនិងធ្វើទារុណកម្ម (ទោះជាអាចប្រកែកមិនព្រមធ្វើក៏ដោយ) បានជំរុញឲ្យមានការស៊ើបរកការពិតឲ្យបានកាន់តែលឿន ការពារមជ្ឈិមបក្ស និងសង្គ្រោះជាតិកុំឲ្យ “អាខ្មាំងយួនលេបទឹកដី” ។ មិនខុសអ្វីពីអាដុលអេចម៉ាន់, ហ្វ្រានស៍ ស្តាង ហ្គុល, និងក្រុមផ្តាច់ខ្លួនថ្មីៗនេះ មានដូចជា អៀង សារី នួន ជា និង ខៀវសំផនទេ អ្នកធ្វើការនៅមន្ទីរស-២១ ទាំងនោះ ក៏អាចនិយាយការពារខ្លួនបានដែរថា




កាលនោះវាផ្សេង ឥឡូវវាផ្សេង ។ ដូចឃ្លាមួយដែល ខៀវ សំផន បាននិយាយនៅឯសន្និសីទសារព័ត៌មាននៅខែធ្នូ ឆ្នាំ១៩៩៨ ជាភាសាអង់គ្លេសទាំងរដាក់រដុបនិងរញីរញ៉័រថា "រឿងដែលកន្លងហួសទៅហើយ ឲ្យវាហួសទៅចុះ" ។ អ្នកទាំងនោះអាចបន្ថែមទៀតថា អំពើឃោរឃៅនិងការរំលោភបំពានធ្វើឡើងនៅមន្ទីរស-២១ គឺដោយសារខ្មាំងបរទេសឈ្លានពានទឹកដីកម្ពុជាប្រជាធិបតេយ្យ និងដើម្បីតស៊ូសង្គ្រោះ"ពូជសាសន៍ខ្មែរ"ស្ទូតត្រង់ដែលត្រូវវិនាសគ្រោះ ។ បើតាមលោកទស្សនៈបែបកម្មផលវិញថា "រាល់កំហុស" ឬការធ្វើជ្រុលដែលប្រព្រឹត្តឡើងនៅក្នុងគុក គឺសុទ្ធតែជាស្នាដៃរបស់"គិញវៀតណាម" ។ នេះជាមាគ៌ាដែល ខៀវ សំផន ប្រកាន់យកនៅទសវត្សរ៍ ឆ្នាំ១៩៨០ ហើយជាមាគ៌ាដែល ប៉ុល ពត ផ្ទាល់ និយាយហើយនិយាយទៀតនៅក្នុងកិច្ចសម្ភាសន៍ជាមួយ ណេត ថេយ័រ ។ ឧបករណ៍ភាសាប្រើសម្រាប់បុគ្គលិកធ្វើការនៅក្នុងគុកនិង"បង១ថ្នាក់លើ"នៅរក្សាលក្ខណៈដូចដើម ។

ការសុំទោសដូចអ្វីដែល អៀង សារី នួន ជា និង ខៀវ សំផន បាននិយាយប្រហែលជាងាយស្រួលយល់ណាស់ ប៉ុន្តែការកំណត់ពីអំពើមនុស្សឃាតយ៉ាងធំនិងអំពើគួរឲ្យព្រឺព្រួចពិតជាមានកម្រិត ។ គ្មាន"បរិបទ"ណាមានទំហំគ្រប់គ្រាន់សម្រាប់ទង្វើរបស់ សុន សេន, ឌុច និង "បង១ថ្នាក់លើ"ទេ ។ បរិយាយយ៉ាងម៉េចក៏នៅតែឃើញថា ឃាតករសម្លាប់មនុស្សដែលមានបញ្ហាដែរ ។ បុគ្គលម្នាក់ ឬបុគ្គលមួយចំនួនដែលដើរតួជំនួសមុខឲ្យមជ្ឈិមបក្សបានសម្រេចចិត្តធ្វើឃាតអ្នកទោសដែលសន្តិបាលឃុំឃាំងដោយមិនខ្វល់ថា អ្នកទោសបានធ្វើអ្វីឡើយ ។ ធ្វើដូច្នេះដើម្បីកម្ចាអ្នកជិតស្និទ្ធសំខាន់ៗ ការពារការណ៍សម្ងាត់និងបង្ហាញថា បក្សធ្វើអ្វីមិនចេះខុសទេ ។ ដោយដឹងពីរបៀបចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យឃើញថា សេចក្ដីសម្រេចចិត្តឲ្យធ្វើការងារក្នុងលក្ខណៈនេះ គឺប្រហែលជាចេញមកពី ប៉ុល ពត ឬយ៉ាងហោចណាស់ធ្វើឡើងត្រូវទៅនឹងការយល់ព្រមរបស់ ប៉ុល ពត ទោះជាមកដល់សព្វថ្ងៃ មិនទាន់ឃើញមានភស្តុតាងណាបញ្ជាក់ពីការយល់ព្រមរបស់ ប៉ុល ពត ក៏ដោយ ។ "បង១ថ្នាក់លើ" ដែលដើរតាមក្រោយប្រតិបត្តិការនៅមន្ទីរស-២១ និង សុន សេន ព្រមទាំង ឌុច ដែលជាអ្នកទទួលខុសត្រូវដំណើរការទាំងអស់នេះដោយផ្ទាល់ដឹងថា អ្វីដែលគេកំពុងធ្វើនិងអ្វីដែលត្រូវធ្វើតទៅទៀត ។

តាមការពិត បុគ្គលទាំងនេះ ប្រហែលជាអាចបន្ទូរបន្ថយ











ការឈឺចាប់របស់អ្នកទោស ដោះលែងកូនក្មេងតូចៗដែលជាប់គុកជាមួយម្តាយ ឬបន្ធូរបន្ថយការកាប់សម្លាប់ ប្រសិនបើគេពិតជាចង់ធ្វើមែនៗ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពិតជាមានជម្រើសធ្វើបែបនេះបាន ហើយយុត្តិធម៌បដិវត្តន៍ក៏អាចធ្វើដោយក្តីមេត្តាបានដែរ ។ មិនតែប៉ុណ្ណោះ អ្នកដែលនៅរស់រានមានជីវិតចាកផុតពីរបបកម្ពុជាប្រជាធិបតេយ្យ បានលើកឡើងនូវឈ្មោះកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលមានចិត្តល្អ ឬកម្មាភិបាលមិនសូវតឹងតែង ។ ក៏ប៉ុន្តែនៅមន្ទីរស-២១វិញ មិនអាចមានផ្លូវផ្សេងបែបនេះឡើយ ។ ទាំង សុន សេន, ឌុច និងកូនចៅដែលធ្វើការនៅក្រោមបង្គាប់ បានបង្កការឈឺចាប់ជាពន់ពេកមកលើអ្នកទោសដោយចិត្តត្រជាក់ជាប្រព័ន្ធនិងគ្មានវិប្បដិសារីចំពោះទង្វើរបស់ខ្លួនឡើយ ។

ហ្សីមុន បូមែន ដែលសរសេរអំពីការសម្លាប់រង្គាលរបស់ណាហ្ស៊ីទៅលើជនជាតិជ្វីហ្វនិងគំនិតសម័យថ្មីនៅក្នុងស្នាដៃរបស់ មីលក្រាម បានរំឭកយើងថា «ពត៌មានគួរឲ្យរន្ធត់បំផុតដែលបានមកពីអំពើមហាឃាតកម្មទៅលើជនជាតិជ្វីហ្វនិងអ្វីដែលយើងដឹងពីជនដៃដល់នៃអំពើនេះ មិនមែនបញ្ជាក់ពីលទ្ធភាពថា«អំពើនេះ» អាចធ្លាក់មកលើយើងទេ ប៉ុន្តែគំនិតថា យើងអាចធ្វើអំពើនេះបានៗ ប្រសិនបើអត្ថន័យនៃមន្ទីរស-២១ (ឬការសម្លាប់រង្គាលជនជាតិជ្វីហ្វ) អាចត្រូវបានបង្រួញមកត្រឹមមួយប្រយោគ ខ្ញុំសូមជ្រើសរើសយកប្រយោគរបស់ បូមែនៗ ចិត្តវិទូមួយរូបឈ្មោះ រ៉ូប៊ើត ចេ លីហ្វតុន ដែលសរសេរអំពីបុគ្គលិកពេទ្យនៅតាមជំរំណាហ្ស៊ី មានគំនិតប្រហាក់ប្រហែលគ្នានេះដែរ ។ លោកបានកត់សម្គាល់ថា «មនុស្សធម្មតាអាចប្រព្រឹត្តអំពើឃោរឃៅបែបនេះ» ។

ការពន្យល់អំពីមន្ទីរស-២១ដែលបន្ទោស«មនុស្សអាក្រក់» ថាបានធ្វើអំពើអាក្រក់ ពោលគឺបន្ទោសអ្នកដទៃថា ជាអ្នកធ្វើអំពើអាក្រក់ មិនបានគិតថា អ្វីដែលយើងទាំងអស់គ្នាចូលរួមជាមួយជនដៃដល់ប្រព្រឹត្តអំពើអាក្រក់ តាមពិតគឺមិនមែនជាវប្បធម៌ ជាលទ្ធិឬទំនោរចង់សម្លាប់មនុស្សដែលមានមកពីកំណើតនោះទេ ប៉ុន្តែវាជាសារជាតិរបស់មនុស្សជាតិ ហើយជាពិសេសជាទំនោររបស់យើងទៅរកការធ្វើតម្រាប់តាមនិងគោរពបញ្ជា ។ ភាគច្រើននៃយើងទាំងអស់គ្នា ខ្ញុំសង្ស័យថា អាចចាប់ផ្តើមស៊ាំនឹងការធ្វើអ្វីមួយ (ដូចជាការធ្វើទារុណកម្ម ឬការកាប់សម្លាប់) ក្នុងខណៈអ្នកដែលយើងគោរពប្រាប់ឲ្យយើងធ្វើបែបនេះនិងខណៈដែលគ្មានកំហិតថា ត្រូវធ្វើយ៉ាងម៉េចៗខ្លះនោះ ។ ចំពោះយើងរាល់គ្នា កិច្ចការស៊ើរតែទាំងអស់នឹងគ្មានអ្វីពិបាកទេ បើជនរងគ្រោះត្រូវបានចាត់ទុកថាជាអ្នកក្រៅទៅហើយនោះ ។ មីលក្រាម បានកត់សម្គាល់ក្នុងសំណេរទាក់ទងនឹងបទពិសោធន៍របស់ខ្លួនថា «បុគ្គលម្នាក់គឺជាភ្នាក់ងារម្នាក់ នៅពេលបុគ្គលនោះចាត់ទុកខ្លួនឯងថា ស្ថិតនៅក្នុងស្ថានភាពសង្គមជាក់ស្តែងដែលតម្រូវឲ្យខ្លួនធ្វើតាមបទបញ្ជាពីបុគ្គលម្នាក់ទៀតដែលមានឋានៈខ្ពស់ជាងខ្លួន» ។ ចង់និយាយថា អ្វីដែលត្រូវបានអនុញ្ញាតឬបញ្ជាឲ្យធ្វើទោះជាអាក្រក់បែបណាក៏ដោយ គឺត្រូវតែកើតឡើង ។ ក្នុងលក្ខខណ្ឌបែបនេះ កម្រមានការប្រកែកណាស់ មានតែការប្រព្រឹត្តតែម្តង ។ ចំណែកឯអំពើជុយទីងសីលធម៌ ដូចដែល បូមែន លើកហេតុផលសមរម្យដែរថា គឺត្រូវតែទៅតាមសង្គម ។ ជុយមកវិញអំពើជម្នះ រឹងរូស ឬភាពមេត្តា គឺវាអាស្រ័យទៅលើជម្រើសផ្ទាល់ខ្លួនរបស់បុគ្គល ។ ជម្រើស




បន្ទប់ឃុំឃាំងតូចៗនៃមន្ទីរស-២១

ដែលផុយទៅនឹងឆន្ទៈរបស់ខ្លួនកម្រមានណាស់ ។ ដូចដែលអ្នកនិពន្ធ ស្តូប្ស តាប់ រំឭកយើងនៅក្នុងន័យផ្សេងមួយទៀតថា «សេចក្តីក្លាហានដែលតម្រូវឲ្យមានក្នុងការកម្រិតអំពើហិង្សានោះជាទូទៅមិនមែនជាសេចក្តីក្លាហានចេញមកពីកម្លាំងកាយដែលជាឆន្ទៈចង់ដាក់ជីវិតនោះទេ ប៉ុន្តែវាជាសេចក្តីក្លាហានក្នុងការជំទាស់ក្រុមរបស់ខ្លួន និងសេចក្តីក្លាហានក្នុងការធ្វើឲ្យគ្រោះថ្នាក់ដល់ឋានៈនៅក្នុងក្រុម ឬអាជីពរបស់ខ្លួន ។

ប៉ុន្តែដោយរំលឹកពាក្យស្រងេះស្រងោចរបស់ ប៊ូមែន វាហាក់ដូចជាថា ការបរិយាយពីអំពើឃោរឃៅរបស់មន្ទីរស-២១ វាលពិឃាតដើងឯកនៃកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងអំពើឃោរឃៅដូចជាការសម្លាប់រង្គាលរបស់ពួកណាហ្ស៊ីទៅលើជនជាតិជ្វីហ្វ ការសម្លាប់រង្គាលនៅវ៉ាន់ដា, បូសនៀ និង ឥណ្ឌូនេស៊ី ចាំបាច់ត្រូវស្វែងរកមិនត្រឹមតែក្នុងចំណោមអ្នកដែលបង្កការឈឺចាប់និងអ្នកដែលចេញបញ្ជាប៉ុណ្ណោះទេ ប៉ុន្តែត្រូវស្វែងរកកម្រិតរួមទូទៅតែម្តង ដូចដែល ស៊ីរីនី និង ប៊ូមែន បានស្នើឡើង ។ នៅក្នុងស្នាដៃនិពន្ធមានចំណងជើងថា «ប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរបំផុត» គ្រេន តាន់ តូដូរ៉ូវ បានបដិសេធការចោទប្រកាន់ដែលថា ស៊ីរីន គាំទ្រ ស្តាងហ្គល ជ្រុលពេក ។ តូដូរ៉ូវ សរសេរថា «តើនេះជាអ្វីដែលយើងចង់បានឬ? ។ ប្រតិកម្មរបៀបនេះបង្ហាញនូវអារម្មណ៍ភ័យខ្លាចដែលបុគ្គលម្នាក់អាចមានក្នុងការរកឃើញថា អ្នកធ្វើអំពើអាក្រក់មិនខុសគ្នាច្រើនទៅនឹងខ្លួនឯងទេ» ។

ការបរិយាយអំពីបាតុភូតដូចជានៅមន្ទីរស-២១នេះគឺបង្កប់នៅក្នុងសមត្ថភាពរបស់យើងផ្ទាល់តែម្តង ដែលមានដូចជាការបញ្ជានិងគោរពគ្នាទៅវិញទៅមករួមគ្នាជាមួយអ្នកផ្សេងទៀតប្រឆាំងនឹងជនចម្លែក លង់ប្រាណនៅក្នុងក្រុមចង់បានភាពឥតខ្ចោះ និងការយល់ព្រមនិងសមត្ថភាពក្នុងការបញ្ចេញកំហឹង និងការយល់ច្រឡំរបស់យើង ជាពិសេសនៅពេលយើងត្រូវបានជំរុញពីអ្នកដែលយើងគោរព ឲ្យធ្វើដូច្នេះទៅលើអ្នកដទៃដែលភាគច្រើនគ្មានអ្នកណាជួយ ។ ចង់ស្វែងរកប្រភពនៃអំពើអាក្រក់ដែលត្រូវបានប្រព្រឹត្តឡើងរៀងរាល់ថ្ងៃនៅមន្ទីរស-២១ យើងមិនចាំបាច់មើលទៅណាឆ្ងាយពីខ្លួនយើងទេ ។ **ចប់ដោយបរិបូណ៌**

# ប្រព័ន្ធសន្តិសុខភូមិភាគនិរតី

របបខ្មែរក្រហមត្រូវបានវាយរលំរលាយអស់រយៈពេលជាង២០ឆ្នាំកន្លងមកហើយ ប៉ុន្តែសំណួរដែលទាក់ទិនដល់អំពើដែលបណ្តាលឲ្យជីវិតប្រជាជនកម្ពុជាជាង១លាន៧សែននាក់ស្លាប់បាត់បង់ជីវិតក្នុងអំឡុងរបបខ្មែរក្រហម នៅតែកើតមាននិងនៅតែលើកមកជជែកវែកញែកយ៉ាងក្តៅគគុកនិងស្រួចស្រាល់នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ។ តើមូលហេតុអ្វីបានជាមានការកាប់សម្លាប់ប្រជាជនកើតឡើង? តើការប្រហារជីវិតប្រជាជនកម្ពុជាមានដំណើរការនិងលក្ខណៈបែបណា?

មូលហេតុសំខាន់ដែលបណ្តាលឲ្យមានការប្រហារជីវិតប្រជាជនកើតឡើង គឺដោយសារគំនិតនិងមនោគមវិជ្ជារបស់មេដឹកនាំខ្មែរក្រហមដែលយល់ថា នៅក្នុងសង្គមនិងជុំវិញខ្លួនពោរពេញទៅដោយខ្មាំង ។ អត្រាខ្មាំងនៅក្នុងសហករណ៍មានរហូតទៅដល់ពាក់កណ្តាលនៃចំនួនប្រជាជនរស់នៅសហករណ៍ទាំងមូល ។ នេះបានសេចក្តីថា ក្នុងចំណោមប្រជាជនរស់នៅក្នុងសហករណ៍២នាក់ ម្នាក់គឺជាខ្មាំង ។ ក្រៅអំពីខ្មាំងនៅក្នុងសហករណ៍ដែលត្រូវខ្មែរក្រហមចាត់ទុកជាប្រភេទខ្មាំងខាងក្នុងនៃរបបនេះ មានខ្មាំងមួយប្រភេទផ្សេងទៀត គឺខ្មាំងខាងក្រៅ ។ ចំពោះខ្មែរក្រហម ខ្មាំងទាំងពីរប្រភេទនេះ ប៉ុនប៉ងវាយដណ្តើមអំណាចនិងបំផ្លិចបំផ្លាញបដិវត្តន៍របស់ខ្លួនគ្រប់ទីកន្លែងនិងគ្រប់ពេលវេលាទាំងនៅលើសមរភូមិនិងសូម្បីតែនៅតាមវាលស្រែ ។

ខ្មាំងខាងក្នុងជាប្រភេទខ្មាំងដែលបក្សកុម្មុយនិស្តកម្ពុជាមានការព្រួយបារម្ភយ៉ាងខ្លាំង ដោយសារខ្មាំងខាងក្នុងមានចំនួនច្រើនរហូតដល់ទៅ១៨៤០០០នាក់ (ស្មើនឹង២ភាគរយនៃចំនួនប្រជាជនកម្ពុជាទាំងអស់) ។ បក្សកុម្មុយនិស្តកម្ពុជាយល់ថា ខ្មាំងខាងក្នុងបានបន្តទំនាស់ស្មុគស្មាញ ស្លាប់រស់ ពីតូចទៅធំដោយ “ប្រព្រឹត្តនូវអំពើវិទ្ធង្សនាផ្សេងៗប្រឆាំងនឹងបដិវត្តន៍” ។ រីឯអំពើវិទ្ធង្សនារបស់ខ្មាំងខាងក្នុងមានការលួចឆក់ បេះបោចដំណាំក្នុងន័យបំផ្លាញបដិវត្តន៍ ។ អំពើវិទ្ធង្សនារបស់ខ្មាំងខាងក្នុងបានកើតឡើងនៅគ្រប់ទីកន្លែង គ្រប់ច្រកល្ហក តំបន់ ស្រុក សហករណ៍ ភូមិ ឃុំ ។ “ក្នុងការធ្វើស្រែគឺមានការប្រយុទ្ធពីរ ទីមួយប្រយុទ្ធនឹងធម្មជាតិទីពីរប្រយុទ្ធជាមួយខ្មាំងវាបំផ្លាញ ។ ខ្មាំងវាបំផ្លាញតាំងពីសន្ទូងទៅ វាបត់ដើម វាមិនស្ទូងពីឫស ពីគល់ឯណា វាស្ទូងបត់ បំផ្លាញច្រូត វាបំផ្លាញដឹក វាបំផ្លាញបញ្ជាន់ វាបំផ្លាញបន្ថយបង្កើនផលដោយការតស៊ូខាងបច្ចេកទេសផង តស៊ូវណ្ណៈផង តស៊ូរវាងបដិវត្តន៍និងមិនបដិវត្តន៍ផង” ។ ខ្មាំងខាងក្នុងនៅបានចូលស៊ីរូងផ្ទៃក្នុងដល់ក្នុងជួរបក្សនិងជួរកម្មាភិបាលដឹកនាំថែមទៀត ។ នៅក្នុងជួរដឹកនាំនេះ ខ្មាំងខាងក្នុងធ្វើសកម្មភាពប្រឆាំងនឹងអង្គការដោយ “ការបង្វែរមហាជនទៅតាមផ្លូវខុសពីមាគ៌ារបស់បក្ស” ។

ខ្មាំងជាប់និន្នាការនយោបាយ វណ្ណៈ ជាប្រភេទខ្មាំងមួយផ្សេងទៀតដែលបក្សកុម្មុយនិស្តកម្ពុជាចាត់ទុកថាជាខ្មាំងដែលមានបំណងគោលជំហរ និង គំនិតដូចខ្មាំងពិតប្រាកដរបស់អង្គការដែរ ។ ខ្មាំងជាប់និន្នាការនយោបាយ និង វណ្ណៈមានទំនាក់ទំនងជាមួយខ្មាំងរបស់អង្គការ ។ អង្គការមានជំនឿថា ការមានគំនិតគោលជំហរប្រឆាំងនឹងអង្គការពីមួយថ្ងៃទៅមួយថ្ងៃ ធ្វើឲ្យកម្លាំងប្រឆាំងនឹងបដិវត្តន៍រីកធំឡើងបន្តឲ្យទំនាស់រីកពីតូចទៅធំ ។ ដូចក្នុងទ្រឹស្តីបដិច្ចសមុប្បាទដែលបានបំពាក់បំប៉នកម្មាភិបាលគ្រប់រូបថា “អ្វីៗទាំងអស់សុទ្ធតែមានទំនាក់ទំនង អ្វីៗទាំងអស់សុទ្ធតែមានការវិវត្តប្រែប្រួលទៅមុខ អ្វីៗទាំងអស់ដែលវិវត្ត គឺវិវត្តពីទាបទៅខ្ពស់ ពីតូចទៅធំ ពីបរិមាណទៅគុណភាព អ្វីៗទាំងអស់សុទ្ធតែមានទំនាស់” ។

ប្រជាជនគ្រប់រូបដែលត្រូវបានចាប់ខ្លួនមកដល់មន្ទីរសន្តិសុខ ត្រូវបានចាត់ទុកជាខ្មាំងរបស់អង្គការដែលបានប្រឆាំងនឹងអង្គការយ៉ាងពេញទំហឹង ។ ក្នុងគំនិតរបស់កម្មាភិបាល មន្ទីរសន្តិសុខ វត្តមានរបស់ប្រជាជនក្នុងមន្ទីរសន្តិសុខ “ទោះបីជាគ្មាន

អាវុធ ឬជាប់ចំណង ក៏ជាគុំពិត គឺជាខ្មាំង» ។ ភារកិច្ចរបស់កម្មាភិបាលមន្ទីរសន្តិសុខជាមួយនឹងខ្មាំងទាំងនោះ គឺជាភារកិច្ចដោះស្រាយទំនាស់ ។ ជាទំនាស់រវាងបដិវត្តន៍នឹងខ្មាំង ហើយជាប្រភេទទំនាស់ស្លាប់រស់ ។ តាមទ្រឹស្តីបដិច្ចសមុប្បាទ វិធីដោះស្រាយទំនាស់ស្លាប់រស់នេះ ដាច់ខាតត្រូវឈរលើគោលជំហរវណ្ណៈ ។ ទ្រឹស្តីនេះពន្យល់ថា «មុននឹងសម្រេចវិភាគទំនាស់មួយ កម្មាភិបាលត្រូវតែសង្កេតមើលអំពីវណ្ណៈរបស់អ្នកដែលបានបង្កឲ្យមានទំនាស់នេះជាមុនសិន» ។

សៀវភៅកំណត់ហេតុរបស់សមមិត្ត ឃិន សូផន កត់ត្រាវគ្គសិក្សាវិភាគទំនាស់ក្នុងសង្គមកម្ពុជា បានលើកឧទាហរណ៍នៃវិធីវិភាគទំនាស់មួយ «យើងឃើញខ្មាំងធ្វើសកម្មភាពហើយ ប៉ុន្តែយើងថាវាមិនអី នេះមកពីយើងណែនាំមិនទាន់ក្តៅ ដូចជាខ្មាំងវាដឹកទឹកត្នោត ហើយជុះអាចម៍ដាក់ក្នុងបំពង់ទៀត យើងថាវាខិលណាស់ គឺមិនថាវាខ្មាំងទេ តាមពិតវាជាខ្មាំង» ។ វិធីវិភាគទំនាស់តាមទ្រឹស្តីបដិច្ចសមុប្បាទបានធ្វើឲ្យប្រជាជនស្លូតត្រង់មានកំហុសបន្តិចបន្តួចក្លាយជាខ្មាំងរបស់អង្គការដោយមិនដឹងខ្លួន ដោយសារអ្វីៗសុទ្ធតែទាក់ទងគ្នា សុទ្ធតែទាក់ទងនឹងអំពើក្បត់ សុទ្ធតែទាក់ទងជាខ្សែសង្វាក់ ។ សកម្មភាពផ្សេងទៀតដែលត្រូវរាប់បញ្ចូលរួមមានការធ្វើបាក់នង្គ័លពេលភ្ជួរ ស្ទូងបត់គល់សន្ទូង ធ្វើឲ្យបាក់ស្លាបព្រា កម្មសិទ្ធឯកជនដោយការលួចបេះផ្លែឈើនិងដំណាំរបស់សមូហភាពជាដើម ។

## *គោលការណ៍និងវិធានការ*

គោលការណ៍របស់បក្សកុម្មុយនិស្តកម្ពុជាក្នុងការដោះស្រាយទំនាស់ស្លាប់រស់រវាងបដិវត្តន៍និងខ្មាំង គឺស្វែងរកនិងប្រហារជីវិត ដែលជាភារកិច្ចចាំបាច់មិនចេះចប់មិនចេះហើយ និងជាភារកិច្ចដ៏ឧត្តុងឧត្តម ដើម្បីបុព្វហេតុ «ការពារ និង កសាងប្រទេស» ។ ពាក្យស្លោកខ្មែរក្រហមមួយបានកំណត់ថា «ដៃម្ខាងបង្កបង្កើនផល ដៃម្ខាងវាយខ្មាំង» ។ រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យដែលចូលជាធរមាននៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦និងលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជាបានកំណត់ការប្រហារជីវិតចំពោះ«ខ្មាំងដែលមានបំណងប្រឆាំងនឹងបដិវត្តន៍និងបំផ្លិចបំផ្លាញរបបកម្ពុជាប្រជាធិបតេយ្យដែលមានលក្ខណៈជាខ្សែសង្វាក់» ។ គណៈកម្មាធិការមជ្ឈិមបក្សក៏បានកំណត់ការផ្តន្ទាទោសចំពោះខ្មាំងតាមស្មារតីរដ្ឋធម្មនុញ្ញនិងលក្ខន្តិកៈបក្សដែរ ។ សេចក្តីណែនាំកំណត់ការផ្តន្ទាទោសស្រាលដោយការ«ណែនាំអប់រំ»និងផ្តន្ទាទោសកម្រិតខ្ពស់ដោយ«កម្ចាត់»ចំពោះខ្មាំងដែលប្រឆាំងនឹងអង្គការ«ដោយចេតនា ដោយគោលជំហរពេញចិត្តពេញថ្លើម» ។

វិធានការដោះស្រាយទំនាស់ស្លាប់រស់របស់បក្សជាមួយខ្មាំង កើតឡើងជាបន្តបន្ទាប់យ៉ាងពេញទំហឹង គ្មានព្រំដែនកំណត់និងគ្មានមេត្តា ។ ពាក្យស្លោកខ្មែរក្រហមមួយកំណត់ថា «ប្រហារជីវិតច្រឡំមនុស្សគ្មានកំហុស១០នាក់ ប្រសើរជាងដោះលែងមនុស្សមានកំហុសម្នាក់» ។

អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ បានឲ្យដឹងថា បន្ទាប់ពីមានយុទ្ធនាការជម្លៀសប្រជាជនចេញពីទីក្រុង បក្សបានតាមដាននិងរកឃើញគ្រាប់រំសេវនិងអាវុធជាច្រើនដែលអតីតទាហាន ប៉ូលិសរបប លន់ ណុល បានលាក់ទុកដើម្បីផ្តួលរំលំដណ្តើមអំណាចវិញ ។ ពេលនោះបក្សបានប្រកាសអំពីវត្តមានខ្មាំង ហើយផែនការរបស់បក្សចំពោះខ្មាំងទាំងនោះ គឺបន្តតាមរកនិងកម្ទេចចោល ។ តាមសម្តីរបស់ អៀង សារី ថានៅទូទាំងប្រទេសមានខ្មាំងខាងក្នុងពី១ ទៅ៥ភាគរយ ។ ចំពោះខ្មាំងខាងក្នុងក្រសួងការបរទេស អៀង សារី បញ្ជាក់ថា បាននិងកំពុងធ្វើសកម្មភាព ។ វិធានការចំពោះខ្មាំងខាងក្នុងទាំងនោះ អៀង សារី ប្រកាសឲ្យ«តាមដានប្រវត្តិរូប និងធ្វើជីវទស្សន៍ឲ្យច្បាស់លាស់»ដោយបញ្ជាឲ្យធ្វើដោយហ្មត់ចត់និងតឹងរ៉ឹងដូចជា«ព្រួល...ព្រួលបិទជិត» ដែលសូម្បីតែ«កំពីសក៏មិនអាចចេញរួចដែរ» ។


អៀង សារី

នួន ជា យល់ថា ខ្មាំងខាងក្នុងដែលសំខាន់ ហើយដែលត្រូវតែប្រហារជីវិតចោលមុនដំបូងបង្អស់ គឺសំណល់របប លន់ ណុល ។ នួន ជា បានណែនាំកម្មាភិបាលអំពីផែនការរបស់បក្សចំពោះជន


នួន ជា

សំណល់ថា "ទាហានចាស់កុំទុកធ្វើអ្វី ព្រោះអានេះវាមិនងាយលះបង់នូវគំនិតចាស់ទេ ដូចនេះត្រូវកម្ទេចចោលទាំងអស់" ។

ផែនការរបស់បក្សក្នុងការស្វែងរកនិងប្រហារជីវិតអតីតទាហាន ប៉ូលិស របប លន់ ណុល ដែលបក្សបានចាត់ទុកជាខ្មាំងក្នុងគោលដៅមុនគេ បានកើតឡើងនៅគ្រប់ទីកន្លែងគ្រប់ក្រសួងមន្ទីរទូទាំងប្រទេស ។ អតីតគណៈឃុំកំពែង ស្រុកព្រៃកប្បាស ខេត្តតាកែវ បានឲ្យដឹងថាផែនការបក្សក្នុងការស្វែងរកនិងប្រហារជីវិតខ្មាំងត្រូវបានដាក់ចុះទៅថ្នាក់ក្រោមដើម្បីអនុវត្ត ។ អតីតគណៈឃុំរូបនេះបានទទួលបញ្ជានិងអនុវត្តតាមផែនការរបស់បក្ស ។ នៅពាក់កណ្តាលឆ្នាំ១៩៧៥ គាត់បានចាប់ និងបញ្ជូនខ្លួនអតីតទាហាន លន់ ណុល ដែលរស់នៅក្នុងឃុំកំពែងជាច្រើននាក់ ប្រគល់ទៅឲ្យគណៈស្រុកព្រៃកប្បាស ។ កម្មាភិបាលខ្មែរក្រហមម្នាក់ទៀតឈ្មោះ អែម មីន ហៅ សែន សរសេររៀបរាប់ក្នុងចម្លើយសារភាពរបស់ខ្លួនថាៈ

"តាមផែនការបក្ស ត្រូវរៀបចំទទួលប្រជាជនដែលជម្លៀសចេញពីទីក្រុងភ្នំពេញនិងទីរួមខេត្តនានា ទុកប្រជាជនទាំងនេះមួយកន្លែងដោយឲ្យរស់នៅក្នុងភូមិនិងឃុំរបស់ប្រជាជន ។ ចំពោះអ្នកដែលបានបង្កប់ខ្លួនក្នុងចំណោមប្រជាជន ចាំបាច់ត្រូវតែដកចេញយកទៅដាក់មួយកន្លែង បន្ទាប់មកធ្វើការវាយតម្លៃ ស៊ើបអង្កេតពួកនេះឲ្យច្បាស់លាស់ ។ ប្រសិនរកឃើញថា នរណាជាមន្ត្រី ត្រូវកម្ទេចម្តងមួយៗ" ។

មុខសញ្ញាខ្មាំងដែលទទួលរងការបោសសម្អាតបន្ទាប់ពីអតីតទាហាន ប៉ូលិស របប លន់ ណុល គឺកម្មាភិបាលខ្មែរក្រហម និងប្រជាជនដែលត្រូវចោទប្រកាន់ថាក្បត់នឹងអង្គការ មានបំណងផ្តួលរំលំបក្សដោយការប៉ុនប៉ងធ្វើរដ្ឋប្រហារ និងធ្វើវិទ្ធង្សនកម្មផ្សេងៗ ។ វិធីសាស្ត្រទីមួយរបស់បក្សកុម្មុយនិស្តកម្ពុជាចំពោះខ្មាំងផ្ទៃក្នុង គឺ"បញ្ចុះបញ្ចូលស៊ុយទិតៀន និង វិធីផ្សេងៗទៀត" ។ វិធីសាស្ត្រនេះត្រូវបរាជ័យ ខ្មាំងនៅតែបន្តអុកឡុកនិងបំផ្លាញបក្សដដែល ។ ដូច្នេះបក្សកុម្មុយនិស្តកម្ពុជាបានលើកយកវិធីសាស្ត្រទីពីរមកអនុវត្តដោយត្រួតពិនិត្យ"ធាតុដើមរបស់កម្មាភិបាល" ។ ក្នុងខែកក្កដា ឆ្នាំ១៩៧៧ នួន ជា បានណែនាំបំពាក់បំប៉នគោលជំហរនយោបាយកងទ័ព និង កម្មាភិបាលក្នុងភូមិភាគឧត្តរអំពីផែនការទីពីររបស់បក្សចំពោះខ្មាំងដែលបានជ្រៀតចូលក្នុងជួរដឹកនាំ ជាពិសេសក្នុងសហករណ៍ និងក្នុងជួរបក្សឲ្យ "តាមដានធ្វើប្រវត្តិរូបដើម្បីបោសសម្អាតឲ្យអស់" ។ ផែនការទីពីរនេះទទួលបានជោគជ័យយ៉ាងធំធេង ។ នួន ជា ថ្លែងប្រាប់គណៈប្រតិភូដាណឺម៉ាកអំពីជ័យជម្នះនេះថា "ការធ្វើប្រវត្តិរូបធ្វើឲ្យយើងរកឃើញនិងដឹងថាកម្មាភិបាលរបស់យើងគឺជាភ្នាក់ងាររបស់ខ្មាំង" ។

### ការបែងចែកសិទ្ធិកម្ទេចខ្មាំង

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គណៈមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជា បានសម្រេចបែងចែកសិទ្ធិសម្រេចកម្ទេចខ្មាំងដល់គ្រប់ភូមិភាគ ក្រសួង មន្ទីរទូទាំងប្រទេសដូចតទៅៈ

- ◆ បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច ។
- ◆ ជុំវិញមន្ទីរមជ្ឈិមត្រូវគណៈមន្ទីរមជ្ឈិមសម្រេច ។
- ◆ តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច ។
- ◆ កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច ។

បន្ទាប់ពីបែងចែកសិទ្ធិកម្ទេចខ្មាំងគ្រប់ប្រភេទរបស់អង្គការទូទាំងប្រទេស គណៈមជ្ឈិមបក្សបានកំណត់និយមន័យខ្មាំងរបស់អង្គការ និងផ្តន្ទាទោសប្រហារជីវិតចំពោះ "ខ្មាំងគ្រប់ប្រភេទគ្រប់ជំនាន់ដែលប៉ុនប៉ងប្រឆាំងនឹងបដិវត្តន៍ ដោយចេតនាមានគោលជំហរពេញចិត្តពេញថ្លើមជាមួយខ្មាំងសត្រូវ" ។

គោលការណ៍និងវិធានការរបស់បក្សចំពោះខ្មាំងបានជ្រួតជ្រាបនិងកើតឡើងចាប់តាំងពីភូមិភាគរហូតដល់ឃុំនិងមន្ទីរសន្តិសុខទូទាំងប្រទេស ។ កម្មាភិបាលមន្ទីរសន្តិសុខម្នាក់សរសេរក្នុងសៀវភៅកំណត់ហេតុរៀនសូត្ររបស់ខ្លួនអំពីវិធានការរបស់បក្សក្នុងការប្រហារជីវិតខ្មាំងរបស់អង្គការថា "ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ទោះបីអ្នកឯងចូលសេ.អ៊ី.អាពីឆ្នាំណាក៏ដោយ ឲ្យតែរួមសកម្មភាពជាខ្សែសន្ទាក់ប្រឆាំងនឹងបដិវត្តន៍មិនព្រមឈប់សោះ អ្នកនោះឯងត្រូវមានទោស ។ ចំពោះយួន និងកា.ហ្សេ.បេ

ក៏ដូចជាសេ.អ៊ី.អាដែរ ឲ្យតែក្រោយ១៧ មេសា ១៩៧៥នេះ មិនព្រមឈប់ គឺត្រូវមានទោស» ។ ចំពោះ ឌុច គណៈមន្ទីរស-២១ យល់ថា ខ្មាំងខាងក្នុងគឺជា«សត្វខ្មូត» ជា«ដង្កូវ» និងជា«មេរោគ» ដែលពួនសម្ងំនៅក្នុងឈើនិងមេរោគដែលកើតចេញក្នុងសាច់ដែលធ្វើឲ្យឈើនិងសាច់នោះខូចស្អុយរលួយ ។ បទវិចារណកថារបស់បក្សបានប្រកាសប្រៀបធៀបខ្មាំងខាងក្នុងទៅនឹង«ដង្កូវក្នុងសាច់» ហើយវិធានការចំពោះដង្កូវនេះ គឺ«ឆ្កឹះចោល» ឲ្យអស់ ។

ចំពោះកម្មាភិបាលមន្ទីរសន្តិសុខ ការអនុវត្តការងារសន្តិបាលដោយសស្រាក់សស្រាំជាការងារដោះស្រាយទំនាស់ស្លាប់រស់រវាងបដិវត្តនិងខ្មាំង ។ «ការងារសន្តិបាលជាការងារតស៊ូវណ្ណៈ ជាការងារគាស់រំលើងឫសគល់វណ្ណៈជិះជាន់ ហើយការងារនេះទៀតសោតជាការងារការពារប្រទេសនិងកសាងបដិវត្តសង្គមនិយម ។

ពីមជ្ឈិមដល់មូលដ្ឋាន ប្រតិបត្តិការនៃមន្ទីរសន្តិសុខកើតឡើងនិងដំណើរការមិនដាច់សង្វាក់ ។ ប្រតិបត្តិការទំនាក់ទំនងរវាងថ្នាក់លើនិងថ្នាក់ក្រោមត្រូវបានកំណត់ក្នុងលក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជាយ៉ាងច្បាស់«អង្គការបក្សគ្រប់ជាន់ថ្នាក់ត្រូវអនុវត្តភារកិច្ចក្នុងចំណោមមហាជន ហើយអង្គការបក្សគ្រប់ជាន់ថ្នាក់ត្រូវតែរាយការណ៍អំពីសភាពការណ៍និងភារកិច្ចដែលខ្លួនបានធ្វើតាមកាលកំណត់នីមួយៗ» ។


តាម៉ុក

ឈិត ជឿន ហៅ តាម៉ុក ឬតា១៥ ជាលេខាភូមិភាគនិរតី សាច់ញាតិ និងកម្មាភិបាលដឹកនាំគ្រប់លំដាប់ថ្នាក់នៅក្នុងភូមិភាគនិរតី បានអនុវត្តយ៉ាងមានប្រសិទ្ធភាពតាមរដ្ឋធម្មនុញ្ញ តាមលក្ខន្តិកៈបក្ស តាមស្មារតីអង្គប្រជុំនិងសេចក្តីណែនាំផ្សេងៗរបស់គណៈមជ្ឈិមបក្ស ។ តាម៉ុកនិងសាច់ញាតិ បានបង្កើតឲ្យមានមន្ទីរសន្តិសុខក្នុងភូមិភាគនិរតីតាំងពីថ្នាក់ឃុំ ស្រុក តំបន់ និងភូមិភាគ ។ មន្ទីរសន្តិសុខក្នុងភូមិភាគនិរតី មានចំនួនសរុប២៥០ដែលបែងចែកជាមន្ទីរឃុំឃាំងថ្នាក់ឃុំចំនួន២២៥ ថ្នាក់ស្រុកចំនួន២១ ថ្នាក់តំបន់ចំនួន៣ និងថ្នាក់ភូមិភាគចំនួន១ ។ មន្ទីរសន្តិសុខទាំងអស់មានគោលបំណងតែមួយ គឺឃុំឃាំងនិងប្រហារជីវិតប្រជាជន ប៉ុន្តែដំណើរការនៃមន្ទីរសន្តិសុខទាំងនោះមានលក្ខណៈខុសប្លែកពីគ្នា ពោលគឺចំនួនអ្នកទោសកើនឡើងពីតិចទៅច្រើនទៅតាមលំដាប់ថ្នាក់ក្រោមទៅថ្នាក់លើ ។ ប៉ុន្តែអ្វីដែលធ្វើឲ្យយើងចាប់អារម្មណ៍នោះ គឺដំណើរការធ្វើទារុណកម្មសួរចម្លើយនិងការសម្លាប់អ្នកទោសមានច្រើននៅមន្ទីរសន្តិសុខថ្នាក់ក្រោមទៅវិញ ។ មន្ទីរដែលមានសកម្មភាពនិងដំណើរការសំខាន់និងស្រួចស្រាល់បំផុតនោះ គឺមន្ទីរអប់រំស្រុកនិងមន្ទីរសន្តិសុខតំបន់ ។

មន្ទីរឈ្លបឃុំគឺជាមន្ទីរឃុំឃាំងជនរងគ្រោះដែលមានទោសស្រាល ដូចជាលួចបេះបោចបន្លែបន្ការបន្តិចបន្តួច ។ មន្ទីរឈ្លបឃុំ មានមុខងារ២ គឺជាមន្ទីរឃុំឃាំងបណ្តោះអាសន្ន និងជាមន្ទីរលត់ដំធ្វើការងារធ្ងន់ធ្ងរ ។ ប្រជាជនដែលជាប់ឃុំឃាំងក្នុងមន្ទីរឈ្លបឃុំត្រូវបានហៅថា «អ្នកទោសរបស់អង្គការ» ។ មន្ទីរឈ្លបឃុំស្ថិតក្រោមការគ្រប់គ្រងរបស់គណៈឃុំនិងប្រធានឈ្លបឃុំ ។ មន្ទីរអប់រំស្រុកជាមន្ទីរនៅចន្លោះកណ្តាលរវាងមន្ទីរឈ្លបឃុំនិងមន្ទីរសន្តិសុខតំបន់ ។ មន្ទីរអប់រំស្រុក គឺជាមន្ទីរឃុំឃាំងប្រជាជនដែលត្រូវបានចោទប្រកាន់និងចាប់ខ្លួនពីបទប្រភេទខ្មាំងរបស់អង្គការជាអតីតទាហាន ប៉ូលិសនៃរបប លន់ ណុល និង ប្រភេទខ្មាំងធ្វើសកម្មភាពប្រឆាំងនឹងអង្គការ ។ មន្ទីរអប់រំស្រុកបំពេញមុខងារឃុំឃាំង សួរចម្លើយ និង ប្រហារជីវិត ។ មន្ទីរអប់រំស្រុកស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈស្រុក និងគណៈមន្ទីរអប់រំស្រុក ។

មន្ទីរសន្តិសុខតំបន់គឺជាមន្ទីរឃុំឃាំងប្រជាជនដែលភាគច្រើនជាអតីតទាហាន ប៉ូលិសក្នុងរបប លន់ ណុល និង កម្មាភិបាលបម្រើការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចោទប្រកាន់ថាក្បត់នឹងអង្គការជាខ្សែសង្វាក់ ។ មន្ទីរសន្តិសុខតំបន់បំពេញមុខងារជាមន្ទីរឃុំឃាំង សួរចម្លើយ និង ប្រហារជីវិត ។ ប្រជាជនដែលជាប់ឃុំឃាំងក្នុងមន្ទីរសន្តិសុខតំបន់ត្រូវបានហៅថា «ខ្មាំងរបស់អង្គការ» ។ មន្ទីរសន្តិសុខតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈមន្ទីរសន្តិសុខតំបន់និងគណៈតំបន់ ។

មន្ទីរសន្តិសុខភូមិភាគនិរតីមានទីតាំងនៅភ្នំសន្លុងក្នុងស្រុក

ទ្រាំង ខេត្តតាកែវ ។ មន្ទីរសន្តិសុខភូមិភាគនេះគឺជាមន្ទីរសម្រាប់ឃុំឃាំងប្រជាជនដែលត្រូវជាប្រពន្ធ កូន សាច់ញាតិរបស់អ្នកដែលត្រូវបានចោទប្រកាន់ថាជាខ្មាំងរបស់អង្គការ ហើយត្រូវបានអង្គការចាប់ខ្លួននិងប្រហារជីវិត ។ មន្ទីរសន្តិសុខភូមិភាគនិរតីគឺជាមន្ទីរឃុំឃាំងសម្រាប់លត់ដំការងារធ្ងន់ធ្ងរ និងមានរបបហូបចុកមិនគ្រប់គ្រាន់ ។ ប្រជាជនដែលត្រូវមើលឃើញថាបានប្រព្រឹត្តកំហុសបន្ថែម រួមមានការលួចឆក់របស់របរសមូហភាពលួចរត់គេចខ្លួន ធ្វើការមិនពេញដៃពេញជើង ត្រូវនាំទៅដាក់ក្នុងបន្ទប់ឃុំឃាំង និង ប្រហារជីវិត ។ មន្ទីរសន្តិសុខភូមិភាគនេះស្ថិតក្រោមការគ្រប់គ្រងរបស់លេខាភូមិភាគនិរតី ។

ខាងក្រោមនេះគឺជាចលនាទាក់ទងជាខ្មែរសង្កាក់ដែលបង្កើតឲ្យមន្ទីរសន្តិសុខក្នុងភូមិភាគនិរតីមានដំណើរការ ÷

ទំនាក់ទំនងទៅវិញទៅមករវាងថ្នាក់ក្រោមនិងថ្នាក់លើបានធ្វើឲ្យប្រតិបត្តិការរបស់មន្ទីរសន្តិសុខដំណើរការមិនចេះដាច់ ដូចចលនាកងវង្វង់ដែលវិលមិនឈប់ឈរ ។ ប្រធានក្រុម ប្រធានកងប្រធានភូមិ គណៈឃុំ និងគណៈសហករណ៍ ជាអ្នករាយការណ៍អំពីសមាសភាពខ្មាំងទៅគណៈស្រុក ។ បន្ទាប់ពីពិនិត្យរបាយការណ៍គណៈស្រុកបញ្ជាឲ្យឈ្លបឃុំចាប់ខ្លួនប្រជាជនបញ្ជូនទៅមន្ទីរឈ្លបឃុំនិងមន្ទីរអប់រំស្រុក ដើម្បីសួរចម្លើយ ។ អ្នកទោសក្នុងមន្ទីរឈ្លបឃុំត្រូវទទួលជោគវាសនា២ គឺ ១) ត្រូវបានដោះលែងឲ្យវិលត្រឡប់ទៅភូមិ ឃុំ និងសហករណ៍វិញ និង២) ត្រូវបញ្ជូនបន្តទៅមន្ទីរអប់រំស្រុក ។ ប្រធានមន្ទីរអប់រំស្រុកផ្ញើចម្លើយសារភាពរបស់អ្នកទោសទៅគណៈតំបន់ ។ បន្ទាប់ពីពិនិត្យចម្លើយសារភាពរបស់អ្នកទោស គណៈតំបន់ជាអ្នកសម្រេចឲ្យប្រហារជីវិត ។ អ្នកទោសដែលមានបុណ្យសក្តិខ្ពស់និងជាប់ពាក់ព័ន្ធដល់ផែនការប្រឆាំងនឹងអង្គការជាខ្មែរសង្កាក់ ត្រូវបានបញ្ជូនជាបន្តបន្ទាប់ពីមន្ទីរសន្តិសុខថ្នាក់ទាបដល់ថ្នាក់ខ្ពស់ និងរហូតដល់មន្ទីរស-២១នៅមជ្ឈិម ។ ចម្លើយសារភាពរបស់អ្នកទោសមន្ទីរស-២១ ត្រូវគណៈមន្ទីរស-២១ ផ្ញើទៅគណៈមជ្ឈិមបក្សដើម្បីពិនិត្យនិងសម្រេច ។

ន ហ៊ីង រ៉ាយ៉ា ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៥ពីព្រំប្រទល់ប្រទេសវៀតណាមខាងត្បូងក្រោមការចោទប្រកាន់ថាជាចារនារី និងជាខ្មែរចាត់តាំងរបស់ ថៅ យិញ ។ បន្ទាប់ពីជាប់ឃុំឃាំងនិងឆ្លងកាត់ការសួចម្លើយអស់រយៈពេលមួយខែក្នុងមន្ទីរសន្តិសុខតំបន់២៥ ន ហ៊ីង រ៉ាយ៉ា ត្រូវបានបញ្ជូនទៅមន្ទីរស-២១នៅថ្ងៃទី២៥ ខែវិច្ឆកា ឆ្នាំ១៩៧៥ ។

អ្នកទោសម្នាក់ទៀតឈ្មោះ ស៊ីសុវត្ថិ ប៊ុតសារ៉ា ហៅ ប្រឹង អាយុ៣៣ឆ្នាំ ត្រូវបានចាប់ខ្លួនឃុំឃាំងក្នុងមន្ទីរសន្តិសុខតំបន់២៥ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៦ ។ ប្រឹង ត្រូវបានបញ្ជូនមកដល់មន្ទីរស-២១នៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៧៦ ហើយត្រូវសមមិត្តឌុច ដាក់ឈ្មោះជូនគណៈមជ្ឈិមបក្សពិនិត្យនៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៦ ។



ប្រាហ៊ុម អតីតទាហានសក្តិ៤កន្ទះនៃរបប លន់ ណុល ត្រូវបានចាប់និងបញ្ជូនខ្លួនជាបន្តបន្ទាប់ពីមន្ទីរឈ្លបឃុំកោះធំទៅមន្ទីរអប់រំស្រុកកោះធំ ។ បន្ទាប់មកត្រូវបញ្ជូនពីមន្ទីរអប់រំស្រុកកោះធំទៅមន្ទីរសន្តិសុខតំបន់២៥ និងពីមន្ទីរសន្តិសុខតំបន់២៥ទៅមន្ទីរស-២១ ។ តាមចម្លើយសារភាពរបស់ ប្រាហ៊ុម បានឲ្យដឹងថាគាត់ត្រូវបញ្ជូនមកដល់មន្ទីរស-២១ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៦ ហើយត្រូវគណៈមជ្ឈិមបក្សសម្រេចឲ្យកម្ទេចនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៧៦ ។

អតីតសមាជិកព្រឹទ្ធសភារបប លន់ ណុល ឈ្មោះ យ៉ាស់យ៉ា ត្រូវបានចាប់ខ្លួននៅភូមិគោហេ ឃុំរការកោង ស្រុកមុខកំពូល តំបន់២៥ នៅវេលាម៉ោង១០យប់នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៥ ។ បន្ទាប់ពីត្រូវចាប់ខ្លួន យ៉ាស់យ៉ា ត្រូវបញ្ជូនខ្លួនជាបន្តបន្ទាប់ពីកន្លែងមួយទៅកន្លែងមួយ ។ ទីបំផុត យ៉ាស់យ៉ា ត្រូវស្លាប់ដោយការធ្វើទារុណកម្មនៅមន្ទីរស-២១ ។

ការស្លាប់បាត់បង់ជីវិតរបស់ ហ៊ុម ម៉ាន អតីតកម្មាភិបាលឡូត៍នេសាទក្នុងតំបន់២៥ មានដំណើររឿងមិនខុសពីយ៉ាស់យ៉ាឡើយ ។ ហ៊ុម ម៉ាន ត្រូវបានចាប់ខ្លួនឃុំឃាំង ហើយបញ្ជូនខ្លួនពីមន្ទីរសន្តិសុខមួយទៅមន្ទីរសន្តិសុខមួយរហូតដល់មន្ទីរស-២១ ។ ទីបំផុត គាត់ត្រូវគណៈមជ្ឈិមបក្សសម្រេចឲ្យកម្ទេចចោលនៅបឹងជើងឯក ។

**អៀ ម៉េង ទ្រី**



**មន្ទីរសន្តិសុខតំបន់១៥**

# ការលើកលែងទោសនិងការអភ័យទោស

ការលើកលែងទោស និងការអភ័យទោស មានចរិតខុសគ្នា ។ ការលើកលែងទោសពាក់ព័ន្ធទៅនឹងការលុបបំបាត់និងការបំភ្លេចនូវទោសកម្មដែលទាំងឧក្រិដ្ឋកម្មនិងទណ្ឌកម្មត្រូវទុកជានិរាករណ៍ ។ ផ្ទុយមកវិញ ការអភ័យទោសគ្រាន់តែត្រូវទុកការដាក់ទណ្ឌកម្មដល់បទល្មើសមួយអន្លើសិន ។ "ជាទូទៅការលើកលែងទោសត្រូវបានប្រើចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងអធិបតេយ្យភាពរបស់រដ្ឋ(អំពើក្បត់ជាតិ អំពើបះបោរ ខុទ្ទាមកម្ម) និងចំពោះទោសការណ៍នយោបាយការអត់អោនទោសដែលត្រូវបានគេយល់ថាមានភាពសក្តិសិទ្ធិសម្រាប់សុខមាលភាពសាធារណៈជាជាងការយកមកកាត់ទោស និងការដាក់ទណ្ឌកម្ម ...ការអភ័យទោសលើកទោសឲ្យការប្រព្រឹត្តបទល្មើសដែលប៉ះពាល់ដល់សន្តិភាពរបស់រដ្ឋ" ។

គោលបំណងដ៏ចម្បងរបស់ការលើកលែងទោសគឺដើម្បីស្តាបនាឡើងវិញនូវសណ្តាប់ធ្នាប់ផ្ទៃក្នុង ។ ការលើកលែងទោសគឺជាឧទាហរណ៍ដ៏មានសារប្រយោជន៍សម្រាប់អ្នករដ្ឋបាលពន្ធនាគារ និងអ្នកចរចានយោបាយព្រោះវាផ្តល់នូវបច្ចេកទេសមួយក្នុងការគ្រប់គ្រងផ្ទៃក្នុងនិងអានុភាពនយោបាយ ។ ប្រសិនបើអង្គសមាជិកសំខាន់ៗនៃភាគីម្ខាងប្រមើលឃើញថា លទ្ធផលចុងក្រោយមួយចេញពីកិច្ចព្រមព្រៀងសន្តិភាពជាការវិនិច្ឆ័យក្តីអំពីសកម្មភាពដែលពួកខ្លួនធ្វើឡើងនៅក្នុងខណៈមានជម្លោះនោះ ប្រហែលជាអ្នកទាំងនោះគ្មានបំណងទម្លាក់អាវុធចោលឡើយ ។ ការលើកលែងទោសអនុញ្ញាតឲ្យអតីតពួកជិះជាន់គាបសង្កត់ខាងយោធាអាចចូលមករួមរស់នៅក្នុងសង្គមជាតិវិញបាន ។ ការផ្លាស់ប្តូររបៀបនេះត្រូវបានជំរុញដោយស្មារតីនៃមាត្រា៦(៥) នៃសារបន្ថែមទី២នៃអនុសញ្ញាទីក្រុងហ្សឺណែវដែលចែងថាៈ "...ចុងបញ្ចប់នៃការប្រទូសរ៉ាយនានាអាជ្ញាធរកាន់អំណាចត្រូវតែខិតខំធ្វើយ៉ាងណាផ្តល់នូវការលើកលែងទោសឲ្យបានទូលាយទៅតាមលទ្ធភាពដែលអាចធ្វើបានដល់ជនទាំងឡាយដែលបានប្រឡូកនៅក្នុងជម្លោះប្រដាប់អាវុធ ឬដល់ជនដែលបានបាត់នូវសេរីភាពរបស់ខ្លួន ដោយហេតុថាមានជាប់ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធដោយត្រូវគេឃុំ ឬឃាត់ខ្លួន ។ ករណីនេះមិនអាចអនុវត្តបានចំពោះជនកំណាចឃោរឃៅរំលោភសិទ្ធិមនុស្សឡើយ ។"

ការលើកលែងទោសមានសារសំខាន់ណាស់ចំពោះសណ្តាប់ធ្នាប់សាធារណៈ ។ ការធ្វើឲ្យបរាជ័យផ្នែកយោធារបស់របបមុនវាស្រួលជាងការធ្វើឲ្យកងកម្លាំងសន្តិសុខទម្លាក់អាវុធចុះចាញ់ ។ លក្ខខណ្ឌនៃការលើកលែងទោសក៏អាចនាំឲ្យមានការរំលោភបំពានទៅថ្ងៃអនាគតដែរ ហើយការណ៍នេះនឹងនាំទៅដល់ភាពប្របូកប្របល់នៅក្នុងសង្គមកាន់តែខ្លាំងថែមទៀត ។ ជនរងគ្រោះប្រហែលជានៅខ្វាចរអែង ។ សូម្បីតែក្នុងកាលៈទេសៈដែលថា ជនរងគ្រោះត្រូវបានធានាផ្តល់នូវអនាគតមួយដែលគ្មានអំពើហិង្សា ក៏អ្នកដែលរស់រានមានជីវិតទាំងអស់នោះប្រហែលជាទាមទារកាន់តែច្រើនជាងការវិលត្រឡប់ទៅរកសណ្តាប់ធ្នាប់សាធារណៈទៅទៀត ពោលគឺជនរងគ្រោះអាចទាមទាការសងសឹក ឬចងពៀរជំនួសវិញ ។

ការខកខានក្នុងការផ្តល់នូវការសងសឹក ឬចងពៀរបង្ហាញថា ការទម្លាយភាពរួចទោសដល់របបមុនដែលបានប្រព្រឹត្តមិនអាចទៅរួចទេ ។ ហេតុដូចនេះ ការលើកលែងទោសប្រហែលជាមិនអាចទ្រទ្រង់នូវក្តីសង្ឃឹមថា មានប្រសិទ្ធិភាពគតិយុត្តនៅក្នុងចិត្តនៃជនរំលោភបំពានដទៃៗទៀតទេ ។ ម្យ៉ាងវិញទៀត ភាពផ្តាច់ការបានផ្តាច់ជីវិតនយោបាយ ។ ក្នុងខណៈពេលដែលមានការទម្លាក់ចេញពីអំណាច ការបែងចែកនយោបាយ និងការបែកខ្ញែកមនោគមវិជ្ជាកើតឡើងមុនពេលមានការបង្ក្រាប ។ ការលើកលែងទោសធ្វើឲ្យមានការផ្លាស់ប្តូរខាងនយោបាយយ៉ាង

រហ័ស ប៉ុន្តែកម្រនឹងធ្វើឲ្យមានផ្លូវក្នុងការរស់នៅដោយគ្មានហិង្សាណាស់ ។

ថ្មីៗនេះប្រទេសអាមេរិកឡាទីនមួយចំនួនបានអនុម័តច្បាប់ជាច្រើនដែលផ្តល់ការលើកលែងទោសដល់កម្លាំងសន្តិសុខនិងយោធាដែលត្រូវបានចោទប្រកាន់ពីបទពាក់ព័ន្ធទៅនឹងការរំលោភសិទ្ធិមនុស្ស ។ ក្នុងករណីច្រើនទៀតច្បាប់ទាំងអស់នេះបានការពារពួកយោធាឲ្យរួចពីការកាត់ទោសខាងព្រហ្មទណ្ឌនិងរដ្ឋប្បវេណីទោះបីជាខ្លួនបានរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរក៏ដោយ ។ ក្នុងករណីមួយចំនួនទៀត អង្គការអន្តរជាតិនានាដែលទទួលខុសត្រូវកិច្ចការត្រួតពិនិត្យការអនុវត្តរបស់រដ្ឋឲ្យស្របទៅនឹងកាតព្វកិច្ចសិទ្ធិសញ្ញាបានផ្អែកទៅលើការគស្ញមតិរបស់ខ្លួនប្រឆាំងនឹងច្បាប់លើកលែងទោសទាំងនេះ ។ ឧទាហរណ៍ការប្រឆាំងនឹងការលើកលែងទោសនៅប្រទេសអាហ្សង់ទីន អែលសាវ៉ាឌ័រ ស៊ូរីណាម និង អ៊ូរ៉ាហ្គាយ ត្រូវបានដាក់ស្នើជូនអង្គការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការរដ្ឋនានានៅទ្វីបអាមេរិក ។

បញ្ហាទាំងនេះស្ថិតនៅលើការធានាថា កាតព្វកិច្ចដែលចែងក្នុងសិទ្ធិសញ្ញាសិទ្ធិមនុស្សមួយចំនួនដើម្បីយកមកកាត់ទោសនូវការរំលោភបំពាន គឺមិនត្រូវគេប្រមាថមើលងាយទេ ព្រោះនេះគឺជាវិធាននៃបទដ្ឋានដាច់ខាត (*Jus Cogens*) ។ មានន័យថាត្រូវប្រតិបត្តិសិទ្ធិមិនប្រមាថ ។ កាលពីឆ្នាំ១៩៨៥ អ្នកចងក្រងឯកសារពិសេសរបស់អង្គការសហប្រជាជាតិម្នាក់បានលើកឡើងថា ការលើកលែងទោសមិនគួរត្រូវផ្តល់ឲ្យជនទាំងឡាយណាដែលមានទោសឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិទេ ។ ការលើកឡើងបែបនេះត្រូវបានគេគាំទ្រដោយសេចក្តីប្រកាសនិងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិស្តីអំពីគោលការណ៍មូលដ្ឋានពីរនៃយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្មនិងការរំលោភអំណាច ។ **អេលីហ្សាប៊ែត ម៉ាន់ស្អាក់**



សមមិត្ត អៀង សារី

# ការផ្សឹកព្រះសង្ឃ: ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញលើសាសនា

នៅពេលខ្មែរក្រហមចូលមកកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ ប្រជាជនកម្ពុជាភាគច្រើនបានគោរពប្រតិបត្តិសាសនាផ្សេងៗដែលមានការរៀបចំត្រឹមត្រូវ ។ ក៏ប៉ុន្តែ ការបង្កើតឡើងនូវរបបកម្ពុជាប្រជាធិបតេយ្យព្រមជាមួយនឹងការងាកទៅរក "ឆ្នាំសូន្យ" បាននាំឲ្យមានការកាត់បន្ថយដល់កម្រិតទាបបំផុតនូវសេរីភាពក្នុងការគោរពប្រតិបត្តិសាសនា ។ ចំពោះប្រវត្តិវិទូនិងអ្នកដែលនៅរស់រានមានជីវិតពីរបប ប៉ុល ពត យល់ថា វាជាការច្បាស់គ្មានអ្វីគួរឲ្យសង្ស័យទេថា បក្សកុម្មុយនិស្តកម្ពុជាពិតជាបានធ្វើទុក្ខបុកម្នេញលើសាសនាមែននៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ ក៏ប៉ុន្តែ ដើម្បីរកឲ្យឃើញថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញលើសាសនា តម្រូវឲ្យមានលក្ខខណ្ឌគតិយុត្តជាក់លាក់មួយចំនួន ។ អត្ថបទនេះបង្ហាញធាតុផ្សំមួយចំនួននៃឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញលើសាសនា ពិភាក្សាលើភាពមានន័យមិនប្រាកដប្រជាជុំវិញបទល្មើសនិងលើកជូនជាសង្ខេបនូវភស្តុតាងមួយចំនួនដែលមានស្រាប់ក្នុងការបង្ហាញឲ្យឃើញថា មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាពិតជាប្រព្រឹត្តបទល្មើសនេះមែន ។



ច្បាប់ស្តីអំពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលហៅនៅទីនេះថា "ច្បាប់កាត់ទោសខ្មែរក្រហម" ដែលឡាយព្រះហស្តលេខាដោយសម្តេចព្រះនរោត្តសីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅខែសីហា ឆ្នាំ២០០១ បានចែងនូវបញ្ញត្តិមួយចំនួនដែលទំនងជាដើម្បីគ្រប់គ្រងតុលាការខ្មែរក្រហមតែម្តង ។ នៅក្រោមច្បាប់កាត់ទោសខ្មែរក្រហម ការធ្វើទុក្ខបុកម្នេញលើសាសនាគឺជាបទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋទាំង៨ដែលស្ថិតក្នុងសមត្ថកិច្ចរបស់តុលាការខ្មែរក្រហមក្នុងនោះរួមមានឃាតកម្ម ការប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌និងការរំលោភទៅលើអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ស្តីអំពីទំនាក់ទំនងការទូត ។ ច្បាប់កាត់ទោសខ្មែរក្រហមយកនិយមន័យការធ្វើទុក្ខបុកម្នេញចេញពីមាត្រា២០៩និង២១០នៃក្រមព្រហ្មទណ្ឌកម្ពុជាដែលហាមប្រាមបទល្មើសប្រឆាំងនឹងជីវិតឬបុគ្គលជាសង្ឃ ទោះបីជានៅក្នុងពេលកំពុងថ្វាយបង្គំសុំសីលក្តីឬដោយសារការគោរពប្រតិបត្តិក្តី ។

## អំពើតម្រូវឲ្យមាន: ក្រុមដែលត្រូវការពារដោយច្បាប់

ដូចជាបទឧក្រិដ្ឋផ្សេងៗទៀតដែរ ការធ្វើទុក្ខបុកម្នេញលើសាសនាមានធាតុផ្សំជាគោលចំនួនពីរគឺ តម្រូវការឲ្យមានអំពើកើតឡើង និង តម្រូវការឲ្យមានចេតនា ។ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ចែងយ៉ាងចង្អៀតតាមទម្រង់ច្បាប់ទាក់ទងនឹងតម្រូវការឲ្យមានអំពើកើតឡើង ។ ច្បាប់នេះហាមប្រាមមិនឲ្យប្រព្រឹត្តបទល្មើសទាំងឡាយណាមកលើជីវិត ឬបុគ្គលដែលជាសង្ឃ ។ ក៏ប៉ុន្តែ មាត្រា៣នៃច្បាប់កាត់ទោសខ្មែរក្រហមមានដាក់បញ្ចូលមាត្រា២០៩ និង២១០ "ការវាយប្រហារលើសាសនា" ដែលជាឧក្រិដ្ឋកម្មមួយប្រភេទដែលត្រូវបានពង្រីកកាន់តែទូលាយចូល

នៅក្នុងច្បាប់អន្តរជាតិជាងនៅក្នុងច្បាប់កម្ពុជា ។ ហេតុដូចនេះ ច្បាប់កាត់ទោសខ្មែរក្រហមធ្វើឲ្យទម្រង់ឧក្រិដ្ឋកម្មនេះកាន់តែទូលំទូលាយជាងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ទៅទៀត ។

ជាការគួរឲ្យងឿងឆ្ងល់គឺថាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ការពារតែព្រះសង្ឃដែលគោរពប្រតិបត្តិសាសនា"ដែលទទួលស្គាល់ដោយរដ្ឋាភិបាលកម្ពុជា"(បញ្ជាក់នៅក្នុងអត្ថបទដើម) ។ នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧និង១៩៧២ ទោះបីជាព្រះពុទ្ធ-សាសនាត្រូវបានប្រកាសជាផ្លូវការថាជាសាសនារបស់រដ្ឋក៏ដោយ ក៏សេរីភាពក្នុងការគោរពប្រតិបត្តិសាសនាទូទៅត្រូវបានធានាយ៉ាងទូលំទូលាយដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ កំណត់សម្គាល់នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦សរសេរថា មានតែព្រះសង្ឃកាន់ព្រះពុទ្ធសាសនាទេដែលត្រូវបានការពារមិនឲ្យមានការធ្វើទុក្ខបុកម្នេញក្រោមមាត្រា២០៩ និងមាត្រា២១០ ។ ចំពោះបទល្មើសប្រឆាំងនឹងបព្វជិតនៃសាសនាផ្សេងៗទៀត ច្បាប់នេះប្រាប់អ្នកអានឲ្យទៅមើលមាត្រា៤៩៥និងទំព័របន្តបន្ទាប់ទៀត រួមមានឧក្រិដ្ឋកម្មដែលមានដែនអនុវត្តទូទៅ ជាអាទិ៍ដូចជាមនុស្សឃាតនិងទារុណកម្មជាដើម ។

ការមិនរាប់បញ្ចូលក្រុមសាសនាដែលជាជនជាតិភាគតិចដូចជាឥស្លាមសាសនិក និង គ្រិស្តសាសនិកនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ធ្វើឲ្យមានចន្លោះប្រហោងទៅក្នុងច្បាប់កាត់ទោសខ្មែរក្រហម ។ គិតត្រឹមឆ្នាំ១៩៧៥ ច្បាប់អន្តរជាតិទាក់ទងនឹងប្រធានបទនេះ ក៏មិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយដែរ ។ គ្មានអនុសញ្ញាណាមួយដើម្បីនឹងហាមប្រាមការរើសអើងសាសនាទេ ទាល់តែដល់ឆ្នាំ១៩៨១ទើបមហាសន្និបាតអង្គការសហ-ប្រជាជាតិអនុម័តសេចក្តីសម្រេច GARes.36/55 ។ សេចក្តីសម្រេចនេះមិនមែនជាសេចក្តីប្រកាសសម្រាប់ការអនុវត្តរួមស្តីអំពីការលុបបំបាត់ភាពមិនចេះអត់ឱននិងការរើសអើងដោយសារសាសនា ឬជំនឿគ្រប់រូបភាពនោះទេ ។

ទស្សនៈរណ៍ល្អជាងគេក្នុងការបញ្ចូលបុគ្គលក្រៅពីព្រះសង្ឃព្រះពុទ្ធសាសនានៅក្នុងច្បាប់ខ្មែរក្រហម គឺស្ថិតនៅលើការវិភាគទៅលើច្បាប់ទម្លាប់អន្តរជាតិ ។ ធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីអំពីសិទ្ធិមនុស្ស និង កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ហាមប្រាមមិនឲ្យមានការរើសអើងសាសនាដោយលើកតម្កល់សេរីភាពខាងជំនឿសាសនាជាសិទ្ធិមនុស្សដ៏ធំ ។ អ្នកសិក្សាជាន់ខ្ពស់ជាច្រើនយល់ស្របថា ការធ្វើទុកបុកម្នេញលើសាសនា ពិតជារំលោភលើច្បាប់អន្តរជាតិតាំងពីមុនសម័យខ្មែរក្រហមមកម្ល៉េះ ។ ផ្អែកតាមទស្សនៈរណ៍នេះ សេចក្តីប្រកាសជាសាកលរបស់អង្គការសហ-ប្រជាជាតិនៅឆ្នាំ១៩៨១ គ្រាន់តែចាប់ផ្តើមសាជាថ្មីនូវធម្ម-និយមជាទម្លាប់ដែលមានតាំងពីមុនមក ប្រឆាំងនឹងការធ្វើទុក្ខបុកម្នេញលើសាសនា ។

មានន័យថា ទោះបីជាច្បាប់កម្ពុជាការពារតែព្រះសង្ឃកាន់ព្រះពុទ្ធសាសនាឲ្យចាកផុតពីការធ្វើទុកបុកម្នេញលើសាសនាគិតត្រឹមឆ្នាំ១៩៧៥យ៉ាងណាក៏ដោយ ក៏នៅមានទស្សនៈរណ៍ដ៏មាំមួយលើកឡើងថា ច្បាប់ទម្លាប់អន្តរជាតិហាមប្រាមមិនឲ្យមានការរើសអើងសាសនាតាមទម្រង់ផ្សេងៗដែលធ្វើឡើងដោយបក្សកុម្មុយនិស្តកម្ពុជា ។ ព្រះរាជអាជ្ញាប្រហែលជានឹងទាញហេតុផលបែបនេះក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ក៏ប៉ុន្តែការទទួលយករបស់តុលាការយ៉ាងណាៗនោះមិនទាន់មានលក្ខណៈប្រាកដប្រជានៅឡើយទេ ។ នៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ទាំងច្បាប់កម្ពុជាទាំងច្បាប់អន្តរជាតិ ពិតជាគ្មានលក្ខណៈច្បាស់លាស់ទេក្នុងការធានាថា គ្រប់ទម្រង់នៃការធ្វើទុក្ខបុកម្នេញលើសាសនាត្រូវបានហាមប្រាម ។

### អំពើតម្រូវឲ្យមានៈ និយមន័យនៃការធ្វើទុក្ខបុកម្នេញលើសាសនា

អំពើ"ធ្វើទុក្ខបុកម្នេញលើសាសនា"មិនទាន់មាននិយមន័យជាក់លាក់ណាមួយនៅឡើយទេ តាមច្បាប់អន្តរជាតិ ប៉ុន្តែពាក្យនេះគ្របអំពើធ្វើបាបរាប់ចាប់ពីការបំបាត់រហូតដល់ការបដិសេធមិនឲ្យទទួលសិទ្ធិជាពលរដ្ឋ ។ ឧទាហរណ៍តុលាការនូរិមប៊ឺកឲ្យនិយមន័យទៅលើ"ការធ្វើទុកបុកម្នេញលើសាសនា"ថារួមមានការចាប់ខ្លួន ការឃុំខ្លួន ការវាយដំ ទារុណកម្ម ការរឹបអូសទ្រព្យសម្បត្តិ ការនិរទេស ការបង្ខំឲ្យធ្វើពលកម្ម ការបដិសេធមិនព្រមផ្តល់សិទ្ធិប្រកបអាជីព និងរៀបការដោយសេរី ឬមិនឲ្យបន្តការសិក្សា និង ការសម្លាប់ ។ ស៊ីវ វ៉ាន់ន័រ និង ចេសិន អាប្រាម

អះអាងថា ការធ្វើទុក្ខបុកម្នេញលើសាសនាប្រហែលជារួមបញ្ចូលអំពើផ្សេងពីនេះទៀត ដូចជាការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន និង ការបិទគ្រឹះស្ថានសាសនា ។

ការឲ្យនិយមន័យតាមច្បាប់អន្តរជាតិទៅលើពាក្យ “ធ្វើទុកបុកម្នេញលើសាសនា” ប្រហែលជាផ្តល់នូវការបង្ហាញផ្លូវដ៏ល្អបំផុតទៅលើរបៀបក្នុងការកំណត់ “បទល្មើស” ប្រឆាំងនឹងជីវិតព្រះសង្ឃ ឬជីវិតបុគ្គល ។ ប៉ុន្តែតុលាការខ្មែរក្រហមនឹងមានអានុភាពខ្លាំងក្នុងការបកស្រាយច្បាប់ទាក់ទងនឹងអំពើដែលតម្រូវឲ្យមានចំពោះការធ្វើទុក្ខបុកម្នេញលើសាសនា ពីព្រោះទាំងច្បាប់អន្តរជាតិនិងករណីយុត្តិសាស្ត្រនៅក្នុងតុលាការក្នុងស្រុក ផ្តល់នូវការណែនាំយ៉ាងមាំទាំអំពីតម្រុយក្នុងការអានច្បាប់ទាំងអស់នេះ ។

ផ្អែកទៅលើការគិតទៅតាមផ្លូវច្បាប់វិញ ទំហំនៃអំពើដែលតម្រូវឲ្យមានដើម្បីឲ្យក្លាយទៅជាការធ្វើទុកបុកម្នេញលើសាសនាគឺពិតជាមានសារសំខាន់ពិសេសខ្លាំងណាស់ ។ ដើម្បីឈានដល់សេចក្តីសម្រេចប្រកបដោយយុត្តិធម៌ តុលាការខ្មែរក្រហមត្រូវតែអនុលោមតាមគោលការណ៍ច្បាប់ដែលស្ទើរតែក្លាយជាគោលការណ៍សាកលទៅហើយនោះ ពោលគឺគោលការណ៍ “*nullem criman sine lege*” ដែលមានន័យថា បុគ្គលទាំងឡាយមិនអាចត្រូវកាត់ឲ្យជាប់ទោសពីបទល្មើសណាមួយដែលមិនមែនជាបទល្មើសនៅពេលប្រព្រឹត្តបានឡើយ ។ ដូច្នេះ ការឲ្យនិយមន័យមិនច្បាស់លាស់ទៅលើបទល្មើសអាចរំលោភទៅលើសិទ្ធិរបស់ចុងចោទខ្មែរក្រហម ។

ផ្ទុយមកវិញ ការឲ្យនិយមន័យចង្អៀតចង្អល់ពេកនាំឲ្យបរាជ័យក្នុងការផ្តល់នូវយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ យោងតាមដំណើររឿងប្រវត្តិសាស្ត្រ និងឯកសារដែលមានស្រាប់ឃើញថា ថ្នាក់ដឹកនាំនិងកម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាបានប្រព្រឹត្តអំពើប្រទូសរ៉ាយប្រឆាំងនឹងបព្វជិតកាន់ព្រះពុទ្ធសាសនា ប៉ុន្តែអ្នកទាំងនោះក៏បានធ្វើទុក្ខបុកម្នេញលើបព្វជិតមិនកាន់ព្រះពុទ្ធសាសនាដែរ ដូចជាឥស្លាមសាសនិកនិងគ្រិស្តសាសនិកក្នុងអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ប្រជាពលរដ្ឋកម្ពុជាត្រូវបានធ្វើឃាត ចាប់ដាក់គុក ឲ្យធ្វើការទាំងបង្ខិតបង្ខំនិងមិនទទួលបាននូវសិទ្ធិពលរដ្ឋ និងសេរីភាព ។ ទង្វើបែបនេះគឺជាផ្នែកមួយនៃយុទ្ធនាការរបស់របប ប៉ុល ពត ក្នុងការលុបបំបាត់សាសនា ។

ប្រសិនបើតុលាការខ្មែរក្រហមឲ្យនិយមន័យចង្អៀត ឬកំណត់ថា ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមការពារត្រឹមតែបព្វជិតកាន់ព្រះពុទ្ធសាសនា នោះការរំលោភបំពានដោយមូលហេតុសាសនារបស់របបកម្ពុជាប្រជាធិបតេយ្យអាចនឹងចូលក្នុងបទល្មើសប្រភេទផ្សេងពីនេះទៀត ដូចជាអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាដើម ។ ក៏ប៉ុន្តែ ការធ្វើទុក្ខបុកម្នេញមួយចំនួនមិនចូលជាបទល្មើសផ្សេងៗទៀតដោយពេញលេញទេ ហើយដោយសារការឲ្យនិយមន័យចង្អៀតទៀតនោះ ការរំលោភបំពានខ្លះអាចនឹងមិនទទួលការផ្តន្ទាទោសឡើយ ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងមានអំណាចសំខាន់ណាស់ក្នុងការបកស្រាយទំហំនៃដែនសមត្ថកិច្ចរបស់ខ្លួន ហើយបទល្មើសនានាដែលស្ថិតនៅក្រៅដែនសមត្ថកិច្ចនោះនឹងត្រូវកាត់សេចក្តីនៅកន្លែងផ្សេងទៀត ប្រសិនបើមាន ។

## ចេតនាដែលតម្រូវឲ្យមាន

បន្ថែមពីលើអំពើដែលតម្រូវឲ្យមានដូចដែលពិភាក្សាខាងលើនេះ ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញលើសាសនាតម្រូវថាចុងចោទបានធ្វើទុក្ខបុកម្នេញមកលើជនរងគ្រោះដោយចេតនាដោយហេតុផលគោរពប្រតិបត្តិសាសនា ឬជំនឿសាសនា ។ អត្ថបទច្បាប់នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ចែងថា ចេតនាក្នុងកម្រិតបឋមទូទៅ ចាំបាច់ត្រូវតែមាន ។ នៅពេលដែលអំពើកើតឡើងនៅក្នុងពេលបព្វជិតថ្វាយបង្គំសុំសីល អំពើនោះគឺត្រូវតែធ្វើឡើងដោយការគ្រោងទុកជាមុន មានន័យថា ចុងចោទពិតជាបានដឹងថាជនល្មើសកំពុងតែវាយប្រហារមកលើព្រះសង្ឃនៅពេលថ្វាយបង្គំសុំសីល ។ នៅពេលដែលការធ្វើទុក្ខបុកម្នេញលើសាសនាកើតឡើងក្រៅវង្វង់នៃការគោរពប្រតិបត្តិសាសនារបស់ព្រះសង្ឃ (យើង) ត្រូវបង្ហាញថា ចុងចោទពិតជាបានធ្វើទុក្ខបុកម្នេញមកលើជនរងគ្រោះដោយមូលហេតុគោរពប្រតិបត្តិសាសនា ។ ក្នុងករណីដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទទួលយកនូវនិយមន័យទូលាយជាងនេះចំពោះបទឧក្រិដ្ឋនេះ

តម្រូវការចេតនាដដែលនេះគឺទំនងជាយកជាសំអាងបានសម្រាប់ជនរងគ្រោះក្រៅពីបព្វជិតកាន់ព្រះពុទ្ធសាសនា ។

## បង្ហាញឲ្យឃើញថាជាការធ្វើទុក្ខបុកម្នេញលើសាសនា

ដើម្បីបង្ហាញថា អតីតមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាមានទោសពីបទធ្វើទុក្ខបុកម្នេញលើសាសនា ចាំបាច់ត្រូវមានភស្តុតាងទាំងការប្រព្រឹត្ត(អំពើ) និងចេតនា ។ ញត្តិរបស់អ្នកនៅរស់ និងអត្ថបទសម្ភាសន៍ជាច្រើនប្រមូលបានពីកន្លែងនានានៅទូទាំងប្រទេសកម្ពុជា បញ្ជាក់ថា ការគោរពប្រតិបត្តិសាសនាព្រះពុទ្ធ (និងឥស្លាម) ត្រូវបានហាមឃាត់ វិហារត្រូវបានកម្ទេច ហើយលោកសង្ឃត្រូវបានផ្សឹក ឬបើមិនដូច្នោះទេ ត្រូវបានរំលោភបំពាន ។ ឯកសាររបស់តុលាការប្រជាជនបដិវត្តន៍ដែលកាត់ទោស ប៉ុល ពត និង អៀង សារី បង្ហាញពីដំណើររឿងរបស់ជនរងគ្រោះដែលនៅរស់ជាច្រើនដែលបានមកពីប្រភពផ្សេងៗ បើទោះបីជាបញ្ហានៃភាពលម្អៀងផ្នែកនយោបាយធ្វើឲ្យខូចដល់តម្លៃភស្តុតាងរបស់ខ្លួនក៏ដោយ ។ សរុបមក គំរូភស្តុតាងឯកសារដែលមានសព្វថ្ងៃបង្ហាញនូវការរំលោភបំពានជាច្រើនករណីប្រឆាំងនឹងព្រះសង្ឃកាន់ព្រះពុទ្ធសាសនានិងសហគមន៍សាសនានានា ។

ប្រសិនបើសន្មត់ថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក៏បានគិតគូរទៅលើការធ្វើទុក្ខបុកម្នេញលើបុគ្គលមិនកាន់ព្រះពុទ្ធសាសនានោះ ប្រវត្តិរូប ចម្លើយសារភាព និងអត្ថបទកិច្ចសម្ភាសន៍នានាដែលមានស្រាប់រៀបរាប់ពីការធ្វើទុក្ខបុកម្នេញពីសំណាក់បក្សកុម្មុយនិស្តកម្ពុជាមកលើសាសនិកឥស្លាម ។ ឧទាហរណ៍ អត្ថបទកិច្ចសម្ភាសន៍ផ្តល់នូវភស្តុតាងបង្ហាញថា នៅឆ្នាំ ១៩៧៦ បក្សកុម្មុយនិស្តកម្ពុជាបានហាមប្រាមមិនឲ្យតមបាយ និងមិនឲ្យសំយ៉ាំង ។ អត្ថបទកិច្ចសម្ភាសន៍ ញត្តិ និងឯកសារនានាបន្សល់ទុកដោយតុលាការឆ្នាំ១៩៧៩ដែលមានការចម្រូងចម្រាស់ក៏ផ្ទុកទៅដោយភស្តុតាងបង្ហាញពីនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជានៅខេត្តកំពង់ចាម និងកន្លែងផ្សេងៗទៀត ពោលគឺការបង្ខំឲ្យជនជាតិចាមបរិភោគសាច់ជ្រូក ចិញ្ចឹមជ្រូក និងឲ្យយកក្រដាសគម្ពីរកូរអានធ្វើជាក្រដាសបង្គន់ ។

ទោះបីជាបព្វជិតកាន់ព្រះពុទ្ធសាសនា និង ក្រុមសាសនាផ្សេងៗទៀតត្រូវបានធ្វើទុក្ខបុកម្នេញយ៉ាងប្រត្យក្សនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យយ៉ាងណាក៏ដោយ វានៅតែជាការចាំបាច់ក្នុងការបង្ហាញឲ្យឃើញថាការរំលោភបំពានដែលលើកឡើងខាងលើត្រូវបានធ្វើឡើងដោយមូលហេតុសាសនា ។ មានភស្តុតាងបញ្ជាក់ថា មេដឹកនាំកំពូលៗមានចេតនាចង់ធ្វើទុក្ខបុកម្នេញលើក្រុមសាសនា ជាពិសេសបព្វជិតកាន់ព្រះពុទ្ធសាសនា ។ មាត្រា ២០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៥ ចែងថា "...មិនអនុញ្ញាតឲ្យមានសាសនាប្រតិកិរិយាដែលបំផ្លាញកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនកម្ពុជាដាច់ខាត" ។ "សាសនាប្រតិកិរិយា"មិនត្រូវបានឲ្យនិយមន័យច្បាស់លាស់ទេ ប៉ុន្តែភស្តុតាងក្រោយៗមកបញ្ជាក់ថា ព្រះពុទ្ធសានា ឥស្លាមសាសនា និង គ្រិស្តសាសនា គឺជាមុខសញ្ញា ។

អត្ថបទកិច្ចសម្ភាសន៍របស់លោក ប៉ែន យៀវនិន ជាមួយអតីតកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យមួយចំនួនដូចជា ហេង សំរិន, សិន សុង និង គុណ ឆាយ បញ្ជាក់ថា នៅក្នុងមហាសន្និបាតបក្សក្នុងខែឧសភា ឆ្នាំ១៩៧៥ មេដឹកនាំកំពូលនៃបក្សកុម្មុយនិស្តកម្ពុជាបានបញ្ជាឲ្យកូនចៅ"បោសសម្អាត" ឬ"ផ្សឹក" ឬ"សម្លាប់" ព្រះសង្ឃ ។ យោងតាមសម្តីរបស់ ហេង សំរិន បានឲ្យដឹងថា ប៉ុល ពត និង នួន ជា ក៏បាននិយាយថា ព្រះសង្ឃគឺជា "វណ្ណៈពិសេស" ជាវណ្ណៈដ៏សំខាន់ក្នុងការប្រយុទ្ធ ។ ប៉ុល ពត និង នួន ជា ទទូចលែងឲ្យមានព្រះសង្ឃ និង វិធីប្រពៃណីសាសនាផ្សេងៗ និង មិនឲ្យមានវត្តអារាមហើយអ្នកទាំងពីរបានធ្វើការសរុបសេចក្តីនៅក្នុងសេចក្តីណែនាំនានាដែលមានន័យថា "លែងឲ្យមានសាសនាទៀតហើយ" ។ ឆ្នាំបន្ទាប់មក នៅត្រង់ចំណុចទី៦ នៃសេចក្តីសម្រេចឆ្នាំ១៩៧៦ មជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជាបានចេញបញ្ជាឲ្យ"កងកម្លាំងប្រដាប់អាវុធកម្ទេច"វិហារកាតូលិក ។

ភស្តុតាងដែលលើកមកពិភាក្សាខាងលើនេះបង្ហាញនូវចេតនាយ៉ាងប្រត្យក្សរបស់មេដឹកនាំមជ្ឈិមនៃបក្សកុម្មុនិស្តកម្ពុជាក្នុងការធ្វើទុក្ខបុកម្នេញលើព្រះសង្ឃកាន់ព្រះពុទ្ធសាសនា និងក្រុមសាសនាផ្សេងៗទៀត ។ ដោយសារតែភាគច្រើននៃកម្មាភិបាលដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានចូលរួមក្នុងមហា-សន្និបាតបក្សឆ្នាំ១៩៧៥ ព្រមជាមួយនឹងការពិតដែលថាគ្មាន

ភ័ស្តុតាងបញ្ជាក់ថា ថ្នាក់ដឹកនាំទាំងនោះមានការខ្វែងយោបល់ទៅនឹងសេចក្តីណែនាំរបស់បក្សកុម្មុយនិស្តកម្ពុជាទេ ។ ព្រះរាជអាជ្ញាមុនពេលតុលាការកើតឡើងគួរតែអាចបង្ហាញឲ្យឃើញថាភាគច្រើន (ហើយប្រហែលជាទាំងអស់ផងក៏មិនដឹង) នៃថ្នាក់ដឹកនាំបក្សកុម្មុនិស្តកម្ពុជាពិតជាបានបំពេញនូវតម្រូវការចេតនាពីបទធ្វើទុក្ខបុកម្នេញលើសាសនា ។ សូម្បីតែអ្នកដែលមិនបានបញ្ជាដោយផ្ទាល់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើទុកបុកម្នេញលើសាសនាក៏ដោយ ក៏ទំនងជាត្រូវទទួលខុសត្រូវតាមច្បាប់នៃការទទួលខុសត្រូវជាខ្សែសង្វាក់បញ្ជាពីបទបានដឹងអំពីសេចក្តីណែនាំរបស់បក្សនិងការអនុវត្តជាក់ស្តែង ហើយមិនបានចាត់វិធានការទប់ស្កាត់ ។

## សេចក្តីសន្និដ្ឋាន

តាមរយៈភ័ស្តុតាងដែលមានស្រាប់ ព្រះរាជអាជ្ញាទាំងឡាយគួរតែអាចបង្កើតនូវករណីបទល្មើសរបស់អតីតមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាពីបទធ្វើទុក្ខបុកម្នេញលើសាសនាក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩ ។ ក៏ប៉ុន្តែដូចដែលអត្ថបទនេះបានលើកឡើងត្រួសៗហើយថា ទំហំនៃបទឧក្រិដ្ឋដូចដែលបានចែងនៅក្នុងច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមគឺប្រកបដោយការមន្ទិលសង្ស័យខ្លាំងណាស់ ។ ការរំលោភបំពានទៅលើបព្វជិតកាន់ព្រះពុទ្ធសាសនា ប្រាកដជានឹងត្រូវវិនិច្ឆ័យបាន ប៉ុន្តែលក្ខណៈនៃការរំលោភបំពាននោះវាអាស្រ័យដោយការឲ្យនិយមន័យរបស់តុលាការខ្មែរក្រហមផ្ទាល់តែម្តងថា តើអំពើអ្វីខ្លះដែលចូលក្នុងបទ“ធ្វើទុក្ខបុកម្នេញលើសាសនា” ។ ការកាត់ឲ្យជាប់ទោសពីបទធ្វើទុក្ខបុកម្នេញលើបុគ្គលមិនមែនជាពុទ្ធសាសនិក ដូចជាឥស្លាមសាសនិក គ្រិស្តសាសនិក និង បុគ្គលជំពូកផ្សេងទៀតនឹងពឹងផ្អែកយ៉ាងខ្លាំងទៅលើការបកស្រាយច្បាប់ពីសំណាក់ចៅក្រមទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងច្បាប់ទម្លាប់អន្តរជាតិ ។ ការសន្និដ្ឋានទាំងនេះគឺចង់បង្ហាញថា ការជំនុំជម្រះក្តីអតីតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនឹងមិនត្រឹមតែអាស្រ័យទៅលើអង្គហេតុដែលមានការប្រទាក់ប្រទងជំពាក់ជាក់វិនគ្នាប៉ុណ្ណោះទេតែថែមទាំងការដោះស្រាយបញ្ហាស្មុគស្មាញនៃអង្គច្បាប់ទៀតផង ។

**ចន ឆរធីអារី**





វត្តកោះគរ នៅខេត្តតាកែវ

# មហាអំណាចភ្លែងឬកនិងតុលាការខ្មែរក្រហម



ប៉ុន្មានឆ្នាំកន្លងទៅនេះ ភាគច្រើននៃប្រព័ន្ធផ្សព្វផ្សាយដែលលើកឡើងអំពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានផ្តោតទៅលើការចរចារវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ។ ការផ្តោតការយកចិត្តទុកដាក់ទៅលើមន្ត្រីអង្គការសហប្រជាជាតិមិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេ ដោយហេតុថាមន្ត្រីទាំងនោះភាគច្រើនជាអ្នកធ្លាប់បានចូលរួមជាលក្ខណៈអន្តរជាតិនៅក្នុងដំណើរការបង្កើតតុលាការ ។ ក៏ប៉ុន្តែអង្គទូតរបស់អង្គការសហប្រជាជាតិគឺគ្រាន់តែជាតំណាងជួរមុខរបស់រដ្ឋការកណ្តាលអន្តរជាតិដែលទទួលរងឥទ្ធិពលដ៏ធ្ងន់ពីសំណាក់មហាអំណាច ។ អត្ថបទនេះចង់លើកឡើងអំពីតួនាទីរបស់រដ្ឋជាសមាជិកដែលមានអំណាចបំផុតហើយដែលត្រូវបានប្រើប្រាស់ក្នុងការជំរុញ និងយកជើងរាទឹកមិនឲ្យដំណើការបង្កើតតុលាការឆ្ពោះទៅមុខ ។



ការិយាល័យទទួលបន្ទុកផ្នែកច្បាប់នៃអង្គការសហប្រជាជាតិនិងប្រមុខដឹកនាំបច្ចុប្បន្ន (លោក ហេន កូរ៉េល) មិនមែនត្រឹមតែជាឈ្នាន់របស់មហាអំណាចប៉ុណ្ណោះទេ ប៉ុន្តែបុគ្គលិកលក្ខណៈនិងប្រព័ន្ធរបស់អង្គការសហប្រជាជាតិមានឥទ្ធិពលយ៉ាងច្បាស់ក្រឡែតទៅលើដំណើរការចរចាជាមួយរដ្ឋាភិបាលកម្ពុជាទៀតផង គឺមិនខុសអំពីអ៊ីដែលជានយោបាយការិយាល័យនិយម នៅក្នុងអង្គការសហប្រជាជាតិនោះទេ ។ ប៉ុន្តែទោះជាមានការិយាល័យនិយមយ៉ាងនេះក៏ដោយក៏តំណាងចរចារបស់អង្គការសហប្រជាជាតិមិនដែលដំណើរការដោយគ្មានពិចារណាអំពីផលប្រយោជន៍របស់មហាអំណាចបានដែរ ។ ជាក់ស្តែងក្នុងករណីកម្ពុជា ដែលជាទីសម្រាប់ការប្រកួតប្រជែងយុទ្ធសាស្ត្រនយោបាយនិងមនោគមវិជ្ជានោះ នយោបាយរបស់មហាអំណាចបានបន្សល់ទុកនូវស្លាកស្នាមប្រវត្តិសាស្ត្រច្បាស់បំផុតនៅលើនយោបាយរបស់អង្គការសហប្រជាជាតិ ។ ភាពទាល់ច្រកដោយសារសង្គ្រាមត្រជាក់នៅទសវត្សរ៍ទី៨០ បានបញ្ចប់ទៅដោយវៀតណាមដកកងកម្លាំងប្រដាប់អាវុធ និងមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសក៏ពិតមែន ប៉ុន្តែនយោបាយបច្ចុប្បន្នជុំវិញបញ្ហាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបង្ហាញថា កម្ពុជានៅតែជាកម្មវត្ថុរបស់រដ្ឋជាសមាជិកដ៏មានអំណាចក្រាសឃ្មឹកនៅលើពិភពលោកដដែល ។

ចាប់តាំងពីសូវៀតដកខ្លួនថយពីតណ្ហចិននៅចុងទសវត្សរ៍ទី៨០មក តួឯកដែលមានអំណាចបំផុតខាងយោធានិងនយោបាយនៅដីគោកអាស៊ី-អាគ្នេយ៍ គឺប្រទេសចិន និង សហរដ្ឋអាមេរិក ។ នៅក្នុងអាណត្តិទីពីររបស់រដ្ឋការលោកប្រធានាធិបតីប៊ីលក្លីនតុន រដ្ឋាភិបាលសហរដ្ឋអាមេរិកបានជំរុញយ៉ាងខ្លាំងក្លា (ទោះបីជាមិនបានជំរុញឲ្យអស់ទំហឹងក៏ដោយ) ឲ្យមានតុលាការកាត់ទោសខ្មែរក្រហម ក្នុងខណៈដែលប្រទេសចិនប្រឆាំងយ៉ាងដាច់អហង្ការនូវការជំនុំជម្រះក្តីអតីតមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ។ តុលាការខ្មែរក្រហមដែលស្នើឡើងនេះ បានក្លាយទៅជាមុខសញ្ញាមួយក្នុងចំណោមមុខសញ្ញាជាច្រើនផ្សេងទៀតដែលទីក្រុងប៉េកាំងនិងទីក្រុងវ៉ាស៊ីនតោន ក្រាញនៀលលើបញ្ហាអធិបតេយ្យជាតិនិងសិទ្ធិមនុស្ស ។ ក្រោមការដឹកនាំរបស់រដ្ឋការប្រធានាធិបតី ប៊ូស ជាពិសេសចាប់តាំងពីការវាយប្រហារនៅថ្ងៃទី១១ ខែកញ្ញានោះមក ការគាំទ្ររបស់សហរដ្ឋអាមេរិកចំពោះបញ្ហាតុលាការខ្មែរក្រហមបានថមថយចុះ ។ ចំណែកឯសាធារណរដ្ឋប្រជាមានិតចិននៅតែជំទាស់យ៉ាងដាច់អហង្ការដដែល ។ ដោយប្រទេសដ៏ធំបំផុតនៅលើពិភពលោកប្រឆាំងនឹងតុលាការ ហើយប្រទេសមានអំណាចបំផុតមិនសូវជាយកចិត្តទុក

ដាក់នោះ ការវិនិច្ឆ័យទោសដែលគួរឲ្យទុកចិត្តបានទៅលើមេដឹកនាំបក្សកុម្មុនិស្តកម្ពុជាគឺពិតជាថយចុះយ៉ាងប្រត្យក្សដែរ ។

## ការជំទាស់របស់ប្រទេសចិន



ប្រទេសចិនកន្លងមកក៏ដូចជាបច្ចុប្បន្ន នៅតែនិយាយជំទាស់ដោយចំហ មិនទទួលយកតុលាការមួយដែលរៀបចំចាត់ចែង ឬគ្រប់គ្រងដោយអន្តរជាតិសម្រាប់កាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ។ ការប្រឆាំងជំទាស់របស់ប្រទេសចិន គឺមានលក្ខណៈច្បាស់លាស់ ហើយត្រង់ៗតែម្តង ដោយសំអាងថា តុលាការដែលរៀបចំឡើងដោយអន្តរជាតិនឹងរំលោភលើអធិបតេយ្យជាតិរបស់ប្រទេសកម្ពុជា ។ អាចមានហេតុផលមួយចំនួនដែលធ្វើឲ្យប្រទេសចិនប្រឆាំងជំទាស់នឹងតុលាការអន្តរជាតិនេះ ។ ទីមួយ ការគាំទ្រយ៉ាងជិតដល់របស់ចិនចំពោះបក្សកុម្មុយនិស្តកម្ពុជា នៅអំឡុងឆ្នាំ១៩៧៥-១៩៧៩ ធ្វើឲ្យឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមមានលក្ខណៈប៉ះពាល់ខ្លាំងក្លាដល់ទីក្រុងប៉េកាំង ។ ការជំនុំជម្រះទោសមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា សឹងតែច្បាស់ថា ជាការបើកកកាយឡើងវិញនូវការពិភាក្សាអំពីតួនាទីរបស់ចិនក្នុងការជួយទំនុកបំរុងដល់ខ្មែរក្រហមនិងធ្វើឲ្យចិនសង្កៀររន្ធត្រចៀកដោយសារការរិះគន់ពីសំណាក់អន្តរជាតិទៀតផង ។

ទីពីរទៀត តុលាការអន្តរជាតិច្បាស់ជាទាក់ទាញការយកចិត្តទុកដាក់ទៅលើលិទ្ធិម៉ៅនិយម និងកុម្មុយនិស្តនិយមនៅជំនាន់ប៉ុល ពត ។ ការជំនុំជម្រះក្តីនេះអាចផ្តល់ឱកាសដល់មហាអំណាចលោកខាងលិច និងអ្នកប្រឆាំងជាជនកុម្មុយនិស្ត វាយប្រហារទៅលើមនោគមវិជ្ជាកុម្មុយនិស្តនិងគំរាមដល់កិត្យានុភាពមនោគមន៍វិជ្ជារបស់ថ្នាក់ដឹកនាំបក្សកុម្មុយនិស្តចិននៅទីក្រុងប៉េកាំង ។ ចំណុចស្រដៀងគ្នាមួយចំនួនរវាង«មហាលោតផ្លោះមហាអស្ចារ្យ»របស់ម៉ៅ ពោលគឺបដិវត្តន៍វប្បធម៌ឆ្នាំ១៩៦៦-១៩៦៨ និង ផែនការ«ឆ្នាំសូន្យ»របស់អង្គការខ្មែរក្រហម គឺពិតជាសំខាន់ដែលអ្នកសង្កេតការណ៍ទាំងក្នុងនិងក្រៅប្រទេសមិនអាចឲ្យរំលងបាន ។

មូលដ្ឋានទីបីដែលធ្វើឲ្យចិនជំទាស់ដល់តុលាការនោះគឺថា តុលាការក្រោមការចាត់ចែងរបស់អន្តរជាតិ(និងជាពិសេសលោកខាងលិច) នឹងបង្ហាញឲ្យឃើញពីការអះអាងអំពីគោលការណ៍ថា ការរំលោភសិទ្ធិមនុស្សជួនកាលជាការបង្ហាញនូវហេតុផលរបស់ប្រទេសអ្នកមានស្តុកស្តម្ភក្នុងការរំលោភទៅលើ«ដែនអធិប-តេយ្យភាព»របស់ប្រទេសកំពុងអភិវឌ្ឍ ។ ជម្លោះដែលកើតឡើងសាជាថ្មីរវាងចិននិងសហរដ្ឋអាមេរិកព្រមទាំងប្រទេសផ្សេងៗទៀតទាក់ទងនឹងសិទ្ធិមនុស្សជាចំណុចដ៏សំខាន់ទាក់ទិនដល់បញ្ហាខាងលើ ជាពិសេសនៅពេលដែលតុលាការខ្មែរក្រហមអាចនឹងចេញរូបរាងឡើងនៅក្បែរប្រទេសចិន គឺទ្វីបអាស៊ី-អាគ្នេយ៍ ។ ទីក្រុងប៉េកាំងធ្លាប់បានយល់ថា រឿងសិទ្ធិមនុស្សលោកខាងលិចមានភាពស្តើងរហៀរ ឬសើរៗចំពោះនយោបាយថ្មី និងមិនម្យៀង ហើយទីក្រុងប៉េកាំងមានមន្ទិលសង្ស័យទៅលើដំណើរការដែលជាការចង្អុលបង្ហាញអំពីភាពងាយទទួលរងនូវការរិះគន់លើបញ្ហាសិទ្ធិមនុស្ស ។

ចំណុចចុងក្រោយមួយទៀតគឺថា គំនិតបង្កើតតុលាការកាត់ទោសខ្មែរក្រហមជាលក្ខណៈអន្តរជាតិដែលមានឥទ្ធិពលយ៉ាងខ្លាំងពីលោកខាងលិចធ្វើឲ្យខាតបង់ចំពោះតុល្យភាពអំណាចការទូតរបស់ចិននៅលើដែនដីអាស៊ី-អាគ្នេយ៍ ។ ទីក្រុងប៉េកាំងចាត់ទុកដីគោកនៅអាស៊ី-អាគ្នេយ៍ថាជាតំបន់ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្លួនជាប្រពៃណីយូរលង់ណាស់មកហើយ ហើយយល់ឃើញថា អំណាចដ៏ខ្លាំងក្លារបស់លោកខាងលិចនៅក្នុងតំបន់នេះគឺជា«អនុត្តរភាព» ឬប្រមាថដល់បំណងដ៏ស្របច្បាប់របស់ខ្លួនមកលើតំបន់នេះ ។ ជាងនេះទៅទៀត ទីក្រុងប៉េកាំងសង្ស័យថា ការចូលរួមរបស់លោកខាងលិចតាមរូបភាពយោធាសេដ្ឋកិច្ចនិងការទូតនៅក្នុងតំបន់នេះបង្កើតបានជាយុទ្ធសាស្ត្រថ្មីមួយដែលដឹកនាំដោយសហរដ្ឋអាមេរិកក្រោយពីសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ដើម្បីរក្សានូវការគ្របដណ្តប់របស់អាមេរិកទៅលើផ្លូវសមុទ្រអាស៊ី-អាគ្នេយ៍ដ៏សំខាន់ ផ្តល់កម្រៃច្រើននិងជាយុទ្ធសាស្ត្រសេដ្ឋកិច្ច ។ ការបង្កើតតុលាការខ្មែរក្រហមដែលដឹកនាំដោយលោកខាងលិចនឹងក្លាយជាសញ្ញាបញ្ជាក់ពីការបន្តភាពសំខាន់របស់អាមេរិកនៅក្នុងតំបន់ដែលគេឲ្យតម្លៃខាងយុទ្ធ-

សាស្ត្រនិងសេដ្ឋកិច្ចដែលចិនមានអារម្មណ៍ថា ជារបស់ខ្លួនបើគិតពីប្រវត្តិសាស្ត្រ វប្បធម៌ និង ភូមិសាស្ត្រ ។

### ការស្ទាក់ស្ទើររបស់សហរដ្ឋអាមេរិក



តួនាទីរបស់សហរដ្ឋអាមេរិកនៅក្នុងការចរចាបង្កើតតុលាការកាន់តែមានលក្ខណៈមិនប្រាកដជាលំដាប់ ដោយសារតែគំនិតនៅទីក្រុងវ៉ាស៊ីនតោនមានលក្ខណៈខុសគ្នាស្រឡះពីគំនិតដែលសម្តែងចេញនៅទីក្រុងប៉េកាំង ។ ជាអន្តរជាតិ រដ្ឋាភិបាលសហរដ្ឋអាមេរិកបានគាំទ្រឥតងាករេចំពោះការបង្កើតតុលាការមួយក្រោមការត្រួតពិនិត្យជិតដល់របស់អន្តរជាតិ ។ ក៏ប៉ុន្តែទីក្រុងវ៉ាស៊ីនតោនគ្មានចេតនាចង់បញ្ចេញកម្លាំងការទូតពេញទំហឹងរបស់ខ្លួនប្រឆាំងនឹងទីក្រុងភ្នំពេញឲ្យនាំមកនូវតុលាការអន្តរជាតិ ឬតុលាការចម្រុះដោយមានការធានាឲ្យមានផ្ទៃផ្កាដែលអាចទទួលយកបានជាលក្ខណៈអន្តរជាតិឡើយ ។

ប្រសិនបើនិយាយថា ប្រទេសចិនបានធ្វើមិនឲ្យសម្រេចបាននូវការបង្កើតតុលាការតាមការប្រឆាំងជំទាស់របស់ខ្លួននោះ ក៏អាចនិយាយបានដែរថា សហរដ្ឋអាមេរិកបានរារាំងដំណើរការកាន់តែខ្លាំងជាងប្រទេសចិនតាមរយៈការគាំទ្រមិនគ្រប់គ្រាន់ ឬភាពអសកម្ម ។ នៅក្នុងខណៈដែលថ្នាក់ដឹកនាំនយោបាយ សកម្មជននិងអ្នកបោះឆ្នោតគាំទ្រដល់ការបង្កើតតុលាការជាលក្ខណៈអន្តរជាតិ ទីក្រុងវ៉ាស៊ីនតោនដូចជាពុំហ៊ានជំរុញបញ្ហានេះឲ្យបានខ្លាំងក្លា ។ ទង្វើនេះធ្វើឡើងដោយមានហេតុផលជាច្រើន ។ ទីមួយ ដូចជាចិនអ៊ីចឹងដែរ សហរដ្ឋអាមេរិកត្រូវបានរិះគន់យ៉ាងខ្លាំងអំពីសកម្មភាពរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាចាប់ផ្តើមពីការគាំទ្ររបបសាធារណរដ្ឋខ្មែរ(លន់ ណុល) និងយុទ្ធនាការទម្លាក់គ្រាប់បែកនៅឆ្នាំ១៩៧០-១៩៧៣រហូតដល់ការបន្តជួយភាគីបដិបក្ខកម្ពុជានៅក្នុងអំឡុងទសវត្សរ៍ទី៨០ នៅពេលដែលរដ្ឋាភិបាលសហរដ្ឋអាមេរិកគាំទ្ររដ្ឋាភិបាលចម្រុះត្រីភាគីកម្ពុជាប្រជាធិបតេយ្យដែលក្នុងនោះមានក្រុមខ្មែរក្រហម ។ ការជំនុំជម្រះក្តីអាចទាក់ទាញការចាប់អារម្មណ៍របស់អន្តរជាតិទៅលើនយោបាយសង្គ្រាមត្រជាក់របស់អាមេរិកនៅទឹកដីឥណ្ឌូចិន ហើយការផ្ទើះដំបៅចាស់សម័យសង្គ្រាមវៀតណាមធ្វើឲ្យមេដឹកនាំសហរដ្ឋអាមេរិកមានការញញើតខ្លាំងណាស់ ។ អ្នកគាំទ្រខាងគណបក្សសាធារណរដ្ឋនិយមរបស់រដ្ឋការ និច សុន ដែលបើកយុទ្ធនាការទម្លាក់គ្រាប់បែកក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៣ ពិតជាចាប់អារម្មណ៍ខ្លាំងណាស់ថា ការណ៍នេះនឹងបង្កើតឲ្យមានលទ្ធភាពផ្ទើះដំបៅចាស់នៅកម្ពុជាឡើងវិញជាក់ជាមិនខាន ។

ជាងនេះទៅទៀត មេដឹកនាំមួយចំនួនក្នុងទីក្រុងវ៉ាស៊ីនតោនគ្មានចេតនាចង់គាំទ្រដំណើរការណាមួយដែលអាចសាំទៅនឹងផលប្រយោជន៍ដល់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលជាគូបដិបក្ខនយោបាយរបស់សហរដ្ឋអាមេរិកនោះទេ ។ សមាជិកសភាអាមេរិកនិងរដ្ឋការប្រតិបត្តិជាច្រើនរូប សុទ្ធតែជាទាហានជើងចាស់ធ្លាប់ប្រឡូកសង្គ្រាមវៀតណាម ហើយភាគច្រើននៃអ្នកទាំងនោះធ្លាប់បានរស់នៅឆ្លងកាត់សម័យមួយដែលទីក្រុងមូស្គូ ទីក្រុងហាណូយនិងសម្ព័ន្ធមិត្តកម្ពុជាបានធ្វើជាសត្រូវស្លាប់រស់របស់ទីក្រុងវ៉ាស៊ីនតោនខាងផ្នែកយុទ្ធសាស្ត្រនិងមនោគមវិជ្ជា ។ មានមេដឹកនាំអាមេរិកដទៃទៀតប្រឆាំងជំទាស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយហេតុផលផ្សេងៗគ្នាដោយលើកឡើងនូវការចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្សនិងការប្រើអំណាចផ្តាច់ការ ។ សមាជិកព្រឹទ្ធសភាអាមេរិក ចេស៊ី ហែម និងសមាជិកសភា ដាណារ៉ូរ៉ាបាឃ័រ ថែមទាំងបានស្នើឡើងនូវដំណោះស្រាយមួយសុំឲ្យមានការកាត់ទោសនាយករដ្ឋមន្ត្រី ហ៊ុន សែន ពីបទឧក្រិដ្ឋកម្មសង្គ្រាមជាជាងកាត់ទោសមេដឹកនាំខ្មែរក្រហមដែលមានវ័យកាន់តែចាស់ទៅហើយនោះ ។

មេដឹកនាំសហរដ្ឋអាមេរិកដឹងខ្លួនទៀតថា ការជំរុញឲ្យមានតុលាការអន្តរជាតិត្រូវតែចំណាយការទាក់ទងតាមផ្លូវការទូត ។ ការប្រឆាំងនឹងប្រទេសចិន គឺជាការខាតបង់មួយ ។ ទីក្រុងវ៉ាស៊ីនតោនក៏ត្រូវព្រួយបារម្ភផងដែរអំពីឥទ្ធិពលនៃសកម្មភាពរបស់ខ្លួននៅតាមប្រទេសកំពុងអភិវឌ្ឍនានាដែលភ័យខ្លាចអាមេរិកធ្វើអន្តរាគមន៍ ។ រដ្ឋការលោកប្រធានាធិបតី ប៊ូស ហាក់មិនសូវមានសុឆន្ទៈចង់ពង្រីកធនធាននយោបាយទៅលើបញ្ហាមួយចំនួនដូចជាបញ្ហាខ្មែរក្រហមជាដើមចាប់តាំងពីមានការវាយប្រហារភេរវកម្មនៅសរទរដូវឆ្នាំ២០០១កន្លងមក ។ កម្មវិធីប្រឆាំងនឹងភេរវកម្ម

មានលក្ខណៈលុបលើបញ្ហាការទូតដែលចាត់ទុកមួយឡែកសិន ។ វាមិនខុសអ្វីពីករណីសង្គ្រាមត្រជាក់កាលពីទសវត្សរ៍ទី៨០ ទេ ដែលកាលនោះ ទីក្រុងវ៉ាស៊ីនតោនបានឲ្យអាទិភាពទៅលើការទាក់ទាញការគាំទ្រពីរដ្ឋាភិបាលបរទេសក្នុងការប្រយុទ្ធប្រឆាំងជាមួយក្រុមជីវពលជ្រុលនិយមឥស្លាម ។

ហេតុផលចុងក្រោយមួយទៀតគឺថាថ្នាក់ដឹកនាំសហរដ្ឋអាមេរិកដែលបញ្ចេញយោបល់ឥតសំចៃនៅក្នុងបញ្ហាបង្កើតតុលាការអន្តរជាតិ ក៏អាចមានបញ្ហាផងដែរនៅក្នុងសម័យមួយដែលទីក្រុងវ៉ាស៊ីនតោនបានក្លាយជាអ្នកទទួលការរិះគន់ខ្លាំងជាងគេបង្អស់នៅលើពិភពលោកទៅលើតុលាការព្រហ្មទណ្ឌអន្តរជាតិថ្មី ។ មេដឹកនាំនយោបាយអាមេរិកជាច្រើនរូបមានលក្ខខណ្ឌជំទាស់នានាជាមួយអង្គការសហប្រជាជាតិ ។ ជាពិសេសជាងនេះទៅទៀតមេដឹកនាំទាំងនេះជឿថា ការជំរុញឲ្យមានតុលាការអន្តរជាតិមិនយូរមិនឆាប់នឹងធ្វើឲ្យមេដឹកនាំនិងយោធាអាមេរិកងាយទទួលរងនូវការវិនិច្ឆ័យទោសដែលជំរុញតាមផ្លូវនយោបាយ ។ ទីក្រុងវ៉ាស៊ីនតោនត្រូវបានចោទប្រកាន់ជាទូទៅរួចទៅហើយថាជាអ្នកលាក់ពុតតាមរយៈជំហររបស់ខ្លួនចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយការជំរុញឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមវាហាក់ដូចជាកាន់តែបន្ថែមទៅលើការចោទប្រកាន់ទាំងនោះមួយកម្រិតទៀត ។

តាមការពិត មេដឹកនាំអាមេរិកនិងក្រុមសកម្មជនជាច្រើននៅតែតាំងចិត្តនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោសតាមរយៈតុលាការព្រហ្មទណ្ឌដែលរៀបចំចាត់ចែង ឬត្រួតពិនិត្យដោយអន្តរជាតិ ។ ក្រុមសិទ្ធិមនុស្សនិងសមាជិកសំខាន់ៗនៃគណបក្សទាំងពីរបានគាំទ្រតុលាការដែលស្នើឡើងនេះ ជាពិសេសគណបក្សប្រជាធិបតេយ្យបានផ្តល់នូវការគាំទ្រឥតងាករេនិងបញ្ចេញយោបល់ដោយឥតសំចៃ ។ ទោះជាយ៉ាងណាក៏ដោយជំហរជាទូទៅរបស់សហរដ្ឋអាមេរិកអាចត្រឹមបានតែចាត់ទុកថាមានលក្ខណៈផ្ទុយគ្នា ឬប្រទាញប្រទង់គ្នាប៉ុណ្ណោះ ។ ប្រទេសចិនបានធ្វើការបញ្ចុះបញ្ចូលអង្គការសហប្រជាជាតិនិងរដ្ឋធំៗមួយចំនួនទៀតឲ្យបញ្ចៀសកុំឲ្យមានតុលាការអន្តរជាតិ ។ ចំណែកឯសហរដ្ឋអាមេរិកវិញបញ្ចេញនូវសម្ពាធមួយដែលលាយឡំគ្នា រវាងការជំរុញជាលក្ខណៈរដ្ឋនិងជាលក្ខណៈឯកជនព្រមទាំងការប្រឆាំងជំទាស់ ។

## ជប៉ុននិងឥណ្ឌាដើរជំទើតជើង





ការមានយោបល់ផ្ទុយគ្នារបស់អាមេរិកគាំទ្រនិងការជំទាស់ដាច់អហង្ការរបស់ប្រទេសចិនចំពោះការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានទុកឱកាសឲ្យប្រទេសមានអំណាចផ្សេងទៀតឈានជើងចូលមកដើរតួនាទីកាន់តែសំខាន់ក្នុងការបង្កើតតុលាការនេះ ។ ជប៉ុន និង ឥណ្ឌា សុទ្ធតែបានបញ្ចេញឲ្យដឹងនូវការចាប់អារម្មណ៍របស់ខ្លួនមកលើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទោះបីជាមហាអំណាចនៅអាស៊ីទាំងពីរនេះបានលូកដៃដោយមានការប្រុងប្រយ័ត្នក៏ដោយ ។ ប្រទេសឥណ្ឌាមានចំណង់ខ្លាំងចង់កាន់កាប់នូវតួនាទីដឹកនាំខ្ពស់ជាងគេតាមផ្លូវការទូតនៅភូមិភាគអាស៊ី-អាគ្នេយ៍ ។ ជាក់ស្តែង ឥណ្ឌាបានពង្រឹងពង្រីកទំនាក់ទំនងជាមួយប្រទេសវៀតណាម ប្រទេសឥណ្ឌូនេស៊ីនិងតួឯកសំខាន់ៗមួយចំនួនទៀតនៅក្នុងតំបន់ ។ ការផ្តល់នូវការគាំទ្ររបស់ទីក្រុងញូវដេលីដល់តុលាការចម្រុះនេះ(ប្រសិនបើអង្គការសហប្រជាជាតិដកថយមិនចូលរួមជារៀងរហូត)នឹងបញ្ជាំងឲ្យឃើញពីចំណាប់អារម្មណ៍របស់ឥណ្ឌាក្នុងដំណើរការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់និងចង់មានមុខមាត់ខ្ពង់ខ្ពស់នៅក្នុងវិស័យការទូតនៅក្នុងភូមិភាគអាស៊ី-អាគ្នេយ៍ ។ ក៏ប៉ុន្តែថ្មីៗនេះ ឥណ្ឌាខ្វាយខ្វល់តែពីរឿងជម្លោះនៅកាស្មៀ ហើយរួញរាមិនចង់ធ្វើឲ្យរង្កៀសចិត្តដល់ទីក្រុងប៉េកាំងដែលជាសម្ព័ន្ធមិត្តរបស់ប៉ាគីស្ថានយូរយារណាស់មកហើយនោះ ។ ទីក្រុងញូវដេលីក៏មានការព្រួយបារម្ភដែរអំពីការភ្ជាប់សម្ព័ន្ធភាពសាជាថ្មីរបស់សហរដ្ឋអាមេរិកជាមួយប៉ាគីស្ថាន ហើយនឹងឈានទៅដោះស្រាយរឿងតុលាការខ្មែរក្រហមយ៉ាងប្រុងប្រយ័ត្នជៀសវាងមិនចាត់វិធានការទាំងឡាយណាដែលនឹងគំរាមកំហែងដល់ទំនាក់ទំនងដ៏សំខាន់ជាមួយទីក្រុងវ៉ាស៊ីនតោន ។

ប្រទេសជប៉ុនក៏សំដែងការចាប់អារម្មណ៍របស់ខ្លួនដូចគ្នានេះដែរ ពោលគឺចង់ផ្តល់ថវិកាដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ជប៉ុនថែមទាំងបានផ្តល់នូវការគាំទ្រឥតងាករេចំពោះដំណើរនីតិវិធីតុលាការក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយមិនខុសពីប្រទេសឥណ្ឌាទេគឺប្រទេសជប៉ុនត្រូវបានរារាំងដោយទំនាក់ទំនងរបស់ខ្លួនជាមួយរដ្ឋសំខាន់ៗមួយចំនួនដែលដើរតួយ៉ាងសកម្មនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ។ សម្ព័ន្ធភាពរវាងខ្លួននិងអាមេរិកនៅតែរក្សាទំនាក់ទំនងល្អខាងផ្នែកសន្តិសុខអន្តរជាតិ ហើយទីក្រុងតូក្យូកម្របានចាត់វិធានការតាមផ្លូវការទូតនៅក្នុងតំបន់ដែលអាចនឹងនាំដល់ភាពតានតឹងជាមួយទីក្រុងវ៉ាស៊ីនតោនណាស់ ។

ជប៉ុនក៏បានប្រយ័ត្នប្រយែងផងដែរ ក្នុងការផ្តើមគំនិតខាងការទូតនានាដែលធ្វើឲ្យអាក់អន់ចិត្តដល់ប្រទេសនានានៅទ្វីបអាស៊ីដែលនៅតែចងចាំនូវលទ្ធិចក្រពត្តិនិយមរបស់ជប៉ុននិង«មហាដែនដីវិបុលភាពនៅអាស៊ីខាងកើត» ជាក់ស្តែងដូចជាភាពរកាំរកូសដែលនៅតែបន្តមិនទាន់ចប់ ទាក់ទងទៅនឹងសៀវភៅប្រវត្តិសាស្ត្រនានា វិមានរំឭកសង្គ្រាមជប៉ុន និងកម្មវត្ថុផ្សេងៗទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះ ។ ការប្រឆាំងជំទាស់ដែលជប៉ុនជួបប្រទះនៅក្នុងការការពារភាពជាមេដឹកនាំខាងការទូតនៅអាស៊ី-អាគ្នេយ៍ គឺដូចជាឧទាហរណ៍ជាក់ស្តែងដែលលោក លី ក្វាន់យូ បានស្តែងឲ្យឃើញស្រាប់ ។ លោកធ្លាប់បានលាន់មាត់ថា ការឲ្យជប៉ុនចូលរួមនៅក្នុងបេសកកម្មថែរក្សាសន្តិភាពនៅកម្ពុជាក្នុងក្របខ័ណ្ឌអ៊ុនតាក់នោះគឺ«ដូចជាឲ្យសូកូឡាទៅអ្នកដឹកស្រាអ៊ីចឹង» ។ ភាពមន្ទិលសង្ស័យរបស់អាស៊ីទៅលើទីក្រុងតូក្យូជួយពន្យល់នូវហេតុផលដែលនាំឲ្យជប៉ុនពឹងផ្អែកយ៉ាងខ្លាំងទៅលើការគាំទ្រខាងហិរញ្ញវត្ថុ មិនមែនកម្លាំងយោធា ឬនយោបាយក្នុងការបញ្ចូលឥទ្ធិពលការទូតរបស់ខ្លួននៅទ្វីបអាស៊ីទេ ។ បញ្ហាតុលាការខ្មែរក្រហមមើលទៅដូចគ្នាបេះបិទ ។

និយាយដោយខ្លីទៅ ទាំងតូក្យូ និង ញូវដេលី សុទ្ធតែមានចំណាប់អារម្មណ៍ចង់បាននូវភាពជាអ្នកដឹកនាំខ្លាំងជាងគេនៅក្នុងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុន្តែប្រទេសទាំងពីរសុទ្ធតែមានការប្រុងប្រយ័ត្នមិនចង់ឲ្យមានភាពតានតឹងក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសចិន ឬសហរដ្ឋអាមេរិកឡើយ ។ ឥណ្ឌា និង ជប៉ុន ទំនងជាមិនអាចបន្តយុទ្ធនាការដាក់ឲ្យទទួលខុស


សមមិត្ត អៀង សារី

ត្រូវចំពោះមុខច្បាប់យកមួយឈ្នះដៃបានទេ ប្រសិនបើគ្មានភ្លើងបៃតង ឬភ្លើងសញ្ញាពណ៌លឿងពីទីក្រុងវ៉ាស៊ីនតោននោះ ។

### សេចក្តីសន្និដ្ឋានៈ មហាអំណាចច្របូកច្របល់



ជាសរុបមក ឥទ្ធិពលនៃនយោបាយមហាអំណាចមកលើការស្វែងរកការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់នៅកម្ពុជាមានលក្ខណៈច្របូកច្របល់ណាស់ ។ នៅក្នុងទសវត្សរ៍ទី៩០ តុល្យភាពនៃឥទ្ធិពលមហាអំណាចទោរទន់ទៅរកការបង្កើតតុលាការ ប៉ុន្តែសេចក្តីសាទរមិនដែលមានស្រុះគ្នាទាល់តែសោះ ។ កាលពីឆ្នាំទៅមិញ រដ្ឋដែលមានអំណាចនិងពាក់ព័ន្ធបំផុតនៅមហាតំបន់អាស៊ី-ប៉ាស៊ីហ្វិក និយាយឲ្យចំ សហរដ្ឋអាមេរិកផ្ទាល់តែម្តងបានប្តូរទៅប្រកាន់យកជំហរមួយទៀតដែលផ្ទុយពីមុន ហើយទីក្រុងវ៉ាស៊ីនតោនដែលបែកខ្វែកគ្នា បានរារាំងមិនឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមខ្លាំងស្ទើនឹងកាលដែលខ្លួនជួយជំរុញពីមុនមកទេ ។ នយោបាយរបស់ឥណ្ឌា និង ជប៉ុន មានលក្ខណៈផ្តល់នូវក្តីសង្ឃឹម ប៉ុន្តែទាល់តែសហរដ្ឋអាមេរិកមានចំណាប់អារម្មណ៍សាជាថ្មី ។

បើគ្មានការគាំទ្រពេញទំហឹងពីសំណាក់មហាអំណាចទេនោះ អ្នកចរចារបស់អង្គការសហប្រជាជាតិអាចមានអានុភាពមិនគ្រប់គ្រាន់ក្នុងការទម្លុះភាពទាល់ច្រកបច្ចុប្បន្ននេះជាមួយរដ្ឋាភិបាលកម្ពុជា ។ ស្ថិតក្រោមសម្ពាធមិនធ្ងន់មិនស្រាល សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និង តំណាងចរចាខាងកម្ពុជាមិនមានសុឆន្ទៈចង់ធ្វើតាមការទាមទាររបស់អង្គការសហប្រជាជាតិដែលចង់បានការធានាបន្ថែមទៀតទៅលើនីតិវិធីដើម្បីធានានូវការជម្រះក្តីប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ឡើយ ។ ការទទួលបាននូវថវិកាចំនួន៦០០លានដុល្លារជាជំនួយទ្វេភាគីដែលលើសពីសំណើរបស់ខ្លួនរហូតទៅដល់២០០លានដុល្លារនោះបង្ហាញថា ការចោទប្រកាន់ថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានជំហរដាច់អហង្ការទៅលើបញ្ហាតុលាការនោះមិនធ្វើឲ្យសម្តេចព្រឺខ្លួនបន្តិចសោះឡើយ ។ បើចង់ឲ្យរដ្ឋាភិបាលកម្ពុជាទទួលយកនូវការជំនុំជម្រះក្តីតាមការទាមទាររបស់អន្តរជាតិ(ជាពិសេសអង្គការសហប្រជាជាតិ) មហាអំណាចនឹងត្រូវតែដាក់សម្ពាធកាន់តែខ្លាំងថែមទៀត ។

ជាក់ស្តែងមានបុគ្គលច្រើនណាស់នៅក្នុងប្រទេសមហាអំណាចនីមួយៗ ព្រមទាំងមានក្រុមបដិបក្ខផ្សេងៗពីគ្នានៅក្នុងថ្នាក់ដឹកនាំរដ្ឋនីមួយៗដែលគាំទ្រតុលាការតាមផ្លូវសីលធម៌ឬមនោគមវិជ្ជារៀងៗខ្លួន ។ ក៏ប៉ុន្តែមកទល់នឹងសព្វថ្ងៃនេះឃើញថា ការគិតពីផលប្រយោជន៍ជាតិផ្ទាល់ខ្លួន យ៉ាងហោចណាស់ក៏មានសារសំខាន់ស្មើនឹងការគិតដល់យុត្តិធម៌ក្នុងការបង្កើតនយោបាយរបស់មហាអំណាចធំៗដែរ ហើយផលប្រយោជន៍ជាតិខ្លួនឯងទាំងនេះបានធ្វើឲ្យគ្មានយុត្តិធម៌សម្រាប់ឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនិស្តកម្ពុជា ។

នយោបាយរបស់មហាអំណាចមិនមែនជាកត្តាតែមួយគត់ក្នុងការគាំទ្រតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ។ នយោបាយទាំងនេះអាចមានការផ្លាស់ប្តូររហ័សបំផុតទៅតាមសភាពជាក់ស្តែងនៃដំណើរការចរចា ។ ក្នុងនាមជាប្រទេសដែលធនធានអំណាចដ៏មានសក្តានុពលនិងតែងតែផ្លាស់ប្តូរជំហរចំពោះបញ្ហាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម សហរដ្ឋអាមេរិកប្រហែលជាភ្នែកជាច្រមុះក៏មិនដឹង ។ ដើម្បីសម្រេចបាននូវយុត្តិធម៌ដែលគួរឲ្យជឿទុកចិត្តបាននៅកម្ពុជាអ្នកបង្កើតគោលនយោបាយរបស់សហរដ្ឋអាមេរិកត្រូវតែជម្នះនូវបញ្ហានានារបស់ខ្លួន ហើយតាំងចិត្តលើកកម្ពស់សិទ្ធិមនុស្សដូចគ្នាដែលជាមូលដ្ឋានគ្រឹះនៃប្រពៃណីនយោបាយនិងមនោគមវិជ្ជារបស់អាមេរិក ។

**ចន ឆរឆីអារី**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមផ្ញើមក
**ទស្សនាវដ្តី«ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥)(២៣)២១០៣៥៨
ឬ Email: dccam@bigpond.com.kh

# ភ្ជាក់ងារផ្តាច់ព្រលឹង៖ បរិយាយអំពីការប៉ះទង្គិចផ្លូវអារម្មណ៍តាមលក្ខណៈ ចិត្តសាស្ត្រសង្គម នៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា

***(តពីលេខមុន)***

*ក្នុងខណៈដែលការមកដល់របស់ព្រះពុទ្ធសាសនាធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងច្រើននៅក្នុងសង្គមខ្មែរ“មរតកអ្នកតស៊ូ”នេះត្រូវបានបន្តទុក ហើយថែមទាំងពង្រីកពង្រឹងទៀតផង ។ ប្រសិនបើអះអាងថា ស្តេចជាអ្នកការពារព្រះធម៌ (ឧទាហរណ៍) នោះព្រះពុទ្ធសាសនាបានធ្វើឲ្យការប្រើកម្លាំងប្រឆាំងនឹងខ្មាំងដែលគំរាមកំហែងដល់សណ្តាប់ធ្នាប់សង្គមមានលក្ខណៈស្របច្បាប់ ។ ធម្មនិយមនេះ ត្រូវបានពង្រឹងនិងពង្រីកដោយភាសិតខ្មែរ ច្បាប់ប្រុស ច្បាប់ស្រី និងនិទានកថាផ្សេងៗដែលជំរុញឲ្យអ្នកផងទាំងពួងគោរពប្រតិបត្តិទៅតាមឋានៈរបស់ខ្លួន ។ កុមារាកុមារីរៀនសូត្រអំពីគំរូវីរភាពរបស់ “អ្នកតស៊ូ” ដែលមានកិត្តិយសបានល្បីឈ្មោះដោយសារការក្លាហានបំពេញភារកិច្ចបានសម្រេចនិងវាយខ្មាំងប្រកបដោយវីរភាពខ្ពស់ ។ “គំរូវីរភាពខ្មែរ”ប្រភេទនេះគឺពឹងផ្អែកទៅលើដំបូន្មានមួយដែលទូន្មានថា អ្នកណាហ៊ានសម្លាប់ខ្មាំងគឺមានមុខមាត់ ចំណែកអ្នកដែលមិនហ៊ានគឺគួរឲ្យអាម៉ាស់ណាស់ ។*

*រឿងដែលមានមានប្រជាប្រិយភាពបំផុតគឺរឿង“រាមកេរ្តិ៍” ដែលខ្មែរបានយកមកច្នៃប្រឌិតជារឿងរាមាយណៈ ។ ក្រៅពីឈុតឆាកសម្តែងនៅក្នុងពិភពព្រាហ្មណ៍ដែលប្រកបដោយហិង្សានិងករណីកិច្ច វីរកថាក៏បានឆ្លុះបញ្ចាំងពីគំនិតខ្មែរទៅលើអាកប្បកិរិយាប្រកបដោយគុណធម៌ក្នុងចំណោមសហគមន៍និងអាកប្បកិរិយាប្រឆាំងនឹងខ្មាំង ។ តួអង្គកុម្ភការសម្តែងនូវការគោរពនិងស្តាប់បង្គាប់បងប្រុសរបស់ខ្លួននិងព្រះមហាក្សត្រព្រះនាមរាបនៅព្រះរាជវាំង ។ ក៏ប៉ុន្តែនៅក្នុងសមរភូមិវិញ កុម្ភការ ប្រយុទ្ធជាមួយបច្ចាមិត្រទាល់តែស្លាប់ដោយដើរតាមករណីកិច្ចរបស់ខ្លួនជាអ្នកតស៊ូ ។ ក្នុងរឿងនីមួយៗសុទ្ធតែមានសីលធម៌អប់រំខុសៗគ្នា ។ ដូចជាអ្នកដើរតាមសម្តេច សីហនុ លន់ ណុល និង ប៉ុល ពត ដែរ គឺ កុម្ភការ មានទំនោរប្រឆាំងនឹងអំពើឈ្លានពានដោយឥតមេត្តាទៅលើអ្នកដែលត្រូវបានចាត់ទុកថាជាសត្រូវនយោបាយសង្គម ។*

## ការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមក្នុងវាលពិឃាត

*ហ្វេស្ទីងហ្គ័រ អះអាងថា បុគ្គលម្នាក់អាចកាត់បន្ថយការប៉ះពាល់អារម្មណ៍ដោយការដឹងឮតាមរយៈ ១)ការផ្លាស់ប្តូរធាតុផ្សំផ្សេងៗនៃការយល់ដឹង ២)ការផ្លាស់ប្តូរអាកប្បកិរិយា ៣)បន្ថែមដោយប្រុងប្រយ័ត្ននូវការយល់ដឹងនានាដែលបំពេញចន្លោះរវាងការដឹងឮដែលមានលក្ខណៈប៉ះទង្គិច ឬ ៤)ការផ្លាស់ប្តូរស្ថានការណ៍ ដែលក្នុងនោះការយល់ដឹងលេចចេញឡើង ។ យុទ្ធសាស្ត្រកាត់បន្ថយការប៉ះទង្គិចអារម្មណ៍ទាំងនេះបើនិយាយឲ្យកាន់តែវែងឆ្ងាយទៀត ក៏អាចប្រើសម្រាប់កាត់បន្ថយការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមដែរ ។ ឧទាហរណ៍ បុគ្គលម្នាក់ដែលបានទទួលរងនូវការប៉ះទង្គិចផ្លូវអារម្មណ៍ដោយចិត្តសស្ត្រសង្គមអាចៈ ១)ផ្លាស់ប្តូរគំរូវប្បធម៌មួយរបស់ខ្លួន ២)ផ្លាស់ប្តូរអាកប្បកិរិយា ដែលគំរូមួយនៃគំរូវប្បធម៌ផ្សេងៗទៀតតម្រូវឲ្យមាន ៣)បន្ថែមនូវគម្រោងថ្មីមានកម្រិតទាបដែលនាំឲ្យគំរូវប្បធម៌នៃការប៉ះពាល់អារម្មណ៍មានភាពចុះសម្រុងគ្នា និង ឬ ៤)ផ្លាស់ប្តូរបរិបទដែលក្នុងនោះ គំរូវប្បធម៌ដែលលើកឡើងមកខាងលើនេះលេចចេញឡើង ។ យុទ្ធសាស្ត្រក្រោយនេះច្រើនតែពិបាក ពីព្រោះបុគ្គលម្នាក់ កម្រមានអំណាចផ្លាស់ប្តូរបរិយាកាសរបស់ខ្លួនដោយគ្មានជំនួយណាស់ ។*

*ក៏ប៉ុន្តែរដ្ឋដែលកាន់អំណាចផ្តាច់ការច្រើនតែធ្វើយ៉ាងដូច្នេះ ។ ការកាត់បន្ថយនូវការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមកើតឡើងទៅតាមបុគ្គលម្នាក់ៗ ។ រដ្ឋដែលកាន់អំណាចផ្តាច់ការ*

ជួយប្រែក្លាយប្រជាជនឲ្យទៅជា "ភ្នាក់ងារផ្តាច់ព្រលឹង" ដោយ ១) បំផុសមនោគមវិជ្ជាដែលផ្លាស់ប្តូរគំរូវប្បធម៌ដែលមានស្រាប់ និង ២) ផ្លាស់ប្តូរបរិបទដែលមានគំរូនានាលេចចេញឡើង ។

**ការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមI ៖ ការឆ្លើយតបជាលក្ខណៈរដ្ឋ**

នៅពេលដែលខ្មែរក្រហមវាយចូលទីក្រុងភ្នំពេញដោយជោគជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កិច្ចការដែលត្រូវបញ្ជា គឺជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនិងទីរួមខេត្តនានា ។ ការធ្វើឲ្យខ្ចាត់ព្រាត់របៀបនេះគឺសំដៅគ្រប់គ្រងប្រជា-ពលរដ្ឋបែងចែកវណ្ណៈ បង្កើតមូលដ្ឋានពលកម្មឲ្យរឹងមាំសម្រាប់បម្រើឲ្យសង្គមកុម្មុយនិស្តកសិកម្មថ្មីមួយ និងកំចាត់ចោលនូវអ្នកប្រឆាំងជំទាស់ ។ មន្ត្រីយោធានិងស៊ីវិលនៃរបបចាស់ត្រូវបានប្រមូលយកទៅសម្លាប់ចោល ។ ក្រៅពីនេះក៏នៅមានយុទ្ធនាការរែកមុខជនក្បត់ធំៗ(ដែលរួមមានដូចជាគ្រូបង្រៀនសិស្សានុសិស្សការិយាលេខានុការ អ្នកបច្ចេកទេស និង អ្នកឯកទេស) ។ "ខ្មាំងវណ្ណៈ"មួយចំនួនត្រូវបានសម្លាប់ចោល ចំណែកឯមួយចំនួនទៀតត្រូវបានបញ្ជូនយកទៅអប់រំកែប្រែនៅតាមជំរំប្រមូលផ្តុំឲ្យលត់ដំទៅតាមជីវិតជាក់ស្តែងរបស់កសិករ ។ យ៉ាងហោចណាស់ មានមនុស្សពី១សែនទៅ២សែននាក់បានស្លាប់បាត់បង់ជីវិតនៅក្នុងយុទ្ធនាការកាប់សម្លាប់លើកដំបូងរបស់កម្ពុជាប្រជាធិបតេយ្យ ។ ក្រោយពីបានចាត់ការជាមួយអ្នកប្រឆាំងនឹងខ្លួនមកពីប្រភពនានា ខ្មែរក្រហមបានបង្កើតនូវកំណែទម្រង់មួយចំនួនទៅលើសង្គមនិងមនោគមវិជ្ជាដែលជួយសម្រួលដល់ការប្រល័យពូជសាសន៍ដោយបំផ្លែងបរិយាកាសដែលក្នុងនោះ "ភ្នាក់ងារផ្តាច់ព្រលឹង" បានប្រព្រឹត្តអំពើរបស់ខ្លួន ។

**ការផ្លាស់ប្តូរសង្គមរបស់កម្ពុជាប្រជាធិបតេយ្យៈ** របបកម្ពុជាប្រជាធិបតេយ្យបានធ្វើការផ្លាស់ប្តូរជាច្រើនដែលធ្វើឲ្យអន្តរាយដល់ "សីលធម៌អហិង្សា ធម៌ត្រជាក់ "ដែលកាលពីដើមឡើយនៅជាប់នឹងការទាក់ទងតាមមូលដ្ឋានជានិច្ច ។ ចំណែកឯជីវិតប្រជាជនខ្មែរត្រូវបានផ្លាស់ប្តូរក្រឡាប់ចាក់ ។ សហករណ៍ក្លាយទៅជាកងសេដ្ឋកិច្ចសង្គមយ៉ាងសំខាន់ ។ ស្ថានភាពសេដ្ឋកិច្ចនិងបរិស្ថានវិទ្យាដែលពីមុនតម្រូវឲ្យមានកិច្ចសហប្រតិបត្តិការជាមួយគ្នានោះត្រូវបានធ្វើលែងឲ្យមានការពាក់ព័ន្ធគ្នាទៅវិញ ។ ពីមុនប្រជាជនខ្មែរធ្លាប់តែមានទំនាក់ទំនងមិត្តភក្តិសាច់ញាតិបងប្អូនដោយរាក់ទាក់ស្និទ្ធស្នាល តាមរយៈការស្គាល់គ្នាជាច្រើនឆ្នាំ ឬធ្វើការជាមួយគ្នា ប៉ុន្តែពេលនេះទំនាក់ទំនងរវាង "ប្រជាជនចាស់" "ប្រជាជនថ្មី" យុទ្ធជន និងកម្មាភិបាលមូលដ្ឋាននៅតាមសហ-ករណ៍បែរជាមានលក្ខណៈប្រកបដោយការភ័យខ្លាចនិងមិនទុកចិត្តគ្នា ហើយមានការសង្ស័យគ្នាទៅវិញទៅមក ។ កាលពីមុនធ្លាប់តែសង្កេតឃើញមានគំរូវិន័យមានតួចមានទាបដែលដាក់កម្រិតនិងធ្វើឲ្យសាយឡើងនូវទំនាស់ ។ ប៉ុន្តែមកដល់ពេលនេះម្នាក់ៗមានសិទ្ធិស្មើៗគ្នាហើយត្រូវតែគោរពធ្វើតាមតែអង្គការមួយតែប៉ុណ្ណោះ ។

ភាពចុះទម្រង់គ្នារវាងក្រុមមួយទៅក្រុមមួយកាន់តែវិចរិលថែមទៀតតាមរយៈការបំផ្លិចបំផ្លាញព្រះពុទ្ធសាសនា ។ ព្រះចៅអធិការវត្តជាច្រើនត្រូវបានសម្លាប់ចោលភ្លាមៗបន្ទាប់ពីបដិវត្តន៍ចប់ទៅ ហើយព្រះសង្ឃនៅសេសសល់ប៉ុន្មានត្រូវបានបង្ខំឲ្យលាចាកសិក្ខាបទមករស់នៅជាប្រជាជនសមញ្ញ ។ វត្តអារ៉ាមត្រូវបានបំផ្លិចបំផ្លាញ គម្ពីរសាសនាត្រូវបានដុតបំផ្លាញចោល ចំណែក រូបពុទ្ធបដិមាត្រូវបានធ្វើឲ្យខូចទ្រង់ទ្រាយ ។ កាលពីមុនកូនខ្មែរទទួលបានដំបូន្មានសុជីវធម៌នៅតាមវិហារ ប៉ុន្តែឥឡូវត្រូវបានបញ្ចូលមនោគមវិជ្ជាមួយដែលឲ្យតម្លៃខ្ពស់ទៅលើផ្តាច់ការបដិវត្តន៍និងការបូជាសាច់ស្រស់ឈាមស្រស់ ។ លទ្ធិកុម្មុយនិស្តបានចូលមកជំនួសព្រះពុទ្ធសាសនាថាជា "សាសនាថ្មី" ។

ដោយសារពីមុនគ្រួសារជាកោសិការសង្គមរបស់ជីវិតប្រជាជនខ្មែរ មកដល់ពេលនេះវាក្លាយទៅជាការគំរាមកំហែងរបស់របបកម្ពុជាប្រជាធិបតេយ្យទៅវិញ ។ បក្សបានប៉ុនប៉ងលុបបំបាត់នូវសារសំខាន់នៃគ្រួសារដោយលុបបំបាត់នូវតួនាទីសង្គមកិច្ចនិងសេដ្ឋកិច្ច ។ សមាជិកក្នុងគ្រួសារត្រូវបានបំបែកទៅតាមប្រព័ន្ធដោយដាក់កម្រិតសង់ផ្ទះសម្បែង ជម្លៀសឲ្យទៅនៅកន្លែងផ្សេង ប្រជុំសមូហភាព និងធ្វើការរយៈពេលយូរទៅតាមក្រុមការងារដែលបែងចែកតាមភេទ(ស្រីដាក់តាមស្រី-ប្រុសដាក់តាមប្រុស) ។ ការបំបែកនេះគឺជាផ្នែកមួយនៃចលនាដ៏ធំនៃការបង្វែរពីការផ្សារភ្ជាប់គ្រួសារទៅនឹងរដ្ឋ ។ ផ្អែកតាមនយោបាយ

ជាផ្លូវការនៃភាពគ្មានវណ្ណៈនិងការឲ្យតម្លៃយ៉ាងខ្លាំងទៅលើកុមារដែលជាអនាគតអ្នកបន្តវេនបដិវត្តន៍ បក្សបានបំផ្លាញនូវគំរូសីលធម៌ដែលមាននៅក្នុងទំនាក់ទំនងរវាងសមាជិកគ្រួសារ ។ វគ្គបំពាក់បំប៉នចិត្តសាស្ត្របានបង្រៀនឲ្យកូនក្មេងថា គេមិនចាំបាច់គោរពឪពុកម្តាយរបស់ខ្លួនទេ ។ ម្តាយ ឪពុក កូន និងអ្នកជិតខាងសុទ្ធតែជា “មិត្ត”ទាំងអស់ ។

**មនោគមវិជ្ជារបស់កម្ពុជាប្រជាធិបតេយ្យៈ** ដោយសារសីលធម៌អហិង្សាត្រូវបានបំផ្លាញហើយនោះ សីលធម៌ហិង្សាត្រូវបានធ្វើឲ្យក្លាយជាមនោគមវិជ្ជាស្របច្បាប់នៅតាមមូលដ្ឋាន ហើយចាប់ផ្តើមបង្កើតទៅជាការទំនាក់ទំនងជាមួយសមូហភាពជារៀងរាល់ថ្ងៃ ។ នៅពេលថ្នាក់ដឹកនាំរបបចាស់ត្រូវបានកម្ទេច ហើយសេដ្ឋកិច្ចសង្គមត្រូវបានចាប់ផ្តើមកែប្រែផ្លាស់ប្តូរនោះ របបកម្ពុជាប្រជាធិបតេយ្យបានតាំងចិត្តនាំមកនូវ“ស្មារតីតស៊ូ” ដាក់នៅក្នុងសហករណ៍ ។ មនោគមវិជ្ជាខ្មែរក្រហមប្រើពាក្យ“តស៊ូ” ដើម្បីរំឭកដល់ព្រលឹងអ្នកតស៊ូពីមុនៗ ។ ម្នាក់ៗត្រូវចុះឈ្មោះចូលបដិវត្តន៍ដើម្បី“កសាងនិងការពារ”ប្រទេស ។ សមរភូមិមុខគឺការដ្ឋាន ។ សកម្មភាពរាល់ថ្ងៃត្រូវបានរៀបចំចាត់ចែងទៅតាមខ្សែសង្វាក់យោធា ។ “កង” “កងអនុសេនាធំ” “កងអនុសេនាធំ” “កងវរសេនាតូច” និង “កងពល ”នៃក្រុមធ្វើការងារ ត្រូវបានបញ្ជូនទៅឲ្យដាំ និងប្រមូលផលដំណាំ រានដីធ្វើចម្ការ និងលើកទំនប់ ជីកប្រឡាយ ។ ដូចជាយោធាដែរ កងសេដ្ឋកិច្ចនេះមានវិន័យម៉ឺងម៉ាត់ រស់នៅយ៉ាប់យឺន និងធ្វើការងារយូរៗទៀតផង ។

សន្តិសុខជាតិគឺជាសមរភូមិក្រោយ ។ ក្រៅពីអារម្មណ៍ភ័យខ្លាចខ្មាំងខាងក្រៅ ដូចជាវៀតណាមជាដើមរបបកម្ពុជាប្រជាធិបតេយ្យ ក៏មានការភ័យខ្លាចចំពោះខ្មាំងខាងក្នុង ។ ម្នាក់ៗត្រូវបានបង្គាប់បញ្ជាឲ្យខំស្វែងរក “ខ្សែក្បត់”ដែលអាចបំផ្លាញបដិវត្តន៍ ឬចូលបម្រើបដិវត្តន៍ ។ ដំបូងបញ្ហានេះនាំឲ្យមាននូវការប្រយុទ្ធជាមួយ“ខ្មាំងវណ្ណៈ” និងភ្នាក់ងារសម្ងាត់បរទេសដែលត្រូវបានប្រៀបប្រដូចទៅនឹង “ជំងឺ” ម្យ៉ាងដែលចាំបាច់ត្រូវតែ“ព្យាបាល” ចេញ ឬ“កាត់ចេញ”ទើបបាន ។ ក្រោយពីទទួលនូវបរាជ័យផ្នែកសេដ្ឋកិច្ច ការប៉ុនប៉ងបម្រុងនឹងធ្វើរដ្ឋប្រហារ ប្រទូស្តរាយជាមួយវៀតណាមនិងការប៉ះទង្គិចផ្ទៃក្នុងជួរបក្សមកយុទ្ធនាការកាប់សម្លាប់លើកទីពីរក៏ចាប់ផ្តើមឡើងនៅចុងឆ្នាំ ១៩៧៦ ។ នៅក្នុងការបោសសម្អាតដែលពោរពេញដោយភាពឃោរឃៅនោះ កម្មាភិបាលជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យត្រូវបានធ្វើទារុណកម្មនៅកន្លែងសួរចម្លើយនៅគុកទួលស្លែង ។ គ្រួសារនិងកូនចៅក្រោមបង្គាប់ដែលមានទោសពីបទជាប់ពាក់ព័ន្ធក៏ត្រូវនាំមកជាមួយដែរ ។ គ្រាន់តែនៅភូមិភាគបូព៌ាតែមួយកន្លែងប៉ុណ្ណោះ មានមនុស្សដល់ទៅជាងមួយសែននាក់ត្រូវបានសម្លាប់នៅឆ្នាំ១៩៧៨ ដោយចោទថា“ក្បាលយួនខ្លួនខ្មែរ” ។ ភេរវកម្មនេះត្រូវបានលើកតម្កើង“ក្នុងនាមបដិវត្តន៍ ។ ហិង្សាក្លាយជាគុណធម៌ ។ ធ្វើសង្គ្រាមក្លាយជាមានមុខមាត់ ។ សម្លាប់ខ្មាំងរបស់បក្ស ក៏យ៉ាងដូច្នេះដែរ” ។

បើចង់ឲ្យ“ការកសាងនិងការពារ”ប្រទេសទទួលបានជោគជ័យជនជាតិខ្មែរទាំងអស់ត្រូវមានស្មារតីបដិវត្តន៍ត្រឹមត្រូវ ។ គំនិតថ្មីត្រូវការទាំងការដើរតាមមាគ៌ាដឹកនាំរបស់បក្សនិងការលះបង់សម្ភារៈនិយម អាកប្បកិរិយាប្រតិកិរិយា និងលះបង់ភក្តីភាពទាំងអម្បាលមានពីមុនមក ។ ដោយសារបក្សតំណាងឲ្យប្រជាជនទើបរាល់សញ្ញាណទាំងឡាយនៃការមិនគោរពប្រតិបត្តិតាមមានន័យស្មើនឹងអំពើក្បត់បក្ស ។ នៅក្នុងសង្គ្រាមខ្មាំងរបស់រដ្ឋប្រភេទនេះ ត្រូវទទួលនូវការកាត់ទោសដោយមិនមានការជំនុំជម្រះឡើយ ។ ដោយសារកម្មាភិបាលមូលដ្ឋានត្រូវបានបញ្ជាឲ្យកម្ចាត់“មេរោគ”ខាងក្នុងខ្លួនដោយមិនទាំងធ្វើរោគវិនិច្ឆ័យតើត្រូវធ្វើយ៉ាងណាផងនោះ អំពើហិង្សាដែលមានលក្ខណៈខុសគ្នាពីមូលដ្ឋានមួយទៅមូលដ្ឋានមួយក៏ចាប់ផ្តើមឡើង ។ នៅកន្លែងខ្លះកម្មាភិបាលដាច់ខាតសម្លាប់ជនសង្ស័យថា ក្បត់ដោយគ្មានញញើតដៃឡើយ ។ នៅមូលដ្ឋានផ្សេងៗទៀត កម្មាភិបាលធំៗធ្វើការល្មមៗមិនតឹងពេកទេ ។ ជាការពិតណាស់បុគ្គលប្រភេទនេះជាច្រើនអាចនឹងទទួលរងនូវការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមនៅពេលដែលខ្លួនត្រូវបានផ្តល់នូវបទបញ្ជាឲ្យសម្លាប់មនុស្សដែលជាការប្រឆាំងនឹង“សីលធម៌អហិង្សា” (ឧទាហរណ៍ដូចគំរូវប្បធម៌ផ្លូវចិត្តដែលហាមមិនឲ្យប៉ះពាល់ដល់សមាជិកនៅក្នុងសហគមជាមួយគ្នា) ដែលសីលធម៌អហិង្សានេះគឺ

ជាផ្នែកមួយដ៏សំខាន់នៃអត្តសញ្ញាណសង្គមរបស់ផងខ្លួន ។ ឥឡូវនេះយើងមកពិនិត្យមើលថាតើ“ភ្នាក់ងារផ្តាច់ព្រលឹង” ទាំងនេះដោះស្រាយជាមួយការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមតាមរបៀបណា? ។

## ការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គម II: ការឆ្លើយតបជាលក្ខណៈបុគ្គល

តើមនុស្សក្លាយជាឃាតករប្រល័យពូជសាសន៍តាមរបៀបណា? ដូចយើងបានឃើញស្រាប់ហើយថា កត្តាមួយក្នុងដំណើរការផ្លាស់ប្តូរគឺបានមកពី“ការឆ្លើយតបជាលក្ខណៈរដ្ឋ” ។ ក្នុងករណីប្រទេសកម្ពុជារបបកម្ពុជាប្រជាធិបតេយ្យបានជួយកាត់បន្ថយការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមដោយការផ្លាស់ប្តូរបរិយាកាសដូចជាបំផ្លាញចោលនូវសីលធម៌អហិង្សា និងនាំមកនូវសីលធមហិង្សាមកដល់ថ្នាក់មូលដ្ឋាន និងដោយផ្តល់នូវមនោគមវិជ្ជាដែលអាចប្រើប្រាស់សម្រាប់កែប្រែគំរូវប្បធម៌ទាំងពីរនេះ(ដូចជាកំណត់សាឡើងវិញនូវពាក្យថា“ខ្មាំង”បញ្ជាឲ្យសម្លាប់“ជនក្បត់”ជំរុញហិង្សាបដិវត្ត) ។ ប៉ុន្តែនៅទីបញ្ចប់ការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមកើតឡើង ហើយត្រូវបានកាត់បន្ថយទៅតាមបុគ្គល ។

“ការឆ្លើយតបជាលក្ខណៈបុគ្គល”បែបនេះមានលក្ខណៈខុសពីគ្នាទៅតាមបុគ្គលម្នាក់ៗ ។ ផ្អែកលើប្រវត្តិជីវិតរបស់ខ្លួនបុគ្គលម្នាក់នឹងចាំបាច់ត្រូវការចាត់វិធានការមួយចំនួនដើម្បីឲ្យក្លាយខ្លួនទៅជា“ភ្នាក់ងារផ្តាច់ព្រលឹង” ។ មានប្រជាជនខ្លះប្រហែលជាត្រូវការត្រឹមតែបរិយាកាសមួយសមរម្យដើម្បីអនុម័តនូវសក្តានុពលភាពនានាដែលខ្លួនធ្វើឲ្យចេញជារូបរាងហើយនោះ ។ មនុស្សដទៃទៀតអាចត្រូវតែធ្វើការផ្លាស់ប្តូរមួយចំនួនដើម្បីឲ្យក្លាយខ្លួនជាពេជ្ឈឃាត ។ ប៉ុន្តែក៏មានអ្នកខ្លះអាចបដិសេធមិនចូលរួមជាមួយរបបប្រល័យពូជសាសន៍ដែរ ។ ពេជ្ឈឃាតប្រល័យពូជសាសន៍ភាគច្រើនប្រហែលជាចូលក្នុងជំពូកកណ្តាលនេះឯង ។ វគ្គនេះនេះនឹងរៀបរាប់អំពី“វិធានការ” មួយចំនួនទាក់ទងនឹងការយល់ដឹងដែលបុគ្គលទាំងឡាយអាចនឹងប្រកាន់យកដើម្បីកាត់បន្ថយការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមដល់ចំណុចដែលធ្វើឲ្យអ្នកទាំងនោះក្លាយខ្លួនទៅជា“ភ្នាក់ងារផ្តាច់ព្រលឹង” ។ ជាពិសេស ខ្ញុំនឹងទាញហេតុផលថា“បុគ្គលិកលក្ខណៈប្រល័យពូជសាសន៍”កើតឡើងនៅក្នុងស្ថានភាពដែលអ្នកដើរតួនោះមានលទ្ធភាពអាចៈ ១) ធ្វើឲ្យជនរងគ្រោះបាត់បង់ភាពជាមនុស្ស ២) ប្រើពាក្យសម្រាលកុំឲ្យអាក្រក់ស្តាប់ចំពោះទង្វើរបស់ខ្លួន ៣) រៀបចំសីលធម៌ឡើងវិញ ៤) ស៊ាំនឹងការសម្លាប់ និង ៥) ប្រកែកមិនទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។ ខ្ញុំនឹងដោះស្រាយរកយុទ្ធសាស្ត្រនានាក្នុងការកាត់បន្ថយការប៉ះទង្គិចផ្លូវអារម្មណ៍នេះ ។

**ការធ្វើឲ្យបាត់បង់តម្លៃជាមនុស្សៈ** ក្រុមអ្នកចិត្តសាស្ត្រសង្គមមួយក្រុមនៅសាកលវិទ្យាល័យស្តែនហ្វដធ្លាប់បានដកពិសោធន៍ចេញពីគុកមួយដែលក្នុងនោះនិស្សិតដែលជាកម្មវត្ថុនៃបទពិសោធន៍នោះត្រូវបានរើសដាក់ឲ្យសម្តែងជា“អ្នកទោស” និង“ឆ្មាំគុក” ។ ៦ថ្ងៃក្រោយមកការសិក្សាស្រាវជ្រាវដែលគម្រោងថានឹងធ្វើឡើងពីរសប្តាហ៍ត្រូវបានផ្អាកក្រោយពីឆ្មាំគុកសម្តែងចេញនូវកាយវិការក្រេវក្រោធរំលោភបំពានខ្លាំងពេកចំពោះអ្នកទោស ។ បទពិសោធន៍នេះបង្ហាញពីទិដ្ឋភាពពីរទាក់ទងគ្នានៃដំណើរការធ្វើឲ្យបាត់បង់តម្លៃជាមនុស្សដែលសម្រួលដល់ការប្រល័យពូជសាសន៍ ពោលគឺការបដិសេធ និងការបញ្ចុះតម្លៃ ។ “ការបដិសេធ”សំដៅដំណើរការដែលមនុស្សបាត់បង់នូវអត្តសញ្ញាណរបស់ខ្លួននិងត្រូវបានចាត់ទុកថាជាមនុស្សដែលស្ថិតនៅក្រុមផ្សេងពីសង្គមធំមួយនោះ ។ “ការបញ្ចុះតម្លៃ”សំដៅវិធីដែលក្រុមមនុស្សទាំងនេះត្រូវបានធ្វើឲ្យក្លាយជាមនុស្សមិនសំខាន់ ឬមនុស្សបាតសង្គម ។ ទាំងការបដិសេធនិងការបញ្ចុះតម្លៃគឺសុទ្ធតែនាំដល់ការធ្វើឲ្យបាត់បង់តម្លៃជាមនុស្សដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដើម្បីលុបបំបាត់ឋានានុក្រមនិងការបែងចែកវណ្ណៈ ខ្មែរក្រហមបានតាំងចិត្តដកចេញនូវអ្នកណាដែល“អាត្មានិយម”មានគំនិត“មូលធននិយម” ។ កម្មសិទ្ធឯកជនត្រូវបានលុបបំបាត់ចោល ។ ត្រូវធ្វើការងាររួម និងហូបរួម ។ ម្នាក់ៗត្រូវស្លៀកពាក់អាវខ្មៅខោខ្មៅ កាត់សក់ឲ្យខ្លី និយាយស្តីនិងអាកប្បកិរិយា“សមសួន”និងកម្ចាត់ចោលនូវទម្លាប់អាត្មានិយមដែលប្រឆាំងនឹង“ការភ្ញាក់រលឹក”បដិវត្តន៍ ។ គោលបំណងដែលចង់បានគឺ

បង្កើតឡើងនូវសង្គមមួយដែលម្នាក់ៗមានលក្ខណៈដូចៗគ្នា ហើយម្នាក់ៗសុទ្ធតែស្ថិតនៅក្រោមរដ្ឋតែមួយ ។

តាមការពិតមនុស្សនៅក្នុងសង្គមនោះត្រូវបានបែងចែកទៅតាមប្រភេទផ្សេងតទៅទៀត ។ ទីមួយ គឺបែងចែករវាងខ្មែរ"ពិតប្រាកដ"ដែលជាផ្នែកមួយរបស់អង្គការនិងអ្នកដែលជា "សត្រូវ"របស់អង្គការ ។ ដោយសារអង្គការជាអ្នកតំណាងឲ្យប្រជាជន អ្នកដែលប្រឆាំងគឺជាអ្នកក្បត់ ។ កម្មាភិបាលមូលដ្ឋានត្រូវបានបញ្ជាឲ្យកម្ចាត់"ខ្មាំងវណ្ណៈ"ដែលចង់បំផ្លាញបដិវត្តន៍ ។ អ្នកដែលស្ថិតនៅក្នុងការសង្ស័យគឺប្រជាជន "ថ្មី" ពោលគឺអ្នកទីក្រុងនិងជនភៀសខ្លួននៅតាមជនបទដែលត្រូវបានដេញចេញពីទីក្រុងនានា និងដែលត្រូវបានគាំទ្រដោយផ្ទាល់ពីសំណាក់កងកម្លាំង លន់ ណុល ដែលខ្មែរក្រហមបានវាយឲ្យបរាជ័យហើយនោះ ។ ដោយធ្លាប់ស្ថិតនៅក្រោមឥទ្ធិពលបរទេស និងចក្រពត្តិនិយម ប្រជាជនថ្មីលែងត្រូវបានចាត់ទុកជា"ខ្មែរសុទ្ធ"ទៀតហើយ តែបែរជាចាត់ទុកជាខ្មាំងដែលគួរតែទទួលរងនូវការធ្វើបាបទៅតាមកម្រិតនៃសីលធម៌ហិង្សា ។ ប្រជាជនជំពូកនេះត្រូវបានបែងចែកដាច់ពីកម្មាភិបាលនិងយុទ្ធជនខ្មែរក្រហមនិងប្រជាជន"ចាស់"ដែលបានរស់ដោយលំបាកវេទនានៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅក្នុងអំឡុងឆ្នាំកើតសង្គ្រាម ។ ចាប់តាំងពីដំបូងដែលមកម្ល៉េះគឺថាប្រជាជន"ថ្មី" គឺជា "អ្នកក្រៅ" ដែលទទួលរងនូវការធ្វើបាបខ្លាំងជាងគេ ។

ក្រៅពីមិនឲ្យចូលក្នុងជីវភាពសមូហភាពដូចគេដូចឯងប្រជាជន"ថ្មី"និងអ្នកដែលត្រូវសង្ស័យថាជាខ្មាំងត្រូវទទួលរងនូវការធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ។ ប្រជាជន"ថ្មី" បាននិយាយថា ខ្លួនត្រូវគេចាប់ញាត់ឡានអស់រយៈពេលជាច្រើនម៉ោងនៅអំឡុងពេលការជម្លៀសលើកក្រោយទៀត ។ ភាគច្រើនត្រូវបត់ជើងធំ និងបត់ជើងតូចនៅកន្លែងណាដែលខ្លួនឈរ ។ ឡានបើកទៅមុខរហូតមិនដែលឈប់សម្រាកទេ ទោះបីជាមានមនុស្សដាច់ខ្យល់ស្លាប់ដោយការថប់ដង្ហើមយ៉ាងណាក៏ដោយ ។ "គេធ្វើបាបយើងខ្លាំងជាងគោក្របីទៅទៀត គេមើលងាយមើលថោក... យើងលែងជាមនុស្សទៀតហើយ" ។ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការដូចសត្វធាតុ ។ ប្រជាជនទាំងនោះមិនត្រឹមតែបង្ខំឲ្យធ្វើការច្រើនម៉ោងនិងដាច់បាយដាច់ទឹកតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើការដោយស្ថិតនៅក្រោមការឃ្លាំមើលមិនដាក់ភ្នែកពីសំណាក់យុទ្ធជន និងមេកងដែលមានអំណាចអាចយកទៅសម្លាប់ចោលក៏បាន ។ មានប្រជាជនជាច្រើនបានរៀបរាប់អំពីការរស់នៅដ៏សែនលំបាកវេទនានៅក្នុងសម័យកម្ពុជាប្រជាធិប-តេយ្យ ។ "យើងឃ្លានបាយ អស់កម្លាំងរហិតរហៃរហូតដល់គ្មានកម្លាំងនឹងលាងសម្អាតខ្លួនប្រាណ ឬសម្លៀកបំពាក់ផង ។ ដល់អ៊ីចឹងទៅ លែងនឹកឃើញអនាម័យ អានាមួយ ស្អីទៀតហើយ ។ ស្អីក៏យើងហូបដែរមិនរើសទេឲ្យតែបានហូប...ដុះកន្លែងណាក៏ដុះទៅ អ្នកណាឃើញអី ក៏ឃើញទៅលែងខ្វល់ ។ ជំងឺរាតត្បាតពាសពេញភូមិ ដូចជាជំងឺអាសន្នរោគ ជំងឺគ្រុនចាញ់ ជំងឺរាគមួល រាករូស និងជំងឺកមរមាស់" ។

ការធ្វើឲ្យបាត់បង់តម្លៃជាមនុស្សបែបនេះគឺឆ្លុះបញ្ចាំងតាមរយៈមនោគមវិជ្ជាអប់រំរបស់ខ្មែរក្រហម ។ ប្រជាជនត្រូវបានណែនាំឲ្យធ្វើការដូចគោដូចក្របីៈ"សមមិត្តគោមិនដែលបដិសេធមិនព្រមធ្វើការទេ ។ សមមិត្តបេះគោរពបញ្ជា ។ សមមិត្តគោមិនដែលមាត់កអីមួយម៉ាត់ ។ សមមិត្តគោមិនដែលតវ៉ានៅពេលគេយកគ្រូសារទៅសម្លាប់ចោលទេ" ។ យុទ្ធជនម្នាក់ប្រាប់ទៅប្រជាជន"ថ្មី"ថាម៉ែសមមិត្តនារីស្លាប់ប្រសើរជាងគោស្លាប់ "គោជួយយើងច្រើនណាស់ ហើយឥតស៊ីបាយទៀត ។ វាគ្រាន់បើជាងពួកឯងឆ្ងាយណាស់" ។ ការបញ្ចុះតម្លៃមួយផ្នែក បណ្តាលមកពីការដែលថាប្រជាជនថ្មីតែងតែត្រូវបានចាត់ទុកថាជា "ឈ្លើយសង្គ្រាម" ។ "សឹងតែរាល់ពេលយើងឮយុទ្ធជនស្រែកថា"ឈ្លើយសឹក"អាជ្រូក ។ យើងឈឺចាប់ណាស់ពីមុន ។ ឥឡូវដល់ពេលឯងត្រូវរងការឈឺចាប់ម្តង" ។ ជួនកាលគេអត់ឱនឲ្យដែរ តែ"ខ្មាំង"ត្រូវតែធ្វើការខ្លាំង ហើយស្តាប់បង្គាប់ ។ ប្រសិនបើគេធ្វើអ្វីខុស ដកចេញក៏មិនខាតចំពោះកម្ពុជាប្រជាធិបតេយ្យដែរ ។ នៅក្នុងពេលពន្យល់រៀបរាប់ពីមូលហេតុដែលមេឃុំសមមិត្ត ចេវ សម្លាប់និងបញ្ជាឲ្យសម្លាប់ប្រជាជនច្រើនម្ល៉េះ លោក ហាំង ឆៅ កត់សម្គាល់ថា"យើងមិនមែនជាមនុស្សទេ ។ យើងរស់នៅថោកទាបណាស់ ដោយសារតែយើងជាខ្មាំង ។ គេវ៉ៃយើងចោលដូចវ៉ៃរុយអញ្ចឹងនេះជាផ្លូវកម្ចាត់អ្នកដែលមិន

ត្រូវទុក» ។

ខ្មែរក្រហមប្រភេទនេះត្រូវបានអប់រំបញ្ចូលមនោគមវិជ្ជាឲ្យគ្មានអារម្មណ៍អាណិតដល់ខ្មាំង ។ ដូចដែលកម្មាភិបាលម្នាក់បានប្រាប់ខ្ញុំថា «យើងត្រូវបានដុះខាត់ស្មារតីឲ្យចេះកាត់ចិត្តពីខ្មាំងឲ្យមានចិត្តចង់សម្លាប់ខ្មាំងដែលក្បត់បដិវត្តន៍ ទោះបីជាអ្នកនោះជាឪពុកម្តាយ បងប្អូន មិត្តភក្តិ ឬ សាច់ញាតិក៏ដោយចុះ ។ អ្វីៗដែលយើងធ្វើគឺដើម្បីបក្ស» ។ គំនិតឲ្យកាត់ចិត្តចំពោះ«ខ្មាំង» ដែលត្រូវគេបដិសេធចោលនិងធ្វើឲ្យបាត់បង់តម្លៃជាមនុស្សជួយឲ្យខ្មែរក្រហមជាច្រើនក្នុងការកាត់បន្ថយការប៉ះពាល់អារម្មណ៍ដោយចិត្តសាស្ត្រសង្គមតាមរយៈការកំណត់សារជាថ្មីថាអ្នកណាត្រូវចាត់ចូលក្នុងសង្គមនិងបង្កើតនូវក្រុមដែលជាមុខសញ្ញាធ្វើយ៉ាងណាឲ្យខ្លួនមានអារម្មណ៍អន្ទះសារ ។ ដោយសារចលនាតស៊ូបដិវត្តន៍ចេះតែបន្តទៅនៅតាមសហករណ៍ កម្មាភិបាលខ្មែរក្រហមមានបញ្ហាតិចតួចណាស់ក្នុងការប្រើប្រាស់«សីលធម៌ហិង្សា ធម៌ក្តៅ» ដើម្បីសម្លាប់ខ្មាំងដែលខ្លួនស្អប់ដែលជាការគំរាមកំហែងដល់បដិវត្ត ដែលមិនមែនជា«ខ្មែរសុទ្ធ» និងដែលមានឋានៈទាបជាងមនុស្សទៅទៀត ។

**ពាក្យសម្រាលប្រើកុំឲ្យអាក្រក់ស្តាប់ពេក៖** ដោយប្រើប្រាស់នូវពាក្យសម្រាលជនដែលប្រព្រឹត្តអំពើហិង្សាមានលទ្ធភាពអាចលាក់បាំងនូវសារជាតិពិតនៃអំពើរបស់ខ្លួនតាមរយៈការសម្តែងមនោសញ្ចេតនាទាំងឡាយណាដែលធ្វើឲ្យខ្លួនមើលទៅឃើញដូចជាមុខស្លូត ឬគួរឲ្យគោរព ។ នៅជំរំណាហ្ស៊ីរបស់អាល្លឺម៉ង់ ជាឧទាហរណ៍ជាក់ស្តែង ជនជាតិជ្វីហ្វត្រូវបានគេចាត់ទុកថាជាជំងឺមួយប្រភេទ បើកម្ចាត់ជំងឺនេះទៅនឹងមានប្រយោជន៍ដល់សុខភាពសាធារណៈដូច្នេះដែរ ។ ជនជាតិជ្វីហ្វដែលមកដល់ទីក្រុងអូសវីត ត្រូវបានរៀបចំឲ្យ «ព្យាបាលជំងឺជាលក្ខណៈពិសេស» ដែលក្នុងការព្យាបាលនោះ«ក្រុមដែលមិនទាន់ឆ្លង»ត្រូវចាក់ថ្នាំស៊ីយ៉ានីតចូលទៅក្នុងក្បាលរ៉ូមីណេផ្កាឈូក ។ ការប្រើល្បិចជាលក្ខណៈភាសាបែបនេះផ្តល់ឲ្យជនដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍នូវ«ការថ្លែងយោបល់ដែលអាចទទួលយកបានថា ការសម្លាប់លែងជាការសម្លាប់ទៀតហើយ ។ ចាំបាច់ត្រូវតែសាកមើល ឬយល់ឃើញថា ជាការសម្លាប់»ក៏បាន ។

អាចមានអ្នកសង្ស័យថា នៅក្នុងវប្បធម៌មួយ ការនិយាយតពីមាត់មួយទៅមាត់មួយជារឿងធម្មតាទៅហើយ ។ យ៉ាងណាមិញ ការពោលពាក្យសម្រាលឲ្យពិរោះស្តាប់ក៏ជារឿងធម្មតាដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក៏ដូចជានៅក្នុងជំរំណាហ្ស៊ីរបស់អាល្លឺម៉ង់ដែរ អំពើឃោរឃៅជាច្រើនត្រូវបានពិពណ៌នាតាមលក្ខណៈវេជ្ជសាស្ត្រ ។ ការកម្ចាត់ខ្មាំងត្រូវបានឲ្យហេតុផលថាដូចជាការចាំបាច់ដូចជាការ«កម្ចាត់» «អ្នកដែលមានជំងឺដែរ» ។ ដំណើរបន្សុទ្ធកម្មបែបនេះចេះតែបន្តទៅមុខជាលំដាប់នៅពេញមួយសម័យកម្ពុជាប្រជាធិបតេយ្យនេះឯង ។ នៅចុងឆ្នាំ១៩៧៦ ប៉ុល ពត បាននិយាយថា៖«នៅក្នុងបក្សមានជំងឺ...យើងមិនទាន់រកឃើញច្បាស់នៅឡើយទេ ។ ត្រូវពិនិត្យជំងឺឲ្យមែនទែន ។ បើចេះតែចាំយូរៗទៅ មេរោគអាចបង្កឲ្យមានបញ្ហាធំមិនខាន» ។ ល្បឿននៃការលប់បំបាត់«ការឆ្លង»នេះបាននាំឲ្យមានវិសុទ្ធកម្មហិង្សាដែលកើនឡើងជាលំដាប់ទាំងនៅតាមមូលដ្ឋាននិងគ្រប់ជាន់ថ្នាក់លើរបស់បក្សខ្លួនឯងផ្ទាល់ ។ នៅភូមិភាគបូព៌ាដែលមានព្រំប្រទល់ជាប់នឹងវៀតណាមមានបុគ្គលជាច្រើនជាពិសេសប្រជាជនថ្មីតែម្តងត្រូវបានសម្លាប់ចោលដោយសង្ស័យថា «មានជំងឺគាំទ្រវៀតណាម» ។

កម្មាភិបាលមូលដ្ឋានកម្ពុជាប្រជាធិបតេយ្យបានប្រើប្រាស់ពាក្យសម្រាលកុំឲ្យពិបាកស្តាប់ជាច្រើនប្រភេទបិទបាំងអំពើប្រល័យពូជសាសន៍របស់ខ្លួន ។ អ្នកខ្លះត្រូវបានគំរាមថា នឹងយក «ទៅព្រៃ» ខ្លះថាយក«ទៅវាលក្រោយភូមិ» ឬយកទៅ «ធ្វើការនៅឯភ្នំ»ជាដើម ។ តាមវប្បធម៌ខ្មែរ កន្លែងទាំងនេះសុទ្ធតែពាក់ព័ន្ធនឹងពាក្យ«ព្រៃ»ដែលជាកន្លែងមួយគួរឲ្យភ័យខ្លាចមិនស៊ីវិល័យជាកន្លែងដែលមានអំពើឃោរឃៅកើតឡើង ។ មុនពេលបណ្តើរទៅធ្វើទារុណកម្ម ដាក់គុក ហើយយកទៅសម្លាប់ចោល អ្នកទាំងនោះតែងតែត្រូវបានប្រាប់ថា គេយកទៅ«រៀនសូត្រ» ឬ«ទៅជួបអង្គការ» ។ ពាក្យដោះសារបែបនេះប្រើសម្រាប់បិទបំបាំងនិងធ្វើអំពើឃោរឃៅដែលកម្មាភិបាលខ្មែរក្រហមបានប្រព្រឹត្តឲ្យមានភាពស្របច្បាប់ ។

**(នៅមានត)**

**អាឡិច ហ៊ីនតុន**

# ស្វែងយល់នូវព្រះពុទ្ធដីកា «ពៀររំងាប់ដោយការមិនចងពៀរ»

នៅក្នុងសង្គមខ្មែរ ការកំណត់យកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋត្រូវបានអនុវត្តជាច្រើនជំនាន់ ។ បាវចនាជាតិកម្ពុជាចែងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣របស់ព្រះរាជាណាចក្រកម្ពុជាគឺ "ជាតិ សាសនា ព្រះមហាក្សត្រ" ។ ក្នុងមាត្រា៤៣ វាក្យខណ្ឌទី៣ ក៏បានចែងដែរថា "ព្រះពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ" ។ ដូច្នេះព្រះពុទ្ធសាសនាបានចាក់ឫសយ៉ាងជ្រៅនៅក្នុងទំនៀមទម្លាប់ប្រពៃណីខ្មែរជាយូរលង់ណាស់មកហើយ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សេរីភាពនៃការគោរពប្រតិបត្តិសាសនា ត្រូវបានកាត់បន្ថយពីកម្រិតទាបបំផុតមកដល់កម្រិតសូន្យសុង ។ ប្រជាជនដែលបានឆ្លងកាត់របបនេះយល់យ៉ាងច្បាស់ថា ខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញលើសាសនាក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។

"ការធ្វើទុកបុកម្នេញលើសាសនា"គឺជាបទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋមួយចំនួនដែលស្ថិតក្នុងច្បាប់កាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិប-តេយ្យ ត្រូវបានឡាយព្រះហស្តលេខាដោយសម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែសីហា ឆ្នាំ២០០១ ។ នៅក្នុងជំពូកទី១ បទប្បញ្ញត្តិទូទៅ មាត្រា១បានកំណត់ច្បាស់ថា "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយណាដែលត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា រំលោភទៅលើច្បាប់និងទំនៀមទម្លាប់អន្តរជាតិ ហើយនិងរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ដល់ថ្ងៃ៦ មករា ១៩៧៩ ។"

ដោយសារមានជំនឿលើព្រះពុទ្ធសាសនាយ៉ាងមុតមាំ ប្រជាជនខ្មែរមួយចំនួនដែលនៅរស់នៅតាមស្រុកស្រែចម្ការពុំបានគិតគូរល្អិតល្អន់ពីទង្វើដែលខ្មែរក្រហមបានប្រព្រឹត្តនៅក្នុងឆ្នាំ១៩៧៥-១៩៧៩ ថាជាបទល្មើសកម្រិតអន្តរជាតិធ្ងន់ធ្ងរនោះឡើយ ។ មិនតែប៉ុណ្ណោះទៀតសោត ជនរងគ្រោះមួយចំនួនមិនចង់រំឭកឡើងវិញនូវអតីតកាលដ៏ខ្មៅងងឹតដែលគ្របដណ្តប់ដោយអំពើឃោរឃៅព្រៃផ្សៃរបស់មេដឹកនាំខ្មែរក្រហមឡើយ ហើយសុខចិត្តទទួលរងការឈឺចាប់និងរស់ជាតិល្វីងជូរចត់យ៉ាងស្ងាត់ស្ងៀមទៅវិញដោយសារតែការភ័យខ្លាច ។ លើសពីនេះទៅទៀត មីងមា លោកយាយ លោកតាខ្លះ បានលើកយកទស្សនៈព្រះពុទ្ធសាសនា"ពៀររំងាប់ដោយការមិនចងពៀរ"ដាក់ក្នុងចិត្ត ហើយបង្វែរជីវិតចេញពីយុត្តិធម៌ទៅវិញ ។

ទន្ទឹមនឹងនេះ ក៏នៅតែមានអតីតខ្មែរក្រហមមួយចំនួនទៀតយល់ច្រឡំដែរថា ទង្វើរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តចំពោះជនរងគ្រោះរបស់ខ្លួន មិនគួរត្រូវបានរំឭកឡើងវិញទេ ពីព្រោះវាគឺជារឿងអតីតកាលដែលកន្លងហួសជាយូរឆ្នាំមកហើយ ។ ខៀវ សំផន អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យបាននិយាយនៅឯសន្និសីទសារព័ត៌មាន នៅខែធ្នូ ឆ្នាំ១៩៩៨ ជាភាសាអង់គ្លេសទាំងរដាក់រដុបថា "រឿងដែលកន្លងហួសទៅហើយឲ្យវាហួសទៅចុះ" ។

ប្រសិនបើយើងបណ្តោយឲ្យអតីតកាលនៃកម្មពៀររបស់ខ្មែរក្រហមកន្លងហួសទៅនោះ បញ្ជាក់ថា វាមិនមែនជាទង្វើមួយនៃ"ពៀររំងាប់ដោយការមិនចង់ពៀរ"ទេ ពីព្រោះថា ប្រសិនបើយើងមិនស្រាយពៀររបស់ខ្មែរក្រហមចេញទេ ពៀរនេះក៏ចេះតែមានតទៅទៀត ។

ពាក្យថា "ពៀរ" មានន័យថា "ចំណងចិត្តក្រោធដែលចងដោយព្យាបាទ បម្រុងនឹងសងសឹកវិញ, ចំណងចិត្តជាសត្រូវៈ

ចងពៀរ, ស្រាយពៀរ, មនុស្សមានពៀរ»។ ចំណែកឯពាក្យថា «ពៃរ» ក៏មានន័យដូចគ្នាទៅនិងពាក្យ«ពៀរ»ដែរ។ ខ្មែរប្រើពាក្យនេះជាបរិវារស័ព្ទសម្រាប់និយាយផ្សំនឹងពាក្យ«ទោស» គឺថាៈ ទោសពៃរ គឺទោសនឹងពៀរ ឬទោសជាពៀរ។ ពាក្យក្លាយរបស់ពាក្យ«ពៃរ៍» គឺ «ពៃរី» មានន័យថា អ្នកមានពៀរ, អ្នកចងពៀរ, បច្ចាមិត្ត, សត្រូវ។ ច្រើនប្រើក្នុងពាក្យកាព្យៈ «យោធាឥតរានឹងពៃរី ប្រយុទ្ធវក់វីយ៉ាងអង់អាច ធ្វើឲ្យសត្រូវបាក់ខ្ចបខ្ចាចថយរត់ប្រសាចលែងងាកក្រោយ»។

ក្នុងន័យព្រះពុទ្ធសាសនា«ពៀរត្រូវរំងាប់ដោយការមិនចងពៀរ» គឺសំដៅលើ«ការរួចចាកពៀរព្រោះស្រាយពៀរ» មានន័យថា កាលបើបានដាចងពៀររួចទៅហើយ ដែលបានរួចរំដោះចាកពៀរលែងមានតទៅទៀត ព្រោះស្រាយចំណងពៀរនោះឲ្យជ្រះស្រឡះចេញ បើមិនស្រាយចេញទេ ពៀរក៏ចេះតែមានតៗទៅទៀត។ ដូចពាក្យកាព្យថា «ទីឃាវុកុមារមានវាចារណ៍ចៀសពៀរបាន ទើបមានសុខក្សេមក្សាន្ត បានសោយរាជ្យគ្រងរដ្ឋពីរ»។(រឿងទីឃាវុកុមារនិងព្រះបាទព្រហ្មទត្តក្នុងទីឃាវុកុមារជាតក ជាពុទ្ធភាសិត)។

តាមពុទ្ធវចនាលោកថែងថា «ពៀររំងាប់ដោយការមិនចងពៀរ»។ តើការដែលយើងនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ចាត់ទុកជាការចងពៀរដែរឬទេ? ឆ្លើយនឹងសំណួរនេះ ព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយនៃកម្ពុជា បានមានសង្ឃដីកាថា វាអត់មានពៀរទេ ក៏ប៉ុន្តែបើពៀរតទៅទៀតនោះ អាប្អូនទោសងងប់នោះ។ បើដល់កាត់ទោសនោះ វាចេះតែខុសទៅ វាចេះតែអូសទាញទាំងអាអ្នកទាំងអស់គ្នាហ្នឹង បើមិនពៀរនឹង ប៉ុល ពត ចុះ ប៉ុល ពត ទៅយកឯណា បើ ប៉ុល ពត ងាប់បាត់ទៅហើយ។

ថ្វីដ្បិតតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនដូចជា សុន សេន, ប៉ុល ពត និង កែវ ពក បានស្លាប់ទៅហើយក៏ពិតមែន ប៉ុន្តែនៅមានមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់មួយចំនួនទៀត ដូចជា ខៀវ សំផន, នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង តាម៉ុក ជាដើម ត្រូវតែមានចំណែកក្នុងការទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងអំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យ។

អំពើរបស់មេដឹកនាំខ្មែរក្រហមដែលធ្វើឲ្យបាត់បង់ជីវិតប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់ហ្នឹង តើគួរតែត្រូវបានកាត់ទោសឬក៏បណ្តោយទៅតាមកម្មពៀរ? ឆ្លើយនឹងសំណួរនេះ ព្រះមហាសុមេធាធិបតី ទេព វង្ស បានមានសង្ឃដីកាថា មិនមែនបណ្តោយតាមកម្មពៀរទេ។ អ្វីត្រូវតែវិនិច្ឆ័យទាំងអស់ ក៏ប៉ុន្តែ វិនិច្ឆ័យឲ្យមានយុត្តិធម៌ផង សូមឲ្យវិនិច្ឆ័យមានយុត្តិធម៌តាមរយៈសាសនាផង។...កុំឲ្យប្រកបនូវការគំរាមកំហែង ការប្រមាថមើលងាយមើលថោកតបត ក្រែងពៀរហ្នឹងវាតគ្នាតទៅទៀត។

ចំណែកសម្តេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី ព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា បានមានសង្ឃដីកាថា រឿងតុលាការ រឿងកាត់ទោសខ្មែរក្រហមអីទាំងអស់ហ្នឹង អាត្មាក្នុងឋានៈជាអ្នកបួស។ អ្នកបួស បើយោងទៅតាមព្រះពុទ្ធដីកា សម្តេចព្រះសម្មាសម្ពុទ្ធ ស្តេចទ្រង់មានព្រះទ័យមេត្តាករុណា មុទិតា ឧបេក្ខា។ គឺថាមិនចំពោះថាអ្នកហ្នឹងជាស្អីទេ គឺទ្រង់មានព្រះទ័យអីចឹង សូម្បីតែទេវទត្តដែលតាមធ្វើគុតព្រះពុទ្ធអង្គ ព្រះពុទ្ធអង្គក៏ស្តេចទ្រង់ព្រះពុទ្ធានុញ្ញាតឲ្យចូលគាល់ដែរ។

សម្តេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី បានមានសង្ឃដីកាបន្តទៀតថា បើយើងគិតទៅតាមរបៀបខ្មែរយើងតាំងពីបរមបុរាណមក លោកថា «កាត់ទឹកមិនដាច់ កាត់សាច់វាឈឺ» អាហ្នឹងក៏មួយនៅក្នុងចំណោមពាក្យខ្មែរយើងដែលមានច្រើនមក។ មួយទៀតគេថា «យល់ញាតិ ឃាតច្បាប់»។ អាហ្នឹងក៏មួយទៀតដែរ។ អីចឹងសង្គមខ្មែរយើងយកមកប្រើទាំងអស់ ច្បាប់ក៏ប្រើ សាច់ញាតិក៏ប្រើ ប្រើទាំងពីរ។

សុភាសិតខ្មែរទាំងពីរឃ្លា ពិតជាត្រឹមត្រូវណាស់។ «កាត់ទឹកមិនដាច់ កាត់សាច់វាឈឺ» ជារឿងមួយពិបាកខ្លាំងណាស់ ហើយជារឿងឈឺចាប់ទៀតផង។ ក្នុងលោកយើងនេះ គ្មានអ្វីដែលថាមិនអាចដោះស្រាយបាននោះទេ ប៉ុន្តែគ្រាន់តែត្រូវការពេលវេលាយូរបន្តិចប៉ុណ្ណោះ។ ដើម្បីធ្វើឲ្យសង្គមមួយមានការអភិវឌ្ឍ និងក្លាយទៅជានីតិរដ្ឋ យើងត្រូវពុះពារឧបសគ្គគ្រប់បែបយ៉ាង និងទ្រាំទ្រការឈឺចាប់មិនតិចឡើយ។ ស៊ូទ្រាំការលំបាក និងការឈឺចាប់មួយរយៈពេល ប្រសើរជាងការបណ្តែត

បណ្តោយឲ្យមានការលំបាកនិងការឈឺចាប់បន្តនាំមុខយើងជារៀងរហូត ។ "យល់ញាតិឃាតច្បាប់" ក៏ជារឿងពិតមិនប្រកែកបានដែរនៅពេលដែលយើងចេះតែបន្តការយោគយល់គ្នា ការអធ្យាស្រ័យឲ្យគ្នាដោយគ្មានដែនកំណត់នោះ ។ ការប្រើមនោសញ្ចេតនាហួសហេតុក្នុងការលើកលែងទោសឲ្យគ្នាជាហេតុធ្វើឲ្យច្បាប់មានតួនាទីកាន់តែតិចតួចនៅក្នុងដំណើរការសង្គមដើម្បីឈានទៅរកនីតិរដ្ឋ ។

សម្តេចព្រះសុគន្ធាធិបតី ប៊ូរ គ្រី បានមានសង្ឃដីកាបញ្ជាក់ទៀតថា ពាក្យថា"អភ័យ" បានន័យថា គេយកមក គេអប់រំឲ្យកែចិត្ត កែគំនិតប្រព្រឹត្តទៅតាមផ្លូវល្អវិញ ដូចជាអង្គុលីមារអីចឹងដែរ ព្រះពុទ្ធអង្គទៅបញ្ឈប់កុំឲ្យអង្គុលីមារហ្នឹងធ្វើការអាក្រក់ តែលោកយកមកអប់រំឲ្យបួស ហ្នឹងអប់រំមួយហើយ ។ តែយើងមិនមែនថា ឲ្យមកបួសអីចឹងទេ យើងអាចថាមកចូលអប់រំទៅតាមផ្លូវសង្គមដែលយើងត្រូវការដែលយើងនាំគ្នាជួយកសាងជាតិទៅតាមផ្លូវណាដែលល្អអីចឹងទៅ ។

នៅក្នុងឆ្នាំ១៩៩៤ រាជរដ្ឋាភិបាលកម្ពុជាបានចេញច្បាប់មួយដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ប៉ុន្តែបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឲ្យចូលរួមរស់ក្នុងសង្គមជាតិកម្ពុជាវិញ ហើយបានលើកលែងទោសដល់មេដឹកនាំខ្មែរក្រហមមួយចំនួន ដូចជាករណី អៀង សារី ជាដើមដែលត្រូវបានតុលាការបដិវត្តន៍ប្រជាជនកម្ពុជាកាត់ឲ្យជាប់ទោសពីបទប្រល័យពូជសាសន៍នៅឆ្នាំ១៩៧៩ ។ រីឯច្បាប់ដើម្បីកាត់ទោសខ្មែរក្រហម គឺជាការស្រាយ"ពៀរ"ដែលធ្វើឲ្យស្របទៅតាមព្រះពុទ្ធបណ្តាំថា "ពៀររំងាប់ដោយការមិនចងពៀរ" ។

ទាក់ទិននឹងសំណួរសួរថា តើក្នុងរបបខ្មែរក្រហមរឿងរ៉ាវនៃការសម្លាប់មនុស្ស វាជារឿងផ្លូវលោក ឬផ្លូវធម៌? ឆ្លើយនឹងសំណួរនេះ ព្រះមហាសុមេធាធិបតី ទេព វង្ស ក៏បានមានសង្ឃដីកាថា នេះបើតាមលោកគាពិចារណាក៏មិនជ្រៅជ្រះ មិនដាច់ស្រេចដែរ ។ ហេតុម៉េចបានថាដូច្នោះ? មកអំពីសត្វជាអ្នកអាស្រ័យកម្ម ។ "កម្ម" បានន័យថាអំពើដែលធ្វើ ។...មិនដឹងជាប៉ុល ពត គេចាប់ផ្តើមធ្វើ ឬក៏ជាពួកមួយមកពីផលហេតុអ៊ី ។ បើថា ប៉ុល ពត គេមិនចាប់ផ្តើមធ្វើទេ អានេះពៀររបស់ពួកយើងហ្នឹង វាមានពៀរពីអតីតមក ។ "សោចបុព្វេ ចកត្ត បុញ្ញកា" នេះ វាហុចឲ្យពីអតីតកាលមក "អតីតា ជាតបច្ចុប្បន្នា ធម្មា" នោះ ។

ក្នុងរឿងកម្មពៀរនេះ មានសំណួរចោទសួរថាតើមេដឹកនាំ



វត្តអម្ពិលបី

រូបថតឆ្នាំ១៩៧៩

ខ្មែរក្រហមសព្វថ្ងៃនេះបានទទួលកម្មដែលគេបានប្រព្រឹត្តហើយឬនៅ? ឆ្លើយនឹងសំនួរនេះ សម្តេចព្រះសុគន្ធាធិបតី ប៊ូរ គ្រី មានសង្ឃដីកាថា ពិភពលោកគេស្អប់គាត់ គេដាក់ទោសគាត់ ទាំងអស់ហ្នឹងជាបាបកម្មរបស់គាត់ហើយ ឃើញទេអាហ្នឹងគាត់បាន

ទទួលរបស់គាត់ហើយ ។ សព្វថ្ងៃពិភពលោកមានអង្គការសហប្រជាជាតិជាដើម គេចេះតែទទូចដើម្បីនឹងកាត់ទោសដាក់ទោសគាត់ហ្នឹង អាហ្នឹងសុទ្ធតែបាបកម្មរបស់គាត់ហើយ ។



សម្តេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី មានសង្ឃដីកាបញ្ជាក់បន្ថែមថា ព្រះពុទ្ធជាម្ចាស់លោកថា យើងមានកម្មជារបស់ខ្លួន កើតមកមានកម្មមកជាមួយហើយ ។...បើអត់កម្មអត់កើតទេ កើតព្រោះកម្ម រស់នៅព្រោះកម្ម ស្លាប់ទៅក៏ព្រោះកម្ម ។

សម្តេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី មានសង្ឃដីកាបញ្ជាក់បន្ថែមទៀតថា ក្នុងព្រះពុទ្ធសាសនាមិនប្រើពាក្យបៃដន្យដាច់ខាត គឺសុទ្ធតែកម្មទាំងអស់ កម្មហ្នឹងនាំឲ្យទៅអីចឹង អំពើដែលយើងធ្វើហ្នឹងនាំយើងទៅអីចឹង ។...ប៉ុន្តែមនុស្សយើងបើយើងមិនជឿកម្ម យើងរកការស្ងប់អត់ឃើញទេ ក្នុងជីវិតរស់ក្នុងគ្រួសារក៏អីចឹង រស់នៅក្នុងសង្គមក៏អីចឹង ។

គ្រប់ទង្វើរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តប្រឆាំងនឹងជនរងគ្រោះរបស់ខ្លួន មិនអាចចាត់ទុកថា ជាបៃដន្យបានឡើយ ។ វាសុទ្ធតែជាចេតនានៃកម្មដែលខ្មែរក្រហមបានសាងមកទាំងអស់ ។ ប្រសិនបើខ្មែរក្រហមមិនជឿថា នេះជាកម្មរបស់ខ្លួនទេនោះ ខ្មែរក្រហមពិតជាមិនអាចរស់នៅក្នុងសង្គមបានឡើយ ។ វិធីល្អបំផុតដើម្បីឲ្យខ្មែរក្រហមអាចរួមរស់នៅក្នុងសង្គមបានលែងមានកម្មពៀរតទៅទៀតនោះ គឺត្រូវតែស្រាយនូវចំណងកម្មពៀរទាំងអស់នោះឲ្យជ្រះស្រឡះតាមរយៈការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ដើម្បីយុត្តិធម៌ និងការអភិវឌ្ឍសង្គមជាតិកម្ពុជាឈានទៅរកនីតិរដ្ឋ ។

នៅក្នុងន័យព្រះពុទ្ធសាសនា ក៏ដូចក្នុងន័យច្បាប់ដែរ ពៀរនឹងតាមផ្តន្ទាចំពោះអ្នកដែលប្រព្រឹត្តនូវអំពើបាប ។ ច្បាប់នឹងផ្តន្ទាទោសចំពោះបុគ្គលដែលប្រព្រឹត្តខុសនឹងច្បាប់ ។ ផ្អែកតាមគោលការណ៍ទូទៅនៃច្បាប់ គឺបុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។ បើច្បាប់ផ្តល់យុតិធម៌ពិតប្រាកដ កម្មពៀរនឹងលែងកើតមានទៀតហើយ ។ ការនាំយកមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមមកវិនិច្ឆ័យទោស គឺជាទង្វើមួយបង្ហាញនូវ«ពៀររំងាប់ដោយការមិនចងពៀរ» ។ ហេតុនេះ ការនាំយកមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស ពុំមែនជាការចងកម្មចងពៀរនោះទេ ប៉ុន្តែត្រូវធ្វើយ៉ាងណាដើម្បីធានាឲ្យមានយុត្តិធម៌មួយដែលមនុស្សទូទៅអាចទទួលយកបាន នោះទើបអាចចាត់ទុកថាជា«ពៀររំងាប់ដោយការមិនចងពៀរ»បាន ។ ទោះបីជាមានយល់ឃើញយ៉ាងណាក៏ដោយ សង្គមមានច្បាប់ ហើយច្បាប់មានតួនាទីសំខាន់ គឺស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដែលត្រូវបានរំលោភនៅក្នុងច្បាប់នៃសង្គម ។

**ថ្លង សុភារិទ្ធ**

# ដរាបណាគ្មានយុត្តិធម៌ ឡាច នី នៅតែខិលខល់នឹងស្រមោលអតីតកាល


ឡាច នី

រហូតមកដល់សព្វថ្ងៃនេះ ឡាច នី បានរស់នៅដោយដក់ជាប់នូវក្តីទុក្ខសោកយ៉ាងធ្ងន់ធ្ងរ ។ ឡាច នី បាន តូញត្អែរថា "ខ្ញុំមិនអាចបំភ្លេចប្រពន្ធកូនខ្ញុំបានទេ លុះត្រាតែខ្ញុំស្លាប់ ។ បើខ្ញុំនៅមានស្រមោលគឺនៅតែនឹកឃើញកូនប្រពន្ធរបស់ខ្ញុំ" ។ សុភមង្គលគ្រួសារបានរលាយបាត់អស់ពីជីវិត ឡាច នី បន្ទាប់ពីខ្មែរក្រហមបានយកប្រពន្ធនិងកូនជាទីស្រលាញ់ទាំង៧នាក់ទៅសម្លាប់នៅអំឡុងខែកក្កដា ឆ្នាំ១៩៧៧ ។

ឡាច នី កើតនៅឆ្នាំ១៩៣៧ នៅភូមិពោធិ៍ចិន្តាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ។ ក្នុងសម័យសង្គមរាស្ត្រនិយម ឡាច នី គឺជាអ្នកធូរធារម្នាក់ ។ គាត់រស់នៅនិងប្រកបរបរលក់ដូរនៅផ្សារស្វាយអន្ទរ ។ គាត់មានលទ្ធភាពបន្តការសិក្សានៅទីរួមខេត្តព្រៃវែងនិងនៅភ្នំពេញរហូតដល់ថ្នាក់ទី៥ ។

ឆ្នាំ១៩៦០ ឡាច នី បានចូលបម្រើការងារក្នុងក្រសួងសុរិយោដី ។ ឆ្នាំ១៩៦២ ឡាច នី បានរៀបការជាមួយនារីម្នាក់ឈ្មោះ ស៊ុំ សាន ។ ស៊ុំ សាន មានស្រុកកំណើត នៅជ្រោយចង្វាទីក្រុងភ្នំពេញ ។ ឪពុករបស់ ស៊ុំ សាន ជាកូនខ្មែរកាត់ចិន និងម្តាយជាជនជាតិវៀតណាម ។

ក្រោយពេលរៀបការរួច ភរិយារបស់ ឡាច នី បម្រើការជាចុងភៅនៅក្រុមហ៊ុននិហរ័ណអាហរ័ណរបស់ឥណ្ឌាឈ្មោះ "ហ្សាមីណង់ ដេស្សង់ ប៉ាលេ ដេស្វារី" នៅវិថីកាល់ម៉ែត ។ ចំណែក ឡាច នី បានលាឈប់ពីការងារនៅក្រសួងសុរិយោដី ។ នៅឆ្នាំ១៩៦៣ ឡាច នី បានសុំចូលបម្រើការខាងផ្នែកជំនួយការភាសាបារាំងនៅក្រុមហ៊ុន ហ្សាមីណង់ ដេស្សង់ ប៉ាលេ ដេស្វារី ជាមួយប្រពន្ធរបស់គាត់ ។ ទាំងពីរនាក់ប្តីប្រពន្ធធ្វើការនៅក្រុមហ៊ុននេះរហូតដល់ឆ្នាំ១៩៦៨ ទើបលាឈប់ពីការងារ ។

បន្ទាប់ពីនោះ ឡាច នី បានមកបង្រៀនភាសាបារាំងនៅសាលាឯកជននៅឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ។ បន្ទាប់ពីបង្រៀនបានប្រមាណ៦ខែ សភាពការណ៍ប្រទេសមានអស្ថិរភាព ឡាច នី សម្រេចចិត្តឈប់បង្រៀន ហើយនាំគ្រួសារត្រឡប់ទៅស្រុកកំណើតនៅខេត្តព្រៃវែងវិញ ។

ក្នុងរយៈកាលដែលក្រុមគ្រួសាររបស់ ឡាច នី រស់នៅភូមិពោធិ៍ចិន្តាំ ក្រោមការទំនុកបម្រុងពីឪពុកម្តាយរបស់ ឡាច នី ប្រពន្ធរបស់គាត់ក៏ប្រកបមុខរបរជាអ្នកលក់បន្លែនៅក្នុងផ្សារស្វាយអន្ទរ ។ ចំណែក ឡាច នី បង្រៀនសិស្សផង និងទៅទិញបន្លែនៅអ្នកលឿងឬនៅអូររាំងឪ មកឲ្យប្រពន្ធលក់ដូរផង ។ ការប្រកបរបរលក់បន្លែរួមផ្សំនឹងការបង្រៀនសិស្សផងនោះបានធ្វើឲ្យជីវភាពគ្រួសារ ឡាច នី ធូរធារគ្រាន់បើ ។

ឡាច នី បានឲ្យដឹងថា ភរិយារបស់គាត់ជាមនុស្សរួសរាយនិងមានសន្តានចិត្តល្អចំពោះបងប្អូនញាតិមិត្តជិតខាង ។ ពេលណាអ្នកជិតខាងមានទុក្ខធុរៈ ស៊ុំ សាន តែងតែចូលរួមចែករំលែកការខ្វះខាតនិងទុក្ខលំបាកជានិច្ច ។ ឡាច នី បាននិយាយថា "ប្រពន្ធខ្ញុំជាមេផ្ទះដ៏ល្អ ជាអ្នកផ្តល់សេចក្តីសុខដល់គ្រួសារ ជាអ្នកធ្វើឲ្យគ្រួសារមានសិរីសួស្តី ចេះស្រលាញ់ក្រុមគ្រួសារនិងញាតិមិត្តជិតខាង ។ គ្រួសារខ្ញុំមិនដែលមានការថ្នាំងថ្នាក់អ្វីជាមួយបងប្អូនញាតិមិត្តជិតខាងឡើយ" ។

សុភមង្គលគ្រួសាររបស់ ឡាច នី បានរលាយអស់ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលខ្មែរក្រហមចាប់ផ្តើមគ្រប់គ្រងប្រទេសកម្ពុជា ។ ក្នុងរបបខ្មែរក្រហម ឡាច នី ត្រូវបានកម្មាភិបាលខ្មែរក្រហមចាត់តាំងឲ្យបង្រៀនកុមារ ។ គាត់បានទទួលបញ្ជាឲ្យបង្រៀនអក្សរដល់កុមារតែក្នុងថិរវេលាតែ២ម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃ គឺក្រោយពេលបាយថ្ងៃត្រង់ ។ ពេលវេលាសល់ពីនោះ គាត់ត្រូវនាំកុមារទៅធ្វើពលកម្មនៅវាលស្រែនិងនៅកន្លែងផ្សេងៗទៀតតាមដែលថ្នាក់លើ

ចាត់តាំង ។ ចំណែកប្រពន្ធរបស់ ឡាច នី ដែលមានកូនតូច ត្រូវកម្មាភិបាល ខ្មែរក្រហមចាត់តាំងឲ្យធ្វើការងារក្នុងកងមីង១ គឺដកស្ទូង ច្រូតកាត់ ដាំបន្លែនៅជិតៗភូមិ ។

មុនពេលខ្មែរក្រហមយកប្រពន្ធនិងកូនរបស់ ឡាច នី ទៅសម្លាប់ ប្រធានឃុំឈ្មោះ ឡឹក ឆែម បានហៅ ឡាច នី ទៅសួរថា "ប្រពន្ធមិត្តឯងជាជនជាតិវៀតណាមឬក៏ខ្មែរ?" ។ ឡាច នី បានឆ្លើយថា "ប្រពន្ធខ្ញុំខ្មែរទេ ឪពុកជាកូនចៅចិន" ។ ឆែម ថា "មិនមែនទេ ជាជនជាតិវៀតណាម ត្រូវតែបញ្ជូនទៅប្រទេសវៀតណាមវិញ" ។ ទោះបី ឡាច នី ខំនិយាយយ៉ាងណាក៏ ឡឹក ឆែម មិនជឿថាប្រពន្ធរបស់ ឡាច នី មិនមែនជាជនជាតិវៀតណាមដែរ ។ ដោយអស់សង្ឃឹមក្នុងការអង្វរករ ឡាច នី ក៏សំណូមពរជាចុងក្រោយថា "បើមិត្តមិនជឿ ចង់ចាប់ប្រពន្ធនិងកូនខ្ញុំយកទៅក៏យកចុះ ខ្ញុំសុំទុកតែកូនច្បងម្នាក់ឈ្មោះ ដាលីដា ដែលធ្វើការនៅក្នុងកងចល័ត" ។ ឡឹក ឆែម នៅតែមិនព្រមដដែល ។ ឡឹក ឆែម បានប្រាប់ ឡាច នី ថា បើឪពុកជាជនជាតិវៀតណាម នឹងយកតែឪពុកទៅសម្លាប់ទេ ។ ប៉ុន្តែបើម្តាយជាជនជាតិវៀតណាម នឹងយកទាំងម្តាយទាំងកូនទៅសម្លាប់ទាំងអស់ ។ ឡឹក ឆែម បានបញ្ជាក់ថា "កូនកើតចេញពីទងសុកម្តាយ គេនិយាយថាមេកណ្តុរកូនក៏កណ្តុរដែរ" ។

ពេលត្រឡប់មកផ្ទះវិញ ឡាច នី មិនហ៊ានប្រាប់ប្រពន្ធថានឹងត្រូវខ្មែរក្រហមយកទៅសម្លាប់ទេ គ្រាន់តែនិយាយថា "ឯងអើយ! ឯងនិងកូនត្រូវគេបញ្ជូនទៅប្រទេសវៀតណាមហើយ" ។ គ្រាន់តែឮថាត្រូវខ្មែរក្រហមបញ្ជូនទៅប្រទេសវៀតណាម ប្រពន្ធរបស់ ឡាច នី កើតទុក្ខសម្រានមិនលក់រហូតដល់ថ្ងៃដែលកងឈ្លបខ្មែរក្រហមយកទៅសម្លាប់ ។ នៅថ្ងៃចុងក្រោយ ស៊ីសាន បានផ្តែផ្តាំប្តីទាំងក្រៀមក្រំថា "ឯងត្រូវថែរក្សាខ្លួន នៅឲ្យបានសុខសប្បាយ" ។

ក្នុងអំឡុងខែកក្កដា ឆ្នាំ១៩៧៧ ខ្មែរក្រហមបានយកប្រពន្ធនិងកូនរបស់ ឡាច នី ទៅសម្លាប់ ។ ខណៈពេលនោះ ឡាច នី ត្រូវខ្មែរក្រហមចាប់ដាក់មន្ទីរឃុំឃាំង ។ ខ្មែរក្រហមធ្វើបែបនេះ ដើម្បីបង្ការកុំឲ្យ ឡាច នី តវ៉ាតាមទៅស្លាប់ជាមួយប្រពន្ធកូនដែរ ព្រោះករណីបែបនេះធ្លាប់កើតមានចំពោះអ្នកមុនៗរួចមកហើយ ។

ប្រពន្ធនិងកូនតូចៗ៦នាក់របស់ ឡាច នី ត្រូវកងឈ្លបដឹកតាមរទេះសេះទៅ ចំណែកកូនស្រីច្បងអាយុ១៣ឆ្នាំឈ្មោះ ដាលីដា មិនបានទៅជាមួយក្នុងគ្រានោះទេ ព្រោះជាប់ធ្វើការងារនៅឯកងចល័ត ។ មុនពេលត្រូវចាប់ខ្លួនមួយថ្ងៃ ដាលីដា ត្រូវឈ្លបតាមហៅពីកងចល័តឲ្យត្រឡប់មកផ្ទះវិញ ។ ថ្ងៃនោះ ដាលីដា ដេកនៅផ្ទះជីដូនជីតានៅខាងលិចសាលាស្រុកព្រៃវែង ។ ឡាច នី និយាយថា "នៅយប់នោះកូនខ្ញុំអត់ដេកទេ យំទល់ភ្លឺ ហើយនិយាយថា ខ្ញុំមិនទៅទេ នៅជាមួយយាយ នៅជាមួយតា ។ កូនខ្ញុំដឹងខ្លួនថាខ្មែរក្រហមយកទៅសម្លាប់ ។ ព្រឹកឡើង កូនខ្ញុំត្រូវឈ្លបដេញចាប់ដូចសត្វជ្រូក ។ កូនខ្ញុំរត់ឲ្យគេជួយពេញភូមិ វេទនាណាស់" ។ ដាលីដា ត្រូវឈ្លបខ្មែរក្រហមខុបតាមកង់យកទៅសម្លាប់ជាមួយម្តាយនិងប្អូនៗ ។

ឡាច នី ជាប់នៅក្នុងមន្ទីរឃុំឃាំងអស់រយៈពេល២ខែ ទើបខ្មែរក្រហមដោះលែងវិញ ។ ចេញពីគុកវិញ ឡាច នី បានទទួលដំណឹងអំពីការស្លាប់ប្រពន្ធនិងកូនទាំង៧នាក់របស់គាត់ ។ ឡាច នី ឈឺចាប់កើតទុក្ខរហូតធ្លាក់ខ្លួនវិកលចរិត ស្រែករកកូនទាំងយប់ទាំងថ្ងៃ ។ ឡាច នី បានបញ្ជាក់នាពេលក្រោយថា "ខួរក្បាលខ្ញុំក្រឡាប់ចាក់ទាំងអស់ ផែនដីឃ្លេងឃ្លោងអស់ហើយ មិនដឹងលិចកើតទេ ដើមឈើក្រឡាប់មែកចុះក្រោម ។ ខ្ញុំដើរស្រែករកកូនទាំងយប់ទាំងថ្ងៃ ឃើញកូនគេថាកូនឯង ដើរឱបតែកូនគេពេញទាំងភូមិ" ។

ប្រមាណមួយឆ្នាំក្រោយពីប្រពន្ធកូនត្រូវខ្មែរក្រហមសម្លាប់ ឡាច នី ត្រូវកម្មាភិបាលខ្មែរក្រហមបង្ខំឲ្យរៀបការប្រពន្ធថ្មីទៀត ។ ឡាច នី ត្រូវរៀបការរួមជាមួយគូស្រករចំនួន១៩គូ ក្នុងនោះមានឈ្មោះ ឃុន ម៉ុន ដែលមានរឿងរ៉ាវគ្រួសារដូច ឡាច នី ដែរ ។ ក្រោយពេលរៀបការរួចខ្មែរក្រហមបានជម្លៀស ឡាច នី និងក្រុមគ្រួសារ ឪពុកម្តាយ បងប្អូន ត្រូវខ្មែរក្រហមជម្លៀសទៅរស់នៅដីខ្វាញ់ គឺទៅភូមិអាងទំលែង និងភូមិថ្កុកត្រពាំងក្នុងស្រុកស្វាយដូនកែវ ខេត្តពោធិសាត់ ។ ខ្មែរក្រហមបាននិយាយប្រាប់ថា ដីខ្វាញ់សម្បូរស្រូវ និងផ្លែឈើ ប៉ុន្តែតាមពិតដីខ្វាញ់ជាកន្លែងលត់ដំ ចាប់បង្ខំឲ្យមនុស្សធ្វើការយ៉ាងធ្ងន់ធ្ងរ

អាហារហូបមិនគ្រប់គ្រាន់ ។ មួយថ្ងៃៗ ឃើញតែមនុស្សស្លាប់ដោយសារកង្វះចំណីអាហារ ធ្វើពលកម្មហួសកម្លាំង និងចាប់យកទៅសម្លាប់ទាំងហ្វូងៗ ។

ក្រោយការដួលរលំនៃរបបខ្មែរក្រហមនាឆ្នាំ១៩៧៩ ឡាច នី បានត្រឡប់មកស្រុកកំណើតវិញ និងបានដឹងថា ប្រពន្ធនិងកូនមុនរបស់គាត់ត្រូវខ្មែរក្រហមសម្លាប់នៅភូមិក្រាំងតរ ។ ក្រាំងតរ ជាកន្លែងសន្តិសុខនិងជាទីតាំងសម្លាប់មនុស្សដ៏ធំមួយនៅក្នុងស្រុកព្រៃវែង ។ ជនរងគ្រោះរាប់ម៉ឺននាក់ដែលស្លាប់នៅក្រាំងតរ មិនមែនសុទ្ធសឹងជាជនជាតិវៀតណាមទេ មានទាំងជនជាតិខ្មែរនិងព្រះសង្ឃទៀតផង ។

ភាពអស់សង្ឃឹមបានគ្របដណ្តប់មកលើជីវិតរបស់ ឡាច នី រហូតមកដល់បច្ចុប្បន្ននេះ ។ ទោះបីជាខ្មែរក្រហមបង្ខំឲ្យគាត់រៀបការប្រពន្ធក្រោយដើម្បីបំភ្លេចប្រពន្ធមុនក៏ដោយ ក៏គាត់នៅតែមិនអាចបំភ្លេចបានដដែល ។ អារម្មណ៍របស់ ឡាច នី នៅតែវិលវល់ជាមួយស្រមោលអតីតកាលរបស់គាត់ ។ ឡាច នី បញ្ជាក់ថា «វាគួរឲ្យអាណោចអធមណាស់ដែលប្រពន្ធកូនត្រូវស្លាប់អស់ ខ្ញុំរស់នៅតែម្នាក់ឯង ។ ពេលណារំឭកដល់ប្រពន្ធកូនខ្ញុំម្តងៗ ខ្ញុំមានអារម្មណ៍ហាក់ដូចជាកូនៗទាំងអស់របស់ខ្ញុំមកអង្គុយពីមុខខ្ញុំអ៊ីចឹង» ។

ឡាច នី សង្ឃឹមថា អារម្មណ៍របស់គាត់នឹងបានធូរស្រាលឡើងវិញនៅពេលណាដែលមានតុលាការឯករាជ្យមួយជំនុំជម្រះទោសអតីតមេដឹកនាំខ្មែរក្រហម ដើម្បីរកយុត្តិធម៌ឲ្យប្រពន្ធ កូនរបស់គាត់ និងជនរងគ្រោះទាំងឡាយដែលបានស្លាប់យ៉ាងអយុត្តិធម៌ក្រោមរបបខ្មែរក្រហម ។ **ឡុង ដានី**

# ចម្លើយសារភាពរបស់ឪពុកខ្ញុំ

លោកនាយកជាទីរាប់អាន ខ្ញុំតែងអានដោយយកចិត្តទុកដាក់រាល់ទស្សនាវដ្តី «ស្វែងរកការពិត» ដែលមជ្ឈមណ្ឌលរបស់លោកបានចេញផ្សាយជាទៀងរាល់ខែ ។ ការអានឯកសារទាំងនេះធ្វើឲ្យខ្ញុំនឹកឃើញនូវសេចក្តីឈឺចាប់ឥតគណនារបស់ឪពុកម្តាយខ្ញុំ ក៏ដូចជាប្រជាពលរដ្ឋខ្មែរដទៃទៀតដែលត្រូវបាត់បង់ជីវិតដោយសារនយោបាយសាហាវយង់ឃ្នងគួរឲ្យខ្ពើមរអើមរបស់អ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ ។

ថ្មីៗនេះខ្ញុំបានស្រាវជ្រាវដឹងថា ឪពុកខ្ញុំឈ្មោះ **ពីង គិមស៊ា** ដែលជាវេជ្ជបណ្ឌិតម្នាក់នៅបាត់ដំបង ត្រូវបានពួកឧក្រិដ្ឋជនឃោរឃៅនេះធ្វើទារុណកម្មរហូតដល់ស្លាប់នៅគុកទួលស្លែង ។ ជាភ័ព្វសំណាងរបស់ខ្ញុំ តាមរយៈ CD របស់មជ្ឈមណ្ឌលរបស់លោក ខ្ញុំក៏បានប្រទះឃើញរូបថត(លេខសម្គាល់០២៥៧២) ព្រមទាំងទិន្នន័យរបស់គាត់មួយចំនួនដូចជូនភ្ជាប់មកជាមួយនេះ ។ តែខ្ញុំមិនអាចរកឃើញឯកសារដែលពួកឆ្មាំគុកទួលស្លែងបានបង្ខំគាត់ឲ្យសរសេរ «សារភាព» នោះឡើយ ។

អាស្រ័យហេតុនេះ ខ្ញុំសូមលោកនាយក មេត្តាអនុញ្ញាតជួយផ្តល់អត្ថបទចម្លងនៃ«ចម្លើយសារភាព»របស់ឪពុកខ្ញុំដើម្បីអាចស្វែងយល់ពីមូលហេតុនៃមរណភាពរបស់គាត់ដោយអនុគ្រោះ ។

ខ្ញុំសូមអរគុណទុកជាមុនចំពោះអំពើដ៏សប្បុរសធម៌គួរជាទីគោរពរបស់លោក ។ សូមជូនពរដល់លោកបានទទួលជោគជ័យប្រសើរថែមទៀតក្នុងការស្រាវជ្រាវចងក្រងឯកសារឧក្រិដ្ឋកម្មរបស់ជនប្រល័យពូជសាសន៍ដែលនឹងត្រូវយកមកកាត់ទោសនាពេលខាងមុខនេះ ។

ថ្ងៃទី២៣ ខែមករា ឆ្នាំ២០០១

**ស៊ា កុសល**




រូបថត ពីង គិមស៊ា ។ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពីង គិមស៊ា ជានាយកមន្ទីរសុខាភិបាលខេត្តបាត់ដំបង និង ជាប្រធានមន្ទីរពេទ្យធំបាត់ដំបង ។ ពីង គិមស៊ា បានទទួលសញ្ញាបត្រវេជ្ជបណ្ឌិតពីក្រុងប៉ារីស ប្រទេសបារាំង ។



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះ តាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth! For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 32, August 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance;
the Royal Danish Government; Swedish International Development Co-operation Agency(Sida);
and the Royal Netherlands Government, *The Hague*.